# ព្រឹត្តិបត្រពន្ធដារ

ត្រីមាសទី៣ ឆ្នាំ២០២៤










លេខ៖ ១១

កក្កដា - កញ្ញា ២០២៤

# អារម្ភកថា



រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដែលមានសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីដំបូង នីតិកាលទី៧ នៃរដ្ឋសភា នៅថ្ងៃព្រហស្បតិ៍ ទី២៤ ខែសីហា ឆ្នាំ២០២៣ និងបានប្រកាសដាក់ចេញ "**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១**" ដើម្បីជំរុញកំណើនសេដ្ឋកិច្ច បង្កើតការងារ ធានាសមធម៌ បង្កើនប្រសិទ្ធភាព និងរក្សាចីរភាព សំដៅឆ្លើយតបនឹងបំណងប្រាថ្នាប្រជាជន ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ និងឆ្នាំ២០៥០ ជាប្រទេសមានចំណូលខ្ពស់។

ភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋ និងវិស័យឯកជននៃរាជរដ្ឋាភិបាលកម្ពុជា បាននិងកំពុងគាំទ្រនិងចូលរួមយ៉ាងសកម្មក្នុងការអនុវត្តកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាលថ្មីអាណត្តិទី៧ ដើម្បីសម្រេចបាននូវបំណងប្រាថ្នាទាំងពីរខាងលើ។ ស្របជាមួយគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានអគ្គនាយកដ្ឋានពន្ធដារជាសេនាធិការ និងមានតួនាទីប្រមូលនិងគ្រប់គ្រងចំណូលពន្ធផ្ទៃក្នុងដែលជាផ្នែកមួយដ៏សំខាន់នៃថវិកាសម្រាប់អភិវឌ្ឍជាតិ ក៏បាននិងកំពុងបន្តប្តេជ្ញាយកចិត្តទុកដាក់លើការកែទម្រង់ទាំងគោលនយោបាយនិងរដ្ឋបាលសារពើពន្ធ ពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ប្រកបដោយភាពសុចរិត និងស្មើភាពចំពោះអ្នកជាប់ពន្ធ ដើម្បីជំរុញអនុលោមភាពដោយស្ម័គ្រចិត្តឈានទៅសម្រេចបាននូវការប្រមូលចំណូលពន្ធប្រកបដោយចីរភាព ក្នុងគោលដៅលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនកម្ពុជា។ ជាមួយគ្នានេះ ក្នុងទិសដៅផ្តល់សេវាគ្រប់មធ្យោបាយជូនអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរ និងទទួលបានព័ត៌មានត្រឹមត្រូវនិងទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារបានរៀបចំបោះពុម្ពព្រឹត្តិបត្រពន្ធដារប្រចាំត្រីមាសចំនួន ១០ លេខ តាំងពីដើមឆ្នាំ២០២២ និងបន្តចងក្រងបោះពុម្ព សម្រាប់ត្រីមាសទី៣ ឆ្នាំ២០២៤ ទៀត ជាមួយនឹងមាតិកា រួមមាន ព្រឹត្តិការណ៍សំខាន់ៗ, ស្ថានភាពនៃការគ្រប់គ្រងប្រមូលចំណូលពន្ធ, វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូលនិងមុខងារគាំទ្រ, បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងគោលនយោបាយសារពើពន្ធ, កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ និងការផ្សព្វផ្សាយនិងបញ្ជ្រាបវប្បធម៌បង់ពន្ធ។

ក្នុងនាមជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ខ្ញុំមានជំនឿថាលោក លោកស្រី សាធារណជន និងស្ថាប័នជាតិ-អន្តរជាតិ នឹងជ្រាបកាន់តែច្បាស់អំពីស្ថានភាពគ្រប់គ្រងការប្រមូលចំណូលពន្ធនិងវឌ្ឍនភាពថ្មីៗ ជាពិសេសកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការធ្វើបច្ចុប្បន្នកម្មបទប្បញ្ញត្តិនិងទំនើបកម្មរដ្ឋបាលសារពើពន្ធនិងប្រព័ន្ធបច្ចេកវិទ្យា ស្របតាមគោលនយោបាយ ទស្សនវិស័យ និងទិសដៅរបស់រាជរដ្ឋាភិបាលកម្ពុជាដែលបានដាក់ចេញតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៕

ថ្ងៃចន្ទ ១៣ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ពុទ្ធសករាជ ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

# ព្រឹត្តិបត្រពន្ធដារ

## ត្រីមាសទី៣ ឆ្នាំ២០២៤

**សមាសភាពទទួលបន្ទុកតាក់តែង និពន្ធ និងបោះពុម្ពព្រឹត្តិបត្រពន្ធដារ**

| | | |
|---|---|---|
| និពន្ធនាយក | ៖ | ឯកឧត្តម **គង់ វិបុល** |
| គណៈដឹកនាំ | ៖ | លោក **វៀម រដ្ឋា** និងលោក **កែ ឈុំបញ្ញា** |
| អ្នករៀបរៀងអត្ថបទ | ៖ | លោកស្រី **សេង ច័ន្ទមុន្នី** លោកស្រី **ជេត ពុទ្ធាវី** និងលោក **រិន ណារ៉ូ** |
| អ្នករចនា | ៖ | លោក **លឹម សិទ្ធិ** កញ្ញា **ឈៀង សុខឡេង** និងលោក **សារិន ម៉េងហៀង** |
| អ្នកផ្តល់រូបភាព | ៖ | លោក **ទិត្យ ចំរើនបញ្ញា** លោក **សុន្ទរៈ ត្រដឹម** និងលោក **ឥន្ទ វាសនា** |
| អ្នកស្រាវជ្រាវ | ៖ | លោក **ជុំ សូលីវណ្ណា** លោក **សំរិទ្ធ មករា** លោក **រិទ្ធ ភីណា** កញ្ញា **សុធីរ វឌ្ឍនា** លោកស្រី **សាវិន វីនីហ្សា** និងលោក **អាន ចាន់ថាណារិទ្ធ** |
| អ្នកកែសម្រួលអក្ខរាវិរុទ្ធ | ៖ | លោក **អ៊ុន សំបុក** និងលោក **ជា ពិសិដ្ឋ** |
| អ្នកបោះពុម្ព | ៖ | លោក **ស៊ុនលី ដឺនី** |
| អ្នកផ្សព្វផ្សាយព័ត៌មាន និងចែកចាយ | ៖ | លោកស្រី **ឌីពៅ ទិត្យធីយ៉ា** លោកស្រី **ថុង ស្រីពៅ** លោក **មូ សុភ័ក្ត្រ** និងលោក **ឡាង ភក្ត្រា** |

# មាតិកា

**ព្រឹត្តិការណ៍សំខាន់ៗ**.....................................................................................៦

**ផ្នែកទី១៖ ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ**

១. លទ្ធផលការងារប្រមូលចំណូលពន្ធ.....................................................................២៩

២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ........................................................២៩

៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ.......................................................៣០

៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ..............................................៣១

**ផ្នែកទី២៖ វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ**

១. ការចុះបញ្ជីពន្ធដារ..........................................................................................៣៥

២. ការផ្តល់សេវាអ្នកជាប់ពន្ធ....................................................................................៣៥

៣. ការចាត់ចែងលិខិតប្រកាសពន្ធ.............................................................................៤២

៤. ការធ្វើសវនកម្មពន្ធដារ.......................................................................................៤៣

៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា.....................................................................៤៣

៦. បច្ចេកវិទ្យាព័ត៌មាន..........................................................................................៤៤

**ផ្នែកទី៣៖ បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ**

១. អនុក្រឹត្យ.......................................................................................................៥១

២. ប្រកាស.........................................................................................................៥២

៣. សេចក្តីណែនាំ.................................................................................................៥២

៤. សេចក្តីជូនដំណឹង............................................................................................៥៣

**ផ្នែកទី៤៖ កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ**

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ..........................................................៥៧

២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន..............................................................៧៣

៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ.........................៧៥

**ផ្នែកទី៥៖ ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលវប្បធម៌បង់ពន្ធ**

១. កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ..........................................៨២

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ..........................................................៨៥

៣. សិក្ខាសាលាសំខាន់ៗ.........................................................................................៨៦

**សំណួរ និងចម្លើយ**.............................................................................................១១០

# ទស្សនវិស័យ

អគ្គនាយកដ្ឋានពន្ធដារ ជាស្ថាប័នសាធារណៈ
ដែលត្រូវបានជឿជាក់ គោរព និងទទួលស្គាល់លើ
គុណភាពនិងជំនាញ ក្នុងការប្រមូលចំណូលពន្ធក្នុងស្រុក
ដើម្បីចូលរួមអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព

# បេសកកម្ម

អគ្គនាយកដ្ឋានពន្ធដារ ពង្រឹងការអនុវត្តច្បាប់
និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ និងផ្តល់សេវាប្រកបដោយ
ស័ក្តិសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងសុចរិតភាព ដើម្បីធានាបាននូវប្រសិទ្ធភាព
នៃការប្រមូលចំណូលពន្ធ និងលើកកម្ពស់អនុលោមភាពដោយស្ម័គ្រចិត្ត

# គុណតម្លៃ

អគ្គនាយកដ្ឋានពន្ធដារបំពេញបេសកកម្ម និង
ធ្វើប្រតិបត្តិការរបស់ខ្លួន ដោយប្រកាន់ខ្ជាប់នូវគុណតម្លៃ ដូចខាងក្រោម ៖

| ការអនុវត្ត | វិជ្ជាជីវៈ | ស័ក្តិសិទ្ធិភាព | សុចរិតភាព | ភាពបត់បែន |
|---|---|---|---|---|
| អនុវត្តច្បាប់ គាំទ្រអ្នកជាប់ពន្ធដែលមានអនុលោមភាព តែម៉ឺងម៉ាត់ចំពោះអ្នកជាប់ពន្ធដែលមិនមានអនុលោមភាព | ប្រើប្រាស់ក្រមសីលធម៌វិជ្ជាជីវៈ និងជំនាញ ដើម្បីផ្តល់នូវសេវាដែលមានភាពសាមញ្ញ ងាយស្រួល ឆ្លាតវៃ និងនវានុវត្តន៍ | ប្រើប្រាស់ធនធានដោយសន្សំសំចៃ ទាន់ពេលវេលា និងចំគោលដៅ | ផ្តល់សេវាអ្នកជាប់ពន្ធដោយស្មើភាព តម្លាភាព និងស្អាតស្អំ | ឆ្លើយតបយ៉ាងសកម្មទៅនឹងបញ្ហាប្រឈម និងទាញយកប្រយោជន៍ពីគ្រប់ឱកាសដែលមាន |

# គោលបំណង

អគ្គនាយកដ្ឋានពន្ធដារបានកំណត់ចេញនូវគោលបំណងជាយុទ្ធសាស្ត្រសំខាន់ៗ
ចំនួន៣ សម្រាប់ជាត្រីវិស័យក្នុងការតម្រង់ទិសនៃកំណែទម្រង់រដ្ឋបាលសារពើពន្ធ

| គោលបំណងទី១ | គោលបំណងទី២ | គោលបំណងទី៣ |
|---|---|---|
| បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវា និងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ | បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក | បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ |

# “យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១”

## ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព

## កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០

### បាវចនា ៥៖

កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព

### អាទិភាពគន្លឹះ ៥៖

មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យាឌីជីថល

### គោលដៅយុទ្ធសាស្ត្រ ៥៖

១.កំណើនសេដ្ឋកិច្ច ៧% ប្រចាំឆ្នាំ ២.បង្កើនការងារ (បរិមាណ និងគុណភាព) ៣.កាត់បន្ថយភាពក្រីក្រ ៤.ពង្រឹងប្រសិទ្ធភាពការងារ និង៥.ចីរភាពនៃការអភិវឌ្ឍសង្គមជាតិនិងការកសាងភាពធន់

### ស្នូលនៃយុទ្ធសាស្ត្រ ៥៖ អភិបាលកិច្ច

១. ការកែទម្រង់ស្ថាប័ន
២. ការពង្រឹងប្រសិទ្ធភាពការងារ
៣. ការពង្រឹងភាពស្អាតស្អំក្នុងរដ្ឋបាលសាធារណៈ
៤. ការពង្រឹងប្រសិទ្ធភាពច្បាប់ និងប្រព័ន្ធយុត្តិធម៌ និង
៥. អភិបាលកិច្ចវិស័យឯកជន

### បរិស្ថានគ្របដណ្តប់ ៥៖

១.ការបន្តពង្រឹងសន្តិភាព ស្ថិរភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
២.ការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យផ្អែកច្បាប់និងឈ្លាសវៃ
៣.ការធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច
៤.ការកសាងភាពជាដៃគូ និង
៥.ការបន្តធ្វើសមាហរណកម្មស៊ីជម្រៅក្នុងតំបន់ និងសកលលោក

### បញ្ចកោណយុទ្ធសាស្ត្រ ៥៖

**បញ្ចកោណទី១៖** ការអភិវឌ្ឍមូលធនមនុស្ស
**បញ្ចកោណទី២៖** ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង
**បញ្ចកោណទី៣៖** ការអភិវឌ្ឍវិស័យឯកជន និងការងារ
**បញ្ចកោណទី៤៖** ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន
**បញ្ចកោណទី៥៖** ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល

### កម្មវិធីគោលនយោបាយអាទិភាព ៦ សម្រាប់ចាប់ផ្តើមអនុវត្តភ្លាមក្នុងឆ្នាំ២០២៣៖

១.ការពង្រីកសេវាថៃទាំសុខភាព ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកល ២.ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ជូនដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យនៅទូទាំងប្រទេស ៣.ការធ្វើស្ថាបនូបនីយកម្មកម្មវិធីជាតិជំនួយសង្គម សម្រាប់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះនៅក្នុងគ្រួសារក្រីក្រនិងគ្រួសារងាយរងហានិភ័យនៅក្នុងគ្រាមានវិបត្តិសេដ្ឋកិច្ច និងគ្រាមានអាសន្ន ៤.ការដាក់ចេញយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ (ចូលរួមក្នុងប្រព័ន្ធនិងអាចទទួលបានផលប្រយោជន៍ពីប្រព័ន្ធគាំពារសង្គមផ្លូវការ) ៥.ការដាក់ចេញនូវយន្តការសម្របសម្រួល និងកម្មវិធីហិរញ្ញប្បទាន សំដៅលើកស្ទួយផលិតកម្ម រកទីផ្សារ និងរក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ និង៦.ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ-សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស។

### វិធានការគន្លឹះ ៥៖

១.ការពង្រឹងសមត្ថភាពរដ្ឋបាលសាធារណៈ (ពង្រឹងគុណភាព ប្រសិទ្ធភាពនិងសមិទ្ធកម្មរបស់មន្ត្រី និងស្ថាប័ន) ២.ការលើកកម្ពស់គុណភាពអប់រំ (ពង្រឹងគុណភាពសាលារដ្ឋពីថ្នាក់មត្តេយ្យដល់មធ្យមសិក្សា-K12) ៣.ការលើកកម្ពស់គុណភាពសេវាសុខាភិបាល (ពង្រឹងសមត្ថភាពផ្តល់សេវាសុខភាពបឋមនៅមូលដ្ឋាន) ៤.ការពង្រឹងការអនុវត្តគោលនយោបាយ ៉ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព (កាត់បន្ថយ និងឈានទៅដល់ការលុបបំបាត់ការជួញដូរ និងការប្រើប្រាស់គ្រឿងញៀននៅក្នុងសហគមន៍) និង៥.ការពង្រឹងនិងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌។

# ព្រឹត្តិការណ៍សំខាន់ៗ



ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ និងសាខាពន្ធដារខេត្ត-ខណ្ឌនៅទូទាំងប្រទេសបាន ចូលរួមអបអរសាទរពិធីបើកការដ្ឋានព្រែកជីកហ្វូណន តេជោ

សូមអានពិស្តារនៅទំព័រទី ៨



**សម្តេចធិបតីនាយករដ្ឋមន្ត្រី** ថ្លែងអំណរគុណចំពោះ ក្រុមហ៊ុន ហ៊ិននីគែន ដែលជឿជាក់លើរាជរដ្ឋាភិបាល និងបន្តវិនិយោគនៅកម្ពុជា

សូមអានពិស្តារនៅទំព័រទី ១០



កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ

សូមអានពិស្តារនៅទំព័រទី ១១



ទស្សនកិច្ចផ្លូវការ របស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមជាគណៈអធិបតីក្នុងវេទិកាធុរកិច្ចនិងពាណិជ្ជកម្ម កម្ពុជា-ចិននិងជំនួបជាមួយវិនិយោគិនមួយចំនួនដែល កំពុងធ្វើការវិនិយោគនៅប្រទេសកម្ពុជា

សូមអានពិស្តារនៅទំព័រទី ១៤



កិច្ចប្រជុំពិភាក្សា និងពិនិត្យលទ្ធភាពក្នុងការធ្វើសន្ទានកម្មតភ្ជាប់ប្រព័ន្ធគ្រប់គ្រងវិនិយោគ (Investment Project Application-IPA) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

សូមអានពិស្តារនៅទំព័រទី ១៧



សិក្ខាសាលាស្តីពី "អនុលោមភាពឯកសារចុះបញ្ជីពន្ធដារជូនអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម"

សូមអានពិស្តារនៅទំព័រទី ១៩




វេទិកាពន្ធដារឆ្នាំ២០២៤រៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា (EUROCHAM) និងសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា (AMCHAM)

សូមអានពិស្តារនៅទំព័រទី ២១



សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ" និង "សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ"

សូមអានពិស្តារនៅទំព័រទី ២៣

# ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ និងសាខាពន្ធដារខេត្ត-ខណ្ឌនៅទូទាំងប្រទេស បានចូលរួមអបអរសាទរពិធីបើកការដ្ឋានព្រែកជីកហ្វូណនតេជោ



នាព្រឹកថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ព្រះរាជាណាចក្រកម្ពុជា ដែលបានបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ក្នុងស្មារតី "**គម្រោងរបស់ខ្មែរទាំងអស់គ្នា ដោយខ្មែរ និងដើម្បីខ្មែរគ្រប់រូប**"។ មិនខុសពីមន្ត្រីរាជការនៅគ្រប់ក្រសួង-ស្ថាប័ន អង្គភាពសាធារណៈ បុគ្គលិកក្នុងវិស័យឯកជន និងជនរួមជាតិខ្មែរគ្រប់រូបនៅទូទាំងប្រទេស ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ និងនៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ នាឱកាសដ៏ថ្លៃថ្លានេះ ក៏បានចូលរួមអបអរសាទរ ប្រកបដោយបរិយាកាសអធិកអធម កុះករ ក្លៀវក្លា គួរជាទីមោទនៈ។ គម្រោងព្រែកជីកហ្វូណនតេជោ ជាគម្រោងព្រែកជីកប្រវត្តិសាស្ត្រដ៏ធំលើកទី១របស់កម្ពុជា ក្រោមគំនិតផ្តួចផ្តើមប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងអំឡុងពេលដែលសម្តេចធ្វើជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ហើយបច្ចុប្បន្នគម្រោងនេះត្រូវបានដឹកនាំអនុវត្តយ៉ាងម៉ឺងម៉ាត់ ប្រកបដោយភាពម្ចាស់ការខ្ពស់ដោយ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

គម្រោងព្រែកជីកហ្វូណនតេជោ នឹងក្លាយជាគម្រោងដែលផ្តល់ផលប្រយោជន៍ដ៏មហាសាលដល់សង្គម-សេដ្ឋកិច្ចកម្ពុជា ព្រមទាំងជាសក្តានុពលថ្មីមួយបន្ថែមទៀតនៃការរីកចម្រើនអេកូធម្មជាតិ ពង្រីកផ្ទៃអាងទន្លេរក្សាបាននូវធនធានទឹកជូនប្រជាជនកម្ពុជា ជាពិសេសអត្ថប្រយោជន៍ក្នុងវិស័យដឹកជញ្ជូន រួមមាន ការកាត់បន្ថយពេលវេលា កាត់បន្ថយថ្លៃដឹកជញ្ជូន កាត់បន្ថយរំហូរនីតិវិធីនិងបែបបទសម្រាប់នាវាក្នុងការឆ្លងកាត់ទំនិញពីកម្ពុជាទៅសមុទ្រ។ លើសពីនេះ គម្រោងនេះនឹងជំរុញឱ្យមានការអភិវឌ្ឍផែរណេបថ្មីៗជាច្រើន បង្កើតតំបន់ពាណិជ្ជកម្មនិងតំបន់សេដ្ឋកិច្ចពិសេសពង្រីកតំបន់អភិវឌ្ឍន៍កសិកម្ម ធារាសាស្ត្រ វារីវប្បកម្ម ចិញ្ចឹមសត្វ ជួយរំដោះទឹកជំនន់ក្នុងរដូវវស្សា ជួយបង្កើនទិន្នផលត្រីទឹកសាបនៅតាមដងព្រែក ជំរុញការរីកចម្រើនវិស័យអចលនទ្រព្យក្នុងតំបន់ និងបង្កើនឱកាសការងារផ្សេងៗទៀតជាដើម៕


Hyper Hope


អរគុណ សន្តិភាព! ខ្ញុំស្រឡាញ់ សន្តិភាព!
អបអរសាទរ! ពិធីបើកការដ្ឋានសាងសង់ព្រែកជីក ហ្វូណនតេជោ


សាខាពន្ធដារ ខណ្ឌដង្កោ
DANGKOR TAX BRANCH









# សម្តេចធិបតីនាយករដ្ឋមន្ត្រី ថ្លែងអំណរគុណ ចំពោះក្រុមហ៊ុន ហ៊ិននីគែន ដែលជឿជាក់លើរាជរដ្ឋាភិបាល និងបន្តវិនិយោគនៅកម្ពុជា



ក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារជាមួយ លោក Jacco Van Der Linden អគ្គនាយកប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកនៃក្រុមហ៊ុន ហ៊ិននីគែន (Heineken) **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានថ្លែងអំណរគុណចំពោះទំនុកចិត្តនិងការជឿជាក់មកលើរាជរដ្ឋាភិបាលកម្ពុជា តាមរយៈការសម្រេចចិត្តបន្តការវិនិយោគនៅប្រទេសកម្ពុជា និងបានរួមចំណែកដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច រួមទាំងការបង្កើតការងារដោយផ្ទាល់និងប្រយោលនៅកម្ពុជា ក្នុងរយៈពេល៣ទសវត្សរ៍មកនេះ។ ជាមួយគ្នានេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក៏បានគូសរំលេចអំពីការបន្តយកចិត្តទុកដាក់ និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធានានូវបរិយាកាសវិនិយោគល្អប្រសើរប្រកបដោយភាពទាក់ទាញ តាមរយៈការដាក់ចេញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្ត និងកញ្ចប់វិធានការនានា ដើម្បីធានាបានការប្រកួតប្រជែងស្មើភាពគ្នា ជំរុញភាពជោគជ័យរបស់វិនិយោគិនដែលមានស្រាប់ និងទាក់ទាញវិនិយោគិនថ្មីៗបន្ថែមទៀត។

លោក Jacco Van Der Linden បានគោរពជម្រាបជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** អំពីប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុននៅប្រទេសកម្ពុជាក្នុងរយៈពេលកន្លងមក និងថ្លែងអំណរគុណចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ដែលតែងតែផ្តល់កិច្ចសហការ និងយកចិត្តទុកដាក់ចំពោះក្រុមហ៊ុន។ ទន្ទឹមនឹងនេះ លោកអគ្គនាយកប្រចាំតំបន់ ក៏បានប្តេជ្ញាចិត្តក្នុងការបន្តការវិនិយោគនៅកម្ពុជា ដោយអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ចូលរួមការពារអ្នកប្រើប្រាស់ និងរួមចំណែកលើកកម្ពស់ការទទួលខុសត្រូវក្នុងសង្គម រួមទាំងកិច្ចការពារបរិស្ថានផងដែរ។

គួរបញ្ជាក់ផងដែរថា អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងផ្តល់កិច្ចសហការយ៉ាងជិតស្និទ្ធក្នុងការជួយជ្រោមជ្រែងដល់ការបំពេញកាតព្វកិច្ចសារពើពន្ធ ព្រមទាំងពង្រឹងការប្រកួតប្រជែងដោយស្មើភាព (Level Playing Field) ចំពោះសហគ្រាសក្នុងវិស័យផលិតស្រាបៀរនិងភេសជ្ជៈគ្មានជាតិសុរា តាមរយៈការដាក់ចេញនូវវិធានការនានាជាអាទិ៍មានកាតព្វកិច្ចដាក់ឧបករណ៍វាស់ចំណុះស្រាបៀរនិងភេសជ្ជៈគ្មានជាតិសុរា (Flowmeter, Conductivity Meter, និង Field Control Box) ការដាក់កាមេរ៉ាសុវត្ថិភាពនៅតាមចំណុចឬបរិវេណនៃឧបករណ៍វាស់ចំណុះ និងមានមន្ត្រីប្រចាំការនៅគ្រប់រោងចក្រផលិតស្រាបៀរនិងភេសជ្ជៈគ្មានជាតិសុរាជាដើម៕

# កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធ ប្រចាំខែមិថុនានិងប្រចាំឆមាសទី១ ឆ្នាំ២០២៤ ព្រមទាំងទិសដៅ សម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ




នាព្រឹកថ្ងៃពុធ ទី២៤ ខែកក្កដា ឆ្នាំ២០២៤ នៅសាលប្រជុំសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធ ប្រចាំខែមិថុនា និងប្រចាំឆមាសទី១ ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តមបណ្ឌិតសភាចារ្យ **ជួ ទិជិត្ត** រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានវត្តមានចូលរួមរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ឯកឧត្តមអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ ព្រមទាំងវត្តមានចូលរួមរបស់លោក-លោកស្រីអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្តាល ទីចាត់ការពន្ធដាររាជធានីភ្នំពេញ សាលាជាតិពន្ធដារ សាខាពន្ធដារខេត្ត-ខណ្ឌ និងការចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Meeting) របស់ថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្តាល សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ៕





ឯកឧត្តមបណ្ឌិតសភាចារ្យ **ជូ វិជិត្ត**
រដ្ឋលេខាធិការប្រចាំការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ឯកឧត្តម **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ



ឯកឧត្តម **អ៊ីង លុយណា**
អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយ



ឯកឧត្តម **ជា វុធណា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក
នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង





ឯកឧត្តម **ជាប ជាវុធ**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



ឯកឧត្តម **អ៊ុំ សីហា**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



ឯកឧត្តម **ហេង សុខណាង**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



ឯកឧត្តម **ម៉ិញ បានកុសល**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



លោកជំទាវ **ប៊ុន នារី**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



ឯកឧត្តម **រ័ត្ន មុនី**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



លោក **លីម ដឹលុច**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



ឯកឧត្តម **លីម ហ៊ុយជីវ**
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

# ទស្សនកិច្ចផ្លូវការ របស់ ឯកឧត្តម គង់ វិបុល រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ចូលរួមជាគណៈអធិបតីក្នុងវេទិកាធុរកិច្ចនិងពាណិជ្ជកម្ម កម្ពុជា-ចិននិងជំនួបជាមួយវិនិយោគិនមួយចំនួនដែលកំពុងធ្វើការវិនិយោគនៅប្រទេសកម្ពុជា



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

នាថ្ងៃសុក្រ ទី២០ ខែកញ្ញា ឆ្នាំ២០២៤ តបតាមការអញ្ជើញពីសមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា (CCIA) ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានដឹកនាំគណៈប្រតិភូនៃអគ្គនាយកដ្ឋានពន្ធដារដើម្បីចូលរួមក្នុងវេទិកាធុរកិច្ចនិងពាណិជ្ជកម្មកម្ពុជា-ចិន ដែលប្រព្រឹត្តទៅនៅទីក្រុងស៊ិនជិន នៃសាធារណរដ្ឋប្រជាមានិតចិន ដោយមានការចូលរួមពីតំណាងសហគ្រាសប្រកបអាជីវកម្មប្រមាណជាង **៤០០ សហគ្រាស**។

តាមរយៈវេទិកាធុរកិច្ចនិងពាណិជ្ជកម្ម កម្ពុជា-ចិន នេះ ឯកឧត្តម **គង់ វិបុល** បានចែករំលែកជូនតំណាងសហគ្រាសដែលបានចូលរួមឱ្យបានជ្រាបអំពីបរិយាកាសវិនិយោគជាទូទៅ ក៏ដូចជាកត្តាអំណោយផលនានារបស់ប្រទេសកម្ពុជា រួមទាំងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខដឹកនាំ ក្នុងការបន្តរក្សាបាននូវសន្តិភាព ស្ថិរភាព និងសន្តិសុខក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ ឯកឧត្តមក៏បានអំពាវនាវ និងអញ្ជើញតំណាងសហគ្រាសទាំងអស់មកទស្សនានៅប្រទេសកម្ពុជាដោយផ្ទាល់ ដើម្បីសិក្សាឈ្វេងយល់ពីស្ថានភាពពិតប្រាកដ និងកត្តាអំណោយផលនានារបស់ប្រទេសកម្ពុជាក្នុងការចូលមកបណ្តាក់ទុនវិនិយោគប្រកបដោយទំនុកចិត្ត និងភាពជឿជាក់ ចៀសវាងការយល់ច្រឡំណាមួយតាមរយៈព័ត៌មានមិនពិតប្រាកដនិងមិនគ្រប់ជ្រុងជ្រោយ។

ជារួម វេទិកាធុរកិច្ចនិងពាណិជ្ជកម្មកម្ពុជា-ចិន នេះ បានប្រព្រឹត្តទៅដោយទទួលបានលទ្ធផលផ្លែផ្កាយ៉ាងល្អ ប្រកបដោយភាពជោគជ័យ ព្រមទាំងទទួលបានការវាយតម្លៃពីអ្នកចូលរួមជាវិជ្ជមាន និងប្រកបដោយភាពកក់ក្តៅ ជាពិសេសការបង្ហាញនូវចំណាប់អារម្មណ៍ក្នុងការអញ្ជើញមកទស្សនា និងបណ្តាក់ទុនវិនិយោគនៅព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសទស្សនកិច្ចនេះដែរ ឯកឧត្តមបានទទួលជួបជាមួយវិនិយោគិនចិនសំខាន់ៗមួយចំនួនដែលកំពុងប្រកបអាជីវកម្មនៅប្រទេសកម្ពុជា ដូចជាក្រុមហ៊ុនអាកាសចរណ៍ស៊ីវិលនៃប្រទេសចិនដែលមានការធ្វើដំណើរមកប្រទេសកម្ពុជា និងក្រុមហ៊ុន BYD ដែលមានគម្រោងវិនិយោគលើរោងចក្រដំឡើងរថយន្តអគ្គិសនីនៅប្រទេសកម្ពុជា ដើម្បីពិភាក្សាសំណេះសំណាល ក៏ដូចជាផ្តល់ការពិគ្រោះយោបល់ផ្នែកពន្ធដារនានានិងដោយផ្ទាល់ជូនវិនិយោគិនទាំងនោះ សំដៅគាំទ្របន្ថែមទៀតដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទាញនិងលើកទឹកចិត្តចំពោះការវិនិយោគក្នុងប្រទេសកម្ពុជា។ ទន្ទឹមនឹងនេះ ឯកឧត្តម ក៏បានឆ្លៀតពេលដ៏មានតម្លៃនេះ អញ្ជើញធ្វើទស្សនកិច្ចនៅក្រុមហ៊ុន Huawei ដោយផ្តោតលើការវិវត្តថ្មីៗនៃបច្ចេកវិទ្យាឆ្លាតវៃនានា និងបញ្ញាសិប្បនិម្មិត (AI) ជាពិសេស បច្ចេកវិទ្យាពាក់ព័ន្ធនឹងការគាំទ្រដល់ការគ្រប់គ្រងប្រមូលចំណូលពន្ធ និងការផ្តល់សេវាអ្នកជាប់ពន្ធ ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

កិច្ចជំនួបនិងទស្សនកិច្ចនេះ ក៏បានបញ្ចប់ប្រកបដោយលទ្ធផលផ្លែផ្កាល្អប្រសើរ និងក្រោមស្មារតីកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងការទទួលខុសត្រូវខ្ពស់ ក្នុងន័យសម្រួលដល់បរិយាកាសធុរកិច្ចរវាងប្រទេសទាំងពីរ និងជាពិសេសជំរុញការទាក់ទាញវិនិយោគិនលើវិស័យសំខាន់ៗក៏ដូចជាជំរុញការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជានាពេលអនាគត៕









H.E. KONG VIBOL
Minister Attached to the Prime Minister




សមាគមសហព័ន្ធអ្នកវិនិយោគកម្ពុជា
柬 埔 寨 投 资 者 商 会 联 盟
CAMBODIA CONFEDERATION OF INVESTORS ASSOCIATION





# កិច្ចប្រជុំពិភាក្សា និងពិនិត្យលទ្ធភាពក្នុងការធ្វើសន្ធានកម្មតភ្ជាប់ប្រព័ន្ធគ្រប់គ្រងវិនិយោគ (Investment Project Application-IPA) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា




នាព្រឹកថ្ងៃចន្ទ ទី១២ ខែសីហា ឆ្នាំ២០២៤ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិភាក្សា និងពិនិត្យលទ្ធភាពក្នុងការធ្វើសន្ធានកម្មតភ្ជាប់ប្រព័ន្ធគ្រប់គ្រងវិនិយោគ ( Investment Project Application – IPA ) របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមការដឹកនាំរបស់ឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។





លោកជំទាវ **ចម និម្មល**
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម



ឯកឧត្តម **ស៊ុន ចាន់ថុល** ឧបនាយករដ្ឋមន្ត្រី
អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា



ឯកឧត្តម **គុណ ញឹម** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា



ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា
ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ





# សិក្ខាសាលា ស្តីពី "អនុលោមភាពឯកសារចុះបញ្ជីពន្ធដារ ជូនអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម"



នារសៀលថ្ងៃអង្គារ ទី៩ ខែកក្កដា ឆ្នាំ២០២៤ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ឯកឧត្តម **គន់ ថិប៊ុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងសិក្ខាសាលា ស្តីពី "**អនុលោមភាពឯកសារចុះបញ្ជីពន្ធដារ ជូនអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម**" ក្រោមអធិបតីភាពលោកជំទាវ **ចម និម្មល** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងដោយមានវត្តមាន ឯកឧត្តម-លោកជំទាវ-លោក-លោកស្រី ថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមរបស់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ភ្នាក់ងារសេវាកម្មពន្ធដារ ចូលរួមផ្ទាល់ប្រមាណ **២០០ រូប**។

សិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយចំណុចសំខាន់ៗរួមមាន៖ ១.ការបំពេញតួនាទីរបស់អ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្មនិងអនុលោមភាពឯកសារចុះបញ្ជីពន្ធដារតាមរយៈថ្នាលបច្ចេកវិទ្យាព័ត៌មានឱ្យបានត្រឹមត្រូវ និងប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ ២.សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ បង្កើនការផ្សព្វផ្សាយនិងការបណ្តុះបណ្តាល អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធ្វើពាណិជ្ជកម្មនិងអនុលោមភាពសារពើពន្ធ ដើម្បីពង្រឹងសមត្ថភាពអ្នកតំណាងស្របច្បាប់ សំដៅធានាបាននូវអនុលោមភាពឯកសារការចុះបញ្ជីពាណិជ្ជកម្មនិងការចុះបញ្ជីពន្ធដារ ក៏ដូចជាការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពីក្រសួងស្ថាប័នផ្សេងទៀត និង៣.អ្នកតំណាងចុះបញ្ជី ត្រូវគោរពក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួនឱ្យមានភាពសុចរិត និងភាពស្មោះត្រង់ ដើម្បីបញ្ចៀសនូវភាពមិនប្រក្រតី ឬការមិនមានអនុលោមភាពចំពោះការបំពេញព័ត៌មាន និងភ្ជាប់ឯកសារមិនបានត្រឹមត្រូវ ឬក្លែងបន្លំឯកសារ។

ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកជំទាវរដ្ឋមន្ត្រី ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងពាណិជ្ជកម្ម ព្រមទាំងមានចំណាប់អារម្មណ៍ និងវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់អ្នកតំណាងស្របច្បាប់ ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ភ្នាក់ងារសេវាកម្មពន្ធដារ គឺបានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការឈ្វេងយល់ និងចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធ ក្នុងគោលដៅពង្រឹងអនុលោមភាពសារពើពន្ធ ជាពិសេសតាមរយៈអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត (Voluntary Compliance)។ អគ្គនាយកដ្ឋានពន្ធដារ

បាននិងបន្តយកចិត្តទុកដាក់ខ្ពស់ ក្នុងការពង្រឹងនិងសម្រួលពាណិជ្ជកម្ម និងការវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និងស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

**ខ្លឹមសារសំខាន់ៗនៃបទបង្ហាញរបស់ ឯកឧត្តម គង់ វិបុល ដើម្បីជំរុញនិងលើកទឹកចិត្តដល់ភ្នាក់ងារផ្តល់សេវាអ្នកជាប់ពន្ធទាំងអស់ ដូចខាងក្រោម៖**

- សូមអ្នកតំណាងស្របច្បាប់ក្នុងការស្នើសុំចុះបញ្ជីពាណិជ្ជកម្ម ភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ផ្តល់ព័ត៌មាន និងឯកសារឱ្យបានត្រឹមត្រូវ និងពិតប្រាកដ
- សូមភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ពង្រឹងក្រមសីលធម៌និងការផ្តល់សេវារបស់ខ្លួនឱ្យបានល្អត្រឹមត្រូវ ចៀសវាង ការសមគំនិត ជ្រោមជ្រែង ឬរៀបចំផែនការគេចវេះពន្ធ
- សូមឱ្យភ្នាក់ងារទាំងអស់ ចូលរួមជាមួយអគ្គនាយកដ្ឋានពន្ធដារ ក្នុងការពង្រឹងអនុលោមភាពការចុះបញ្ជីពន្ធដារ ដើម្បីលើកកម្ពស់ការប្រកួតប្រជែងដោយស្មើភាពគ្នា ក៏ដូចជាទប់ស្កាត់បទល្មើសពន្ធដារ
- បន្តជំរុញនិងបង្កើនល្បឿននៃការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធ (Digital Transformation of Tax Administration) ដើម្បីឱ្យអគ្គនាយកដ្ឋានពន្ធដារសម្រេចឱ្យបាននូវដំណើរបរិវត្តកម្មរដ្ឋបាលសារពើពន្ធពីជំនាន់ទី១.៥ (Tax Administration 1.5) ទៅជំនាន់ទី២.៥ (Tax Administration 2.5) និងឈានទៅដល់រដ្ឋបាលសារពើពន្ធជំនាន់ទី៣.0 (TaxAdministration3.0) ដែលដំណើរនេះក៏ស្របទៅតាមនិន្នាការនិងតម្រូវការដ៏លឿនរហ័សនៃការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធក្នុងតំបន់និងសកលលោក៕



*លោកជំទាវ **ចម និម្មល***
*រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម*



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា*
*ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*



# វេទិកាពន្ធដារ ឆ្នាំ២០២៤ រៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ( EUROCHAM ) និងសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា ( AMCHAM )




នាព្រឹកថ្ងៃពុធ ១ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ នៅសណ្ឋាគារសូហ្វីតែល ភ្នំពេញ ភូគីត្រា មានវេទិកាពន្ធដារ ឆ្នាំ២០២៤ Tax Forum 2024 ដែលត្រូវបានសហការរៀបចំដោយសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា ( EUROCHAM ) និងសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា ( AMCHAM ) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ឯកឧត្តម Jacques Pellet ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំងប្រចាំព្រះរាជាណាចក្រកម្ពុជា លោក Jost Kadel ប្រធានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៃស្ថានទូតអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា លោក Tassilo Brinzer ប្រធានសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា និងលោក Casey Barnett ប្រធានសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា ដោយមានការចូលរួមពីឯកឧត្តមអគ្គនាយករង ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងអភិបាល បណ្ណាធិការ និងតំណាងសហគ្រាសដែលជាសមាជិកនៃសភាពាណិជ្ជកម្មទាំងពីរ៕








*លោក* **Tassilo Brinzer**
*ប្រធានសភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា*




*ឯកឧត្តម* ***គង់ វិបុល*** *រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា*
*ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*



*លោក* **Casey Barnett**
*ប្រធានសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជា*



*លោក* **Jost Kadel** *ប្រធានកិច្ចសហប្រតិបត្តិការ*
*អភិវឌ្ឍន៍នៃស្ថានទូតអាល្លឺម៉ង់ប្រចាំព្រះរាជាណាចក្រកម្ពុជា*



# សិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "សៀវភៅណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ" និង "សៀវភៅណែនាំស្ដីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ"



នាព្រឹកថ្ងៃអង្គារ ទី២៣ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា មានការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី **"សៀវភៅណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ"** និង **"សៀវភៅណែនាំស្ដីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ"** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គន់ ទិមុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ វត្តមានជាកិត្តិយសរបស់ ឯកឧត្តម Cherdkiat Atthakor ឯកអគ្គរាជទូតថៃប្រចាំព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម Shaharuddin Onn ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា អ្នកឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា ថ្នាក់ដឹកនាំនិងតំណាងស្ថានទូតម៉ាឡេស៊ី ថៃ វៀតណាម សហគមន៍អឺរ៉ុប អាល្លឺម៉ង់ បារាំង ជប៉ុន ហ្វីលីពីន និងព្រុយណេ ឯកឧត្តម-លោកជំទាវ-លោកអគ្គនាយករង ថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានពីតំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និយ័តករគណនេយ្យនិងសវនកម្ម និយ័តករមូលបត្រកម្ពុជា ជាពិសេសការចូលរួមរបស់អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក លោកស្រី និងនាងកញ្ញាតំណាងវិស័យឯកជន ដែលមានជាអាទិ៍ សម្ព័ន្ធសមាគមសហគ្រាសធុនតូចនិងមធ្យមកម្ពុជា (FASMEC) សមាគមស្បែកជើងកម្ពុជា សភាពាណិជ្ជកម្មម៉ាឡេស៊ីនៅកម្ពុជា សមាគមទេសចរណ៍កម្ពុជា សមាគមធនាគារនៅកម្ពុជា សមាគមភស្តុភារកម្មកម្ពុជា សមាគមពាណិជ្ជកម្មហុងកុងនៅកម្ពុជា សមាគមពាណិជ្ជកម្មថៃប្រចាំប្រទេសកម្ពុជា និងការិយាល័យតំណាងសម្ព័ន្ធឧស្សាហកម្មកៅស៊ូវៀតណាមប្រចាំកម្ពុជា ក៏ដូចជាអភិបាល តំណាងសហគ្រាសភ្នាក់ងារសេវាកម្មពន្ធដារ ចូលរួមផ្ទាល់ប្រមាណជាង **៨៥០ រូប** និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីពន្ធដារ ចូលរួមតាមប្រព័ន្ធអនឡាញ (Zoom Meeting) ប្រមាណជាង **៥៥២ រូប**។

ជាកិច្ចចាប់ផ្ដើម អ្នកឧកញ៉ា **គិត ម៉េង** ប្រធានសភាពាណិជ្ជកម្មកម្ពុជា បានផ្ដល់កិត្តិយសសម្ដែងនូវចំណាប់អារម្មណ៍ចំពោះសិក្ខាសាលានាថ្ងៃនេះ គឺជាការបោះជំហាននៃប្រព័ន្ធពន្ធដារកម្ពុជា និងក្នុងនាមវិស័យឯកជននិងសភាពាណិជ្ជកម្ម

កម្ពុជា សូមចូលរួមអបអរសាទរចំពោះលទ្ធផលជារូបរាងនៃ SOP នេះ គឺជាការផ្ញើសារទៅអន្តរជាតិថាប្រព័ន្ធពន្ធដារកម្ពុជាកាន់តែបើកចំហផ្តល់នូវ "**ការព្យាករ និងតម្លាភាពនៃពន្ធ** (Predictability and Transparency of Tax)"។

ជាកិច្ចបន្ទាប់ ឯកឧត្តម **គង់ ទិបុល** បានថ្លែងសុន្ទរកថាបើកសិក្ខាសាលានិងថ្លែងអំណរគុណ ចំពោះវត្តមានដ៏ច្រើនកុះកររបស់ឯកឧត្តមឯកអគ្គរាជទូត អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោក លោកស្រី និងនាងកញ្ញា បានឆ្លុះបញ្ចាំងយ៉ាងប្រត្យក្សអំពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការឈ្វេងយល់ និងចូលរួមបំពេញ កាតព្វកិច្ចសារពើពន្ធ ក្នុងគោលដៅពង្រឹងអនុលោមភាពសារពើពន្ធ ជាពិសេសតាមរយៈអនុលោមភាពសារពើពន្ធ ដោយស្ម័គ្រចិត្ត (Voluntary Compliance)។ ជាគោលការណ៍ចម្បងអគ្គនាយកដ្ឋានពន្ធដារបាននិងបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹងនិងសម្រួលពាណិជ្ជកម្ម និងការវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ ជាពិសេសគោលនយោបាយពន្ធដារបានសម្រួលនិងលើកកម្ពស់បន្ថែមទៀតនូវបរិយាកាសធុរកិច្ចជូនដល់វិនិយោគិនក្នុងស្រុក សំដៅសម្រួលដល់ការវិនិយោគនិងការប្រកបអាជីវកម្មឱ្យកាន់តែមានភាពងាយស្រួលនិងទទួលបានប្រាក់ចំណេញ និងឈានទៅបន្តទាក់ទាញបន្ថែមទៀត នូវវិនិយោគិនបរទេសឱ្យចូលមកប្រទេសកម្ពុជា។

**ខ្លឹមសារសំខាន់ៗនៃសុន្ទរកថាគន្លឹះរបស់ឯកឧត្តម គង់ ទិបុល**

- ការរៀបចំនូវសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ (SOP on Auditing) និងគឺជាការបើកទំព័រថ្មីមួយនៃការពង្រឹងអភិបាលកិច្ចល្អ របស់អគ្គនាយកដ្ឋានពន្ធដារ ពោលគឺការកែទម្រង់ផ្នែកសារពើពន្ធដ៏មុតស្រួចនេះគឺអនុលោមតាមគោលការណ៍នៃការពង្រឹងអភិបាលកិច្ច
- ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំ និងផ្សព្វផ្សាយនូវសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ (SOP on Auditing) និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ (SOP on Investigation) ដែលសៀវភៅ SOP ទាំងពីរនេះគឺជាឯកសារដ៏សំខាន់ និងជាជំនួយសម្រាប់អ្នកជាប់ពន្ធក្នុងការធ្វើអាជីវកម្មនិងបំពេញកាតព្វកិច្ចសារពើពន្ធ។ សមិទ្ធផលនេះ គឺជាសមិទ្ធផលបន្ថែមលើ SOP ចំនួន ៤៤ ដែលអគ្គនាយកដ្ឋានពន្ធដារបានចងក្រងរៀបចំក្នុងការប្រតិបត្តិការងារសម្រាប់អង្គភាពក្រោមឱវាទទាំងឡាយ ហើយបាននិងកំពុងបន្តធ្វើបច្ចុប្បន្នភាព
- តាមរយៈសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ ជាទូទៅការធ្វើសវនកម្មពន្ធដារត្រូវធ្វើឡើងតែម្តងគត់ក្នុងវង្វង់ ៣ ឆ្នាំ ប៉ុន្តែអ្នកជាប់ពន្ធអាចស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារឱ្យ ធ្វើសវនកម្មមុនកាលកំណត់បាន
- អគ្គនាយកដ្ឋានពន្ធដារនឹងចុះធ្វើសវនកម្មក្នុងវង្វង់ ៣ ឆ្នាំម្តង ប៉ុន្តែប្រសិនបើរកឃើញថាសហគ្រាសមានហានិភ័យ ឬភាពមិនប្រក្រតី រដ្ឋបាលសារពើពន្ធអាចចុះធ្វើសវនកម្មពន្ធដារលើសហគ្រាសនោះ ក្នុងពេលណាមួយក៏បាន
- អគ្គនាយកដ្ឋានពន្ធដារបានអំពាវនាវដល់សហគ្រាសទាំងអស់ឱ្យយកចិត្តទុកដាក់ក្នុងការពង្រឹងអនុលោមភាព និងបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួនឱ្យបានត្រឹមត្រូវដើម្បីចៀសវាងនិងកាត់បន្ថយនូវបន្ទុកទណ្ឌកម្មរដ្ឋបាល ដែលអាចនឹងគរទុករយៈពេលយូរ
- អគ្គនាយកដ្ឋានពន្ធដារបានថ្លែងអំណរគុណដល់វិស័យឯកជន ដែលបានដើរតួជាដៃគូសហការដ៏សំខាន់របស់រាជរដ្ឋាភិបាលនាពេលកន្លងមក
- ឯកឧត្តម **គង់ ទិបុល** បានឆ្លៀតឱកាសគូសរំលេចជូនអង្គសិក្ខាសាលាពីដំណើរកែទម្រង់នាពេលកន្លងមករបស់អគ្គនាយកដ្ឋានពន្ធដារ និងបានថ្លែងអំណរគុណជូនវិស័យឯកជនចំពោះការយល់ដឹងពីគោលបំណងនិងចូលរួមជាមួយរដ្ឋបាលសារពើពន្ធក្នុងការអនុវត្តការងារកែទម្រង់ប្រកបដោយជោគជ័យនាពេលកន្លងមក
- ស្នើឱ្យអ្នកជាប់ពន្ធទាំងអស់ប្រើប្រាស់កម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ (GDT Check and Track) ដោយហេតុ

ថា រាល់លិខិតបញ្ជាបេសកកម្មរបស់រដ្ឋបាលសារពើពន្ធមាន QR Code ច្បាស់លាស់ ដូច្នេះអ្នកជាប់ពន្ធអាចប្រើប្រាស់កម្មវិធីនេះ ដើម្បីស្កេនពិនិត្យពីភាពត្រឹមត្រូវនៃលិខិតបញ្ជាបេសកកម្មទាំងនោះ

- បញ្ហានៃការគេចវេះពន្ធដែលមានជាច្រើនរូបភាពគឺជាបញ្ហាប្រឈមជាសកលរបស់គ្រប់រដ្ឋបាលសារពើពន្ធទាំងអស់ ក៏ដូចរដ្ឋបាលសារពើពន្ធទូទាំងសកលលោក អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងខិតខំកែទម្រង់និងទទួលពង្រឹងសមត្ថភាពរបស់ខ្លួនដោយទទួលបានលទ្ធផលជាវិជ្ជមាន ក្នុងការទប់ស្កាត់និងលុបបំបាត់ការគេចវេះពន្ធ ដែលមានកិច្ចសហការជាមួយ រដ្ឋបាលសារពើពន្ធនិងដៃគូសហការនានា (ដូចជា IMF, OTA, World Bank, JICA, OECD, Swedish Tax Agency ជាដើម)
- ខណៈដែលការគេចវេះពន្ធធ្លាប់ចោទជាបញ្ហាខ្លាំងកាលពីអតីតកាល បច្ចុប្បន្នការកែទម្រង់ស៊ីជម្រៅរបស់អគ្គ-នាយកដ្ឋានពន្ធដារ បានផ្តល់ផលជាវិជ្ជមានក្នុងការកាត់បន្ថយជាអតិបរមានូវបញ្ហានេះ និងបានលើកកម្ពស់នូវអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធធៀបនឹងរយៈពេលកន្លងមកមុនការកែទម្រង់
- គ្មានស្ថាប័នពន្ធដារនៅលើសកលលោកណា ដែលតែងតែពិគ្រោះយោបល់ យកចិត្តទុកដាក់ស្តាប់ និងទទួលយកធាតុចូល យ៉ាងសស្រាក់សស្រាំពីវិស័យឯកជនក្នុងការរៀបចំច្បាប់បទប្បញ្ញត្តិនានាដូចពន្ធដារកម្ពុជាទេ
- ពន្ធដារមិនអាចរីករាយទេ នៅពេលឃើញសហគ្រាសរកស៊ីខាត
- សិក្ខាសាលានាថ្ងៃនេះ គឺជាផ្នែកមួយនៃការពង្រឹងការផ្សព្វផ្សាយនិងលើកកម្ពស់វប្បធម៌បង់ពន្ធ តាមរយៈការរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាល ដោយគិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលសរុបចំនួន **៤០០ លើក** មានសិក្ខាកាមចូលរួមចំនួន **៥៦ ១៧៣ រូប** និងបានផ្តល់សេវាពិគ្រោះយោបល់តាមគ្រប់មធ្យោបាយសរុបចំនួន **៥១ ៩៥០ ករណី**
- អគ្គនាយកដ្ឋានពន្ធដារ បានយកចិត្តទុកដាក់ក្នុងការបន្តធ្វើឱ្យប្រសើរឡើងជាបន្តបន្ទាប់នូវការផ្តល់សេវាអ្នកជាប់ពន្ធដើម្បី លើកកម្ពស់វប្បធម៌បង់ពន្ធ និងពង្រឹងអនុលោមភាពសារពើពន្ធ ដែលនឹងធានាបាននូវចីរភាពចំណូលសម្រាប់ជាប្រយោជន៍នៃថវិកាជាតិ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល
- លើកទឹកចិត្តដល់គ្រប់សហគ្រាស អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ ចូលរួមពង្រឹងអនុលោមភាពសារពើពន្ធ ជាពិសេសអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត (Voluntary Compliance)
- អគ្គនាយកដ្ឋានពន្ធដារមានយន្តការសវនកម្មដែលជាម៉ែត្រវាស់នូវកម្រិតអនុលោមភាពសារពើពន្ធ ហើយបន្ថែមពីលើនេះ មន្ត្រីពន្ធដារមានតួនាទីត្រូវបំពេញការងារក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ ដែលកំណត់ដោយច្បាប់
- អគ្គនាយកដ្ឋានពន្ធដារបានជំរុញ និងលើកទឹកចិត្តឱ្យសហគ្រាសអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការតវ៉ាស្របតាមច្បាប់និងលិខិតបទដ្ឋានជាធរមាន ដោយផ្តល់នូវទឡ្ហីករណ៍ច្បាស់លាស់ក្នុងការដោះស្រាយ
- អគ្គនាយកដ្ឋានពន្ធដារបានណែនាំដល់សវនករពន្ធដារទាំងអស់ឱ្យអនុវត្តការងារស្របតាមក្រមសីលធម៌វិន័យនិងវិជ្ជាជីវៈ ដូចមានកំណត់ក្នុងឯកសារសៀវភៅណែនាំ (SOP) ទាំងពីរ
- ជំរុញឱ្យភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ពង្រឹងការផ្តល់សេវារបស់ខ្លួន ចៀសវាងការប្រកាសបង់ពន្ធជូនអ្នកជាប់ពន្ធខុស ឬយឺតយ៉ាវ ឬមានចន្លោះប្រហោងណាមួយជាយថាហេតុ និងដាច់ខាតត្រូវចៀសឱ្យផុតពីការពាក់ព័ន្ធនឹងអំពើគេចវេះពន្ធ
- អំពាវនាវដល់អ្នកជាប់ពន្ធចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយតាមរយៈការប្រកាសនិងបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ព្រមទាំងចូលរួមរាយការណ៍នូវរាល់ករណីអសកម្ម ឬការគំរាមកំហែងពីសំណាក់មន្ត្រីពន្ធដារ។

ក្នុងឱកាសនេះ ផងដែរ ក៏មានវេទិកាសំណួរ-ចម្លើយ ដែលមានវត្តមានរបស់ឯកឧត្តម **គង់ វិបុល**, លោកជំទាវ **ប៊ុន នារី** ឯកឧត្តម **លឹម ហ៊ុយជីវ** លោក **ស្រ៊ុន អង្គរ៉េន** លោក **ជួរ សៃ** លោក Edwin Vanderbruggen (Partner

VDB Loi) និងលោកស្រី **Vijirawan Chamnan** (Tax Partner DFDL) ដោយមានឧកញ៉ា **Tan Khee Meng** (ប្រធានសភាពាណិជ្ជកម្មម៉ាឡេស៊ីនៅកម្ពុជា MBCC) ជាអ្នកសម្របសម្រួល។ វេទិកានេះបានផ្តល់ឱកាសដល់អ្នកចូលរួមទាំងអស់លើកឡើងជាសំណួរនិងទទួលបានចម្លើយយ៉ាងក្បោះក្បាយ និងបានចូលរួមអបអរសាទរ ចំពោះ SOP ដែលដាក់ចេញឱ្យអនុវត្តនេះ ហើយបន្ថែមពីនេះទៀត ឯកឧត្តម **គង់ វិបុល** ក៏បានទទួលយកនូវការស្នើសុំនានាពីវិស័យឯកជនពាក់ព័ន្ធនឹងពន្ធដារមកពិចារណា ជាពិសេសការស្នើសុំពាក់ព័ន្ធនឹងការជំរុញ និងធ្វើឱ្យប្រសើរឡើងសម្រាប់វិស័យទេសចរណ៍ក្នុងខេត្តសៀមរាបផងដែរ៕






អ្នកឧកញ៉ា ***គិត ម៉េង***, *ឯកឧត្តម* ***គង់ វិបុល***, *ឯកឧត្តម* **Cherdkiat Atthakor** *និងឯកឧត្តម* **Shaharuddin Onn** (*រូបពីឆ្វេងទៅស្តាំ*)



# ផ្នែកទី១
# ស្ថានភាពនៃការគ្រប់គ្រងការប្រមូលចំណូលពន្ធ

១. លទ្ធផលការងារប្រមូលចំណូលពន្ធ
២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ
៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ
៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

# ๒

# ១. លទ្ធផលការងារប្រមូលចំណូលពន្ធ

សរុបរយៈពេល ៩ខែដើមឆ្នាំ២០២៤ ចំណូលពន្ធអាករ ដែលប្រមូលបានជាក់ស្ដែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **១០ ៦៨៩,១៨ ប៊ីលានរៀល** (ប្រមាណជា **២ ៦៣៩,៣០ លានដុល្លារ**) ស្មើនឹង **៦៣,៣៨%** នៃផែនការដែលបានកំណត់ក្នុងច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។

**ចំណូលពន្ធអាករគ្រប់ប្រភេទ រយៈពេល ៩ខែដើមឆ្នាំ២០២៤**




# ២. ស្ថានភាពចំណូលពន្ធតាមប្រភេទអ្នកជាប់ពន្ធ

**ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ រយៈពេល ៩ខែដើមឆ្នាំ២០២៤**



សរុបរយៈពេល ៩ខែដើមឆ្នាំ២០២៤ ចំណូលពន្ធអាករតាមប្រភេទអ្នកជាប់ពន្ធ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានក្នុងនោះរួមមាន៖

- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធធំ ចំនួន ៨ ១០២,៦៦ **ប៊ីលានរៀល** ស្មើនឹង **៧៥,៨០%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធមធ្យម ចំនួន **១ ៧៧២,៦១ ប៊ីលានរៀល** ស្មើនឹង **១៦,៥៨%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីអ្នកជាប់ពន្ធតូច ចំនួន **៧៣,១៥ ប៊ីលានរៀល** ស្មើនឹង **០,៦៨%** ធៀបនឹងចំណូលពន្ធអាករសរុប
- ចំណូលពន្ធអាករពីប្រភេទពន្ធផ្សេងៗ (ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ ពន្ធលើអចលនទ្រព្យ និងពន្ធផ្សេងៗ) ចំនួន **៧៤០,៧៥ ប៊ីលានរៀល** ស្មើនឹង **៦,៩៣%** ធៀបនឹងចំណូលពន្ធអាករសរុប៕

## ៣. ស្ថានភាពចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗ

**ចំណូលពន្ធអាករតាមប្រភេទពន្ធសំខាន់ៗ រយៈពេល ៩ខែដើមឆ្នាំ២០២៤**




សរុបរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលតាមប្រភេទពន្ធសំខាន់ៗរួមមាន៖

- ពន្ធលើប្រាក់ចំណូលចំនួន **៣ ២៣២,០៣ ប៊ីលានរៀល**
- អាករលើតម្លៃបន្ថែមចំនួន **២ ៥៥២,៨៥ ប៊ីលានរៀល**
- អាករពិសេសចំនួន **៧២៨,៧៩ ប៊ីលានរៀល**
- ពន្ធលើប្រាក់បៀវត្សចំនួន **១ ០៧៩,៥ ប៊ីលានរៀល**
- ពន្ធប្រថាប់ត្រាសរុប (ផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ) ចំនួន **៤៩៦,៨៨ ប៊ីលានរៀល**
- ពន្ធកាត់ទុកទូទៅចំនួន **២ ០៦៨,៦៦ ប៊ីលានរៀល**
- ផ្សេងៗចំនួន **៥៣០,៤៩ ប៊ីលានរៀល**៕

# ៤. ស្ថានភាពចំណូលពន្ធតាមសកម្មភាពអាជីវកម្មសំខាន់ៗ

ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ ចំណូលពន្ធពីសកម្មភាពកម្មន្តសាល សកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រង និងអាហារដ្ឋាន-នីហារណ៍ គឺជាចំណូលពន្ធចម្បង និងលេចធ្លោជាងគេ។ ជាក់ស្តែង ចំណូលពន្ធអាករពីចំណូលពន្ធពីសកម្មភាពកម្មន្តសាលមានចំនួន **២ ៣៩៩,៥៣ ប៊ីលានរៀល**, សកម្មភាពសេវាហិរញ្ញវត្ថុនិងធានារ៉ាប់រងមានចំនួន **២ ២៥៣,៣៤ ប៊ីលានរៀល** និងចំណូលពន្ធអាករពីសកម្មភាពនីហារណ៍-អាហារណ៍មានចំនួន **១ ៦១១,៧១ ប៊ីលានរៀល**។ ទន្ទឹមនឹងនេះ ចំណូលពន្ធពីសកម្មភាពដែលកើនឡើងគួរឱ្យកត់សម្គាល់សម្រាប់ ៩ខែដើមឆ្នាំ២០២៤ គឺចំណូលពន្ធអាករបានមកពីសកម្មភាពកម្មន្តសាល បើធៀបនឹងរយៈពេលនិងសកម្មភាពដូចគ្នានៃឆ្នាំ២០២៣ កើនឡើងចំនួន **១៥៦,៧៨ ប៊ីលានរៀល** ស្មើនឹង **៦,៩៩ %**។ តារាងចំណូលពន្ធអាករ តាមសកម្មភាពអាជីវកម្មសំខាន់ៗដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ មានបង្ហាញដូចខាងក្រោម៖

**តារាងចំណូលពន្ធអាករតាមសកម្មភាពអាជីវកម្មសំខាន់ៗ រយៈពេល ៩ខែដើមឆ្នាំ២០២៤**

(តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញ Online របស់អគ្គនាយកដ្ឋានពន្ធដារ)

| បរិយាយ | ខែកក្កដា | ខែសីហា | ខែកញ្ញា | សរុបរួម |
|---|---|---|---|---|
| អាហារណ៍-នីហារណ៍ (រួមបញ្ចូលការលក់ផលិតផលគេលសិលា) | ១៦០,៨៣ | ១៥១,៥៣ | ១៤៩,៤៣ | ១ ៦១១,៧១ |
| សេវាហិរញ្ញវត្ថុ និងធានារ៉ាប់រង | ១៦០,៣០ | ១៥៨,០៨ | ១៥០,៧៥ | ២ ២៥៣,៣៤ |
| កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១០,៨៥ | ៨,២១ | ៨,៦៩ | ៩៩,៧៤ |
| ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ | ៦,៨៧ | ៥,៤៤ | ៦,៨៤ | ១៥៣,១១ |
| កម្មន្តសាល | ២២១,២៨ | ២០៧,១១ | ២១១,៩៨ | ២ ៣៩៩,៥៣ |
| សកម្មភាពអចលនវត្ថុ | ៤៨,៣៨ | ៤៣,០១ | ៤១,៧២ | ៥០៨,៤៥ |
| ការដឹកជញ្ជូន និងការស្តុកទុក | ៥៤,៥១ | ៥៦,៩៥ | ៥៥,៤៥ | ៥៦៣,៧៨ |
| ព័ត៌មានវិទ្យា និងទូរគមនាគមន៍ | ៤១,៨២ | ៦៦,៥១ | ៥៨,០០ | ៦៨៥,៩២ |
| ការអប់រំ | ១១,៨១ | ៧,១៨ | ៩,១៣ | ៧៩,២៣ |
| សេវាកម្មស្នាក់នៅ និងអាហារ | ២៤,៤៩ | ២៥,១៤ | ២៥,១៨ | ២៦៧,០៣ |
| ការសាងសង់ | ៥០,១៨ | ៥៥,១៨ | ៥១,៨០ | ៥២០,៤៤ |

* សម្គាល់ ៖ ចំណូលឯកតាគិតជាប៊ីលានរៀល។

# ផ្នែកទី២
# វឌ្ឍនភាពការងារនៃមុខងារប្រតិបត្តិការស្នូល និងមុខងារគាំទ្រ

១. ការចុះបញ្ជីពន្ធដារ

២. ការផ្តល់សេវាអ្នកជាប់ពន្ធ

៣. ការចាត់ចែងលិខិតប្រកាសពន្ធ

៤. ការធ្វើសវនកម្មពន្ធដារ

៥. ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា

៦. បច្ចេកវិទ្យាព័ត៌មាន

## ១.ការចុះបញ្ជីពន្ធដារ

ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានអនុញ្ញាតឱ្យចុះបញ្ជីសរុបចំនួន **៧ ៩៥៣ សហគ្រាស** (ពន្ធធំ ៤៩៥ ពន្ធមធ្យម ៣ ៧១៣ និងពន្ធតូច ៣ ៧៤៥) ក្នុងនោះតាមថ្នាលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានចំនួន **៧ ៣៨៣** សហគ្រាស (ពន្ធធំ ៤៥៩ ពន្ធមធ្យម ៣ ៤៥១ និងពន្ធតូច ៣ ៤៧៣)។ ដោយឡែក ចំពោះប្រតិបត្តិការពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក មានអ្នកជាប់ពន្ធដែលបានមកចុះបញ្ជីគិតចាប់ពីឆ្នាំ២០២២ ដល់ខែកញ្ញា ឆ្នាំ២០២៤ សរុបចំនួន **៩៥ សហគ្រាស**៕

## ២.ការផ្តល់សេវាអ្នកជាប់ពន្ធ

### មជ្ឈមណ្ឌលពិគ្រោះយោបល់

ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាអ្នកជាប់ពន្ធសរុបចំនួន **៧៥ ៧៩៦ ករណី** បើធៀបនឹងរយៈពេលដូចគ្នា ឆ្នាំ២០២៣ ឃើញថាថយចុះ **-១០ ២៤០ ករណី** ស្មើនឹង **-១១,៩០%** ក្នុងនោះ មានការថយចុះគ្រប់ករណីនៃការផ្តល់សេវា។ ការថយចុះនៃការសាកសួរសំណួរតាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធ គឺឆ្លុះបញ្ចាំងអំពីការយល់ដឹងរបស់អ្នកជាប់ពន្ធមានការកើនឡើង៕

**ការផ្តល់សេវាពិគ្រោះយោបល់ រយៈពេល ៩ខែដើមឆ្នាំ២០២៣និងឆ្នាំ២០២៤**

| បរិយាយ | ៩ខែដើមឆ្នាំ២០២៣ | ៩ខែដើមឆ្នាំ២០២៤ | %ថយ |
|---|---|---|---|
| ទូរស័ព្ទ (១២៧៧) | ៥២ ៣១០ | ៤៨ ៨៨៣ | -៦,៥៥% |
| GDT Live Chat | ២៥ ០៨៤ | ២២ ៤០៦ | -១០,៦៨% |
| បណ្តាញសង្គម Facebook | ៦ ៧១៨ | ៣ ៣៧៧ | -៤៩,៧៣% |
| កម្មវិធី "ពន្ធដារកម្ពុជា" | ៣៩ | ៣៥ | -១០,២៦% |
| កម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ" | ៣៦ | ២៨ | -២២,២២% |
| តេឡេក្រាម "ព័ត៌មានពន្ធដារកម្ពុជា" | ១ ៨៤៩ | ១ ០៦៧ | -៤២,២៩% |
| **សរុបរួម** | ៨៦ ០៣៦ | ៧៥ ៧៩៦ | -១១,៩០% |

### ការផ្តល់សេវាអ្នកជាប់ពន្ធចំពោះ "ការគាំទ្រប្រព័ន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ (e-Tax Service)"

ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានផ្តល់សេវាដោះស្រាយបញ្ហាប្រឈមនានា ក្នុងការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីតាមរយៈអនឡាញ (e-Tax Service) សរុបចំនួន **២៤ ៨៧៣ ដង** ដែលក្នុងនោះការស្នើសុំតាមរយៈ GDT Live Chat ចំនួន **៩ ៨៤០ ដង**, សារអេឡិចត្រូនិក (E-Mail) ចំនួន **៤០២ ករណី**, ទូរស័ព្ទ (១២៧៧) ចំនួន **១០ ១៥៩ ដង**, ហ្វេសប៊ុកចំនួន **៦ ដង** និងក្រុមតេឡេក្រាម (Telegram) ចំនួន **៤ ៤៦៦ ដង**៕

# កម្មវិធីពន្ធដារកម្ពុជា

កម្មវិធីពន្ធដារកម្ពុជា គឺជាកម្មវិធីដែលអគ្គនាយកដ្ឋានពន្ធដារបានរៀបចំឡើងដើម្បីចែករំលែកចំណេះដឹង ព័ត៌មានទាក់ទងនឹងពន្ធដារ ជាពិសេសផ្តល់ឱកាសឱ្យសាធារណជនចូលរួមមតិយោបល់ ឬលើកឡើងនូវចម្ងល់នានាពាក់ព័ន្ធនឹងប្រធានបទនីមួយៗ ដែលធ្វើការផ្សាយផ្ទាល់តាមរយៈទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ រៀងរាល់ថ្ងៃព្រហស្បតិ៍ វេលាម៉ោង ១១:០០ ដល់ម៉ោង ១២:០០ថ្ងៃត្រង់។ កម្មវិធីនេះ ទទួលបានការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកជាប់ពន្ធ និងសាធារណជន ដែលទស្សនិកជនអាចផ្តល់មតិយោបល់ ឬសួរសំណួរតាមរយៈទូរស័ព្ទមកលេខ ១២៧៧ ដោយឥតគិតថ្លៃ ឬអាចចូលទៅផ្តល់មតិយោបល់ (Comment) នៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារភ្លាមៗក្នុងពេលផ្សាយផ្ទាល់ នោះវាគ្មិននឹងធ្វើការឆ្លើយតបផ្ទាល់ក្នុងកម្មវិធីតែម្តង។ ក្នុងករណីខកខានមិនបានទស្សនាការផ្សាយផ្ទាល់ ទស្សនិកជនក៏អាចទស្សនាឡើងវិញ ព្រមទាំងអាចសួរសំណួរតាមរយៈ Comments ក្នុងវីដេអូនោះ ក្រុមការងារ GDT Call Center របស់អគ្គនាយកដ្ឋានពន្ធដារ នឹងធ្វើការឆ្លើយតបជូនតាមលំដាប់លំដោយ។ ក្រៅពីការចូលទៅទស្សនាឡើងវិញនៅលើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ ទស្សនិកជនក៏អាចចូលទៅទស្សនាក្នុងបណ្តាញយូធូប (YouTube) "General Department of Taxation, Cambodia" របស់អគ្គនាយកដ្ឋានពន្ធដារផងដែរ។

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីពន្ធដារកម្ពុជាសរុបចំនួន **១៣ លើក** ដោយផ្តោតលើប្រធានបទសំខាន់ៗរួមមាន ១.ភ្នាក់ងារសេវាកម្មពន្ធដារ ២.កម្មវិធីទូរស័ព្ទដៃរបស់អគ្គនាយកដ្ឋានពន្ធដារ (GDT Apps) ៣.ការស្នើសុំអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀង DTA និងវិញ្ញាបនបត្រនិវាសនជន ៤.នីតិវិធីនៃការដាក់ពាក្យបណ្តឹងតវ៉ាលើការកំណត់ពន្ធឡើងវិញ ៥.ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌបទប្បញ្ញត្តិស្តីពីពន្ធដារ ៦.នីតិវិធីនៃការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម ៧.ពន្ធកាត់ទុកទូទៅ ៨.សេវាអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ៩.កាតព្វកិច្ចសារពើពន្ធនិងការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាសវិនិយោគ ១០.ពន្ធលើអចលនទ្រព្យ ១១.ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យនិងអាករលើការស្នាក់នៅ ១២.អាករពិសេស និងអាករសម្រាប់បំភ្លឺសាធារណៈ និង១៣.កាតព្វកិច្ចពន្ធ ចំពោះភតិសន្យាហិរញ្ញវត្ថុ៕



## កម្មវិធីពន្ធដារកម្ពុជាស្ដីពី "ផ្លាក់ខារសេវាកម្មពន្ធដារ"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានកញ្ញា **ម៉ែន ម៉ានី** នាយករងសាលាជាតិពន្ធដារ និងលោក **ឆាយ មុណា** ប្រធានការិយាល័យនៃសាលាជាតិពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៦៩ អ្នកចូលទស្សនាចំនួន ៥៥ ០០០ ដង និងមានការចែករំលែកបន្ត ចំនួន ២២៥ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី "កម្មវិធីទូរស័ព្ទដៃរបស់អគ្គនាយកដ្ឋានពន្ធដារ (GDT Apps)"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **សុត្រ សារេត** អនុប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គនាយកដ្ឋានពន្ធដារ និងលោក **ផន វណ្ណៈ** មន្ត្រីនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣៥ អ្នកចូលទស្សនាចំនួន ៤២ ៤០០ ដង និងមានការចែករំលែកបន្តចំនួន ២២៩ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី "ការស្នើសុំអត្ថប្រយោជន៍នៃកិច្ចព្រមព្រៀង DTA និងវិញ្ញាបនបត្រនិវាសនជន"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **សេង ពិសិដ្ឋ** ប្រធានការិយាល័យនៃនាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និងលោក **ស៊ាន សុខពៅ** អនុប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៤៩ អ្នកចូលទស្សនាចំនួន ២៧ ២០០ ដង និងមានការចែករំលែកបន្តចំនួន ១៧៩ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "នីតិវិធីនៃការដាក់ពាក្យបណ្តឹងតវ៉ាលើការកំណត់ពន្ធឡើងវិញ"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោកស្រី **យុង សោភា** អនុប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ និងលោក **គឹម គន្ធថាវន្តរី** ប្រធានការិយាល័យនៃនាយកដ្ឋាន នីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៣៩ អ្នកចូលទស្សនាចំនួន ២៥ ៧០០ ដង និងមានការចែករំលែកបន្ត ចំនួន ១៣៨ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **គង់ សុខហេង** និងលោក **ជួន វ៉ាន់ឌី** អនុប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ១៩ អ្នកចូលទស្សនា ចំនួន ២៨ ៤០០ ដង និងមានការចែករំលែកបន្តចំនួន ១៧៦ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "នីតិវិធីនៃការស្នើសុំបង្វិលសងអាករលើតម្លៃបន្ថែម"



ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ឯក ពិសិដ្ឋ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ម៉ៅ ឆិន** អនុប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់ អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៦៩ អ្នកចូលទស្សនា ចំនួន ៣៧ ៥០០ ដង និងមានការចែករំលែកបន្ត ចំនួន ២៥៨ ដង៕

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ពន្ធកាត់ទុកទូទៅ"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **សុខ កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **កុល ម៉ារ៉ាដុល្លារ** ប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុកមានមតិយោបល់ (Comments) ចំនួន ៣៨ អ្នកចូលទស្សនាចំនួន ២៨ ០០០ ដង និងមានការចែករំលែកបន្តចំនួន ២៣៩ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "សេវាអ្នកជាប់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារ"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ព្រាប មុណា** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ និងលោកស្រី **សេង ច័ន្ទមុន្នី** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៣២ អ្នកចូលទស្សនាចំនួន ២០ ១០០ ដង និងមានការចែករំលែកបន្ត ចំនួន ១២១ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្តីពី "ភាពពុកិច្ចសារពើពន្ធនិងការលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះសហគ្រាសវិនិយោគ"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **អេង វេតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោកស្រី **សុខ កុសល** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជន ផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៣៩ អ្នកចូលទស្សនាចំនួន ២០ ៤០០ ដង និងមានការចែករំលែកបន្ត ចំនួន ១៣២ ដង។

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “ពន្ធលើអចលនទ្រព្យ”

កម្មវិធីនេះមានលោក **សុវណ្ណ សម្បូណ៌** ប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ និងលោក **ម៉ែន ពេជ្រដារ៉ូ** អនុប្រធានការិយាល័យនៃនាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ២៨ អ្នកចូលទស្សនា ចំនួន ២១ ១០០ ដង និងមានការចែករំលែកបន្តចំនួន ១០៨ ដង៕




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងអាករលើការស្នាក់នៅ”

កម្មវិធីនេះមានលោក **ព្រាប មូណា** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ និងលោក **ម៉ា មូរ៉ា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ២១ អ្នកចូលទស្សនា ចំនួន ១១ ៦០០ ដង និងមានការចែករំលែកបន្តចំនួន ៨២ ដង៕




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី “អាករពិសេស និងអាករសម្រាប់បំភ្លឺសាធារណៈ”

កម្មវិធីនេះមានលោក **ម៉ឹង សុខឡៅ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ប៉ុក មូរក្សី** អនុប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ៣២ អ្នកចូលទស្សនា ចំនួន ១០ ៣០០ ដង និងមានការចែករំលែកបន្តចំនួន ១០២ ដង៕




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

## កម្មវិធីពន្ធដារកម្ពុជាស្ដីពី "កាតព្វកិច្ចពន្ធ ចំពោះកតិសន្យាហិរញ្ញវត្ថុ"




ស្កេន ដើម្បីចូលទៅទស្សនាវីដេអូដើម

កម្មវិធីនេះមានលោក **ឆាយ ជាហេង** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោក **ឯក ពិសិដ្ឋ** ប្រធានការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ ជាវាគ្មិន និងត្រូវបានផ្សាយផ្ទាល់លើទំព័រហ្វេសប៊ុកផ្លូវការ របស់អគ្គនាយកដ្ឋានពន្ធដារ នាព្រឹកថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ ដោយទទួលបានការចូលរួមតាមទូរស័ព្ទផ្ទាល់ពីទស្សនិកជនផងដែរ។ បើគិតមកដល់ដំណាច់ត្រីមាសទី៣ ឆ្នាំ២០២៤ តាមស្ថិតិនៅលើទំព័រហ្វេសប៊ុក មានមតិយោបល់ (Comments) ចំនួន ២៧ អ្នកចូលទស្សនា ចំនួន ១១ ០០០ ដង និងមានការចែករំលែកបន្តចំនួន ១០១ ដង។



# ៣.ការចាត់ចែងលិខិតប្រកាសពន្ធ

អគ្គនាយកដ្ឋានពន្ធដារ បាននិងកំពុងដាក់ឱ្យប្រើប្រាស់កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូចលើទូរស័ព្ទដៃ ឈ្មោះ GDT Tax Prefiling App (មានមុខងារ ១.កត់ត្រាទិន្នន័យទិញ-លក់ ២.ប្រកាសពន្ធប្រចាំខែ-ប្រចាំឆ្នាំ ៣.មើលប្រវត្តិប្រកាសពន្ធ-ប្រវត្តិបង់ប្រាក់ពន្ធ និង៤.ពិនិត្យមើលបំណុលពន្ធរបស់ក្រុមហ៊ុន) ដែលលោកអ្នកអាចចូលទៅទាញយកនៅក្នុង Play Store ឬ App Store។ សម្រាប់អ្នកជាប់ពន្ធមធ្យមនិងធំ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០២២ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធតាមអនឡាញ (e-Filing) និងប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) ដែលមានលក្ខណៈពេញលេញភ្ជាប់ជាមួយនឹងមុខងារទូទាត់ប្រាក់ពន្ធតាមរយៈប្រព័ន្ធអេឡិចត្រូនិក និងប្រព័ន្ធធនាគារ ដើម្បីផ្តល់ភាពងាយស្រួលជូនអ្នកជាប់ពន្ធកាត់បន្ថយពេលវេលា និងដោះស្រាយបញ្ហាប្រឈមក្នុងការបំពេញលិខិតប្រកាសនិងទូទាត់ប្រាក់ពន្ធ។ បន្ថែមពីនេះ នាថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៣ អគ្គនាយកដ្ឋានពន្ធដារ បានចេញសេចក្តីណែនាំលេខ ៤៥៤១៧ អពដ ស្តីពីនីតិវិធីនៃការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែតាមអនឡាញ ក្នុងគោលបំណងផ្តល់ជូនអ្នកជាប់ពន្ធក្នុងការកែតម្រូវលិខិតប្រកាសពន្ធប្រចាំខែកន្លងមក ដែលបានប្រកាសខុសទិន្នន័យដោយផ្អែកលើមូលដ្ឋាន នៃការភាន់ច្រឡំ ឬភ្លាំងភ្លាត់ ឬមានបំណងធ្វើបច្ចុប្បន្នភាពទិន្នន័យ ព្រមទាំងបញ្ចូលមុខងារថ្មី រួមមាន ការភ្ជាប់លិខិតផ្ទេរសិទ្ធិនិងប័ណ្ណសម្គាល់សម្រាប់គណនីប្រើប្រាស់ជាភ្នាក់ងារសេវាកម្មពន្ធដារនិងតំណាងសហគ្រាស ភ្ជាប់របាយការណ៍ហិរញ្ញវត្ថុ និងការកែតម្រូវលិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំដែលបានប្រកាសរួចរាល់៕

***ដើម្បីឈ្វេងយល់កាន់តែច្បាស់អំពីនីតិវិធីក្នុងការដាក់ពាក្យស្នើសុំកែតម្រូវ***
***លិខិតប្រកាសពន្ធប្រចាំខែ សូមលោក លោកស្រីស្កេននូវ QR Code នេះ***



## ៤.ការធ្វើសវនកម្មពន្ធដារ

ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មគ្រប់ប្រភេទលើសហគ្រាសសរុបបាន ចំនួន **៨ ៤៥១ ករណី** មានប្រាក់ពន្ធចំនួន **៤ ០៣៧,៣៦ ប៊ីលានរៀល**។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ ឃើញថាការធ្វើសវនកម្មមានការថយចុះចំនួន **១ ០៦៧ ករណី** ស្មើនឹង **១១,២១%**។

**ចំនួនករណី និងប្រាក់ពន្ធអាករ ដែលបានមកពីការធ្វើសវនកម្ម រយៈពេល ៩ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២៣**

| បរិយាយ | ចំនួនករណី | ប្រាក់ពន្ធអាករ(ប៊ីលានរៀល) |
|---|---|---|
| ឆ្នាំ២០២៤ | ៨ ៤៥១ | ៤ ០៣៧,៣៦ |
| ឆ្នាំ២០២៣ | ៩ ៥១៨ | ១០ ១២៣,៥៤ |

## ៥.ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា

### ការប្រមូលបំណុលពន្ធ

ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ បំណុលពន្ធប្រមូលបានមានចំនួន **៤៧៦,៤៣ ប៊ីលានរៀល** (ប្រមាណជា **១១៧,៦៤ លានដុល្លារ**) បើប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ មានចំនួន **៦៤៦,៣៦ ប៊ីលានរៀល** (ប្រមាណជា **១៥៩,៦ លានដុល្លារ**) ។

**លទ្ធផលប្រមូលបំណុលពន្ធ រយៈពេល ៩ខែដើមឆ្នាំ២០២៤ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣**

ឯកតាគិតជាប៊ីលានរៀល

| បរិយាយ | រយៈពេល៦ខែ | កក្កដា | សីហា | កញ្ញា | សរុបរួម |
|---|---|---|---|---|---|
| ឆ្នាំ២០២៤ | ៣៤៧,៨៥ | ៥៤,២២ | ៣៦,៣៨ | ៣៧,៨៣ | **៤៧៦,៤៣** |
| ឆ្នាំ២០២៣ | ៤៧០,៥៩ | ៥៨,៥៦ | ៦២,៣១ | ៥៤,៩៤ | **៦៤៦,៣៦** |
| %ថយ | -២៤,១៥% | -០,០៧ | -0.៤២% | -០,៣១% | **-0.២៦%** |

*សម្គាល់៖ តួលេខប្រមូលបំណុលពន្ធ "សរុបរួម" មានការកែតម្រូវឡើងវិញ និងកត់ត្រាបន្ថែមនូវតួលេខបំណុលពន្ធទារបានក្នុងខែកក្កដា-កញ្ញា មួយចំនួន ដោយអ្នកជាប់ពន្ធមិនបានយកបង្កាន់ដៃទូទាត់ប្រាក់ពន្ធទៅប្រកាស ដើម្បីកត់ត្រា។

### បណ្តឹងតវ៉ា

ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ា ចំនួន **៦៣៨ ករណី** បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៣ គឺមានការកើនឡើងចំនួន **៣០៧ ករណី**។ ចំនួនទឹកប្រាក់បានបង់ចំពោះបណ្តឹងតវ៉ាដោះស្រាយបាន មានចំនួន **៥ ៣៨៣ ២៥៧ ដុល្លារ**។

# ៦.បច្ចេកវិទ្យាព័ត៌មាន

អគ្គនាយកដ្ឋានពន្ធដារបានបន្តធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងបច្ចេកវិទ្យាព័ត៌មានពន្ធដារ សម្រាប់គាំទ្រដល់ការគ្រប់គ្រងការប្រមូលចំណូលពន្ធ ការផ្តល់សេវាអ្នកជាប់ពន្ធ ចាប់ពីឆ្នាំ២០១៤ ដល់បច្ចុប្បន្នសរុបចំនួន **៨២ ប្រព័ន្ធ-កម្មវិធី** និងគេហទំព័រ៕

**ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន**

| បរិយាយ | ប្រព័ន្ធ | កម្មវិធី | គេហទំព័រ | សរុបរួម |
|---|---|---|---|---|
| ឆ្នាំ២០១៤ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៥ | ០៣ | ០២ | ០០ | ០៥ |
| ឆ្នាំ២០១៦ | ០៣ | ០១ | ០០ | ០៤ |
| ឆ្នាំ២០១៧ | ១០ | ០១ | ០១ | ១២ |
| ឆ្នាំ២០១៨ | ០៤ | ០៤ | ០០ | ០៨ |
| ឆ្នាំ២០១៩ | ០១ | ០០ | ០០ | ០១ |
| ឆ្នាំ២០២០ | ១៣ | ០៤ | ០១ | ១៨ |
| ឆ្នាំ២០២១ | ០៧ | ០២ | ០០ | ០៩ |
| ឆ្នាំ២០២២ | ១១ | ០៣ | ០០ | ១៤ |
| ឆ្នាំ២០២៣ | ០៣ | ០៣ | ០០ | ០៦ |
| ឆ្នាំ២០២៤ | ០១ | ០០ | ០០ | ០១ |
| **សរុបរួម** | ៥៩ | ២១ | ០២ | ៨២ |

## គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ (GDT Website)

អគ្គនាយកដ្ឋានពន្ធដារមានគេហទំព័រផ្លូវការមួយ (www.tax.gov.kh) ដើម្បីផ្សព្វផ្សាយព័ត៌មានថ្មីៗ ទាក់ទងនឹងអ្នកជាប់ពន្ធ សេវាសាធារណៈ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ទំនាក់ទំនងអន្តរជាតិ សេវាកម្មអេឡិចត្រូនិកពន្ធដារ និងកិច្ចការទាំងឡាយរបស់អង្គភាពពន្ធដារ ដែលតែងតែមានអ្នកជាប់ពន្ធចូលទស្សនាជាប្រចាំ។ ជាក់ស្តែងក្នុងខែកញ្ញា ឆ្នាំ២០២៤ មានចំនួនអ្នកចូលទស្សនា **២៤ ៣៧១៧ ដង** និងក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ មានចំនួនអ្នកចូលទស្សនាសរុប **២ ០០០ ៦៥៥ ដង**៕

## ការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ពីឆ្នាំ ២០១៤ ដល់បច្ចុប្បន្ន

### ឆ្នាំ២០១៤

១.កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន
២.ប្រព័ន្ធគ្រប់គ្រងពន្ធមធ្យោបាយដឹកជញ្ជូន
៣.ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីសហគ្រាស
៤.ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស

### ឆ្នាំ២០១៥

៥.កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស
៦.កម្មវិធីប្រតិទិនពន្ធដារ
៧.ប្រព័ន្ធសុវត្ថិភាពច្រកចេញ-ចូល
៨.ប្រព័ន្ធគ្រប់គ្រងពន្ធអចលទ្រព្យ និងប្រថាប់ត្រា
៩.ប្រព័ន្ធគ្រប់គ្រងពាក្យស្នើសុំប្រឡងចូលបម្រើការងារ

### ឆ្នាំ២០១៦

១០.កម្មវិធីអង្កេតសហគ្រាស
១១.ប្រព័ន្ធគ្រប់គ្រងសន្និធិបង្កាន់ដៃទទួលប្រាក់ពន្ធ
១២.ប្រព័ន្ធគ្រប់គ្រងការទទួលប្រាក់ពន្ធ
១៣.ប្រព័ន្ធគ្រប់គ្រងលើការជួលអចលនទ្រព្យ

### ឆ្នាំ២០១៧

១៤.គេហទំព័របញ្ជូនរបាយការណ៍ព័ត៌មាន(FATCA)
១៥.ប្រព័ន្ធត្រួតពិនិត្យពន្ធមធ្យោបាយតាមRFID
១៦.ប្រព័ន្ធគ្រប់គ្រងកម្មវិធីប្រជុំរបស់អពជ
១៧.ប្រព័ន្ធគ្រប់គ្រងបំណុលពន្ធ
១៨.ប្រព័ន្ធគ្រប់គ្រងគណនីរបស់មន្ត្រីនិងដៃគូសហការ
១៩.ប្រព័ន្ធរក្សាទុកនិងចែកចាយឯកសារផ្ទៃក្នុង
២០.ប្រព័ន្ធគ្រប់គ្រងអ៊ីម៉ែលរបស់អពជ
២១.ប្រព័ន្ធគ្រប់គ្រងសន្លឹកតែមប្រើបារី
២២.ប្រព័ន្ធគ្រប់គ្រងសវនកម្មសហគ្រាស
២៣.ប្រព័ន្ធគ្រប់គ្រងមជ្ឈមណ្ឌលពិគ្រោះយោបល់
២៤.ប្រព័ន្ធគ្រប់គ្រងការបង់ពន្ធតាមអនឡាញ
២៥.កម្មវិធីត្រួតពិនិត្យតែមប្រើបារី

### ឆ្នាំ២០១៨

២៦.ប្រព័ន្ធគ្រប់គ្រងព័ត៌មានសហគ្រាស
២៧.ប្រព័ន្ធគ្រប់គ្រងព័ត៌មានបុគ្គល
២៨.ប្រព័ន្ធគ្រប់គ្រងតាមដានឯកសារ
២៩.ប្រព័ន្ធតាមដានចំណូលពន្ធដារ
៣០.កម្មវិធីព័ត៌មានស្តីពីពន្ធដារ
៣១.កម្មវិធីត្រួតពិនិត្យបេក្ខជនប្រឡង
៣២.កម្មវិធីជជែកជាមួយពន្ធដារ
៣៣.កម្មវិធីអង្កេតអចលនទ្រព្យ

### ឆ្នាំ២០១៩

៣៤.ប្រព័ន្ធគ្រប់គ្រងការស្នើសុំបង្វិលសង អតប

### ឆ្នាំ២០២០

៣៥.គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ
៣៦.ប្រព័ន្ធគ្រប់គ្រងរបាយការណ៍នៃការធ្វើសារខ្លី
៣៧.ប្រព័ន្ធបញ្ជូនឯកសារលិខិតប្រកាសរបស់អពជ
៣៨.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពជ និងអគរក
៣៩.ប្រព័ន្ធសន្ទានកម្មទិន្នន័យរវាងប្រព័ន្ធអពជ និងដឹកជញ្ជូនផ្លូវគោក នៃក្រសួងសាធារណការនិងដឹកជញ្ជូន
៤០.ប្រព័ន្ធសន្ទានកម្មទិន្នន័យចំណូលពន្ធរវាង FMIS
៤១.ប្រព័ន្ធគ្រប់គ្រងស្នើសុំការលើកទឹកចិត្តពន្ធដារ
៤២.ប្រព័ន្ធគ្រប់គ្រងការសិក្សាពន្ធដារ
៤៣.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកជាប់ពន្ធ
៤៤.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ
៤៥.ប្រព័ន្ធគ្រប់គ្រងសន្និធិរបស់អគ្គនាយកដ្ឋានពន្ធដារ
៤៦.ប្រព័ន្ធគ្រប់គ្រងការចៀសវាងយកពន្ធត្រួតគ្នា
៤៧.ប្រព័ន្ធគ្រប់គ្រងចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យា
៤៨.ប្រព័ន្ធគ្រប់គ្រងបង់ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិយានយន្ត
៤៩.កម្មវិធីការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច
៥០.កម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ
៥១.កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ
៥២.កម្មវិធីគ្រប់គ្រងលិខិតរដ្ឋបាលពន្ធដារ

### ឆ្នាំ២០២១

៥៣.ប្រព័ន្ធស្វ័យប្រវត្តិកម្មផ្ទៀងផ្ទាត់ការបង់ពន្ធ
៥៤.ប្រព័ន្ធគ្រប់គ្រងរបាយការណ៍ពន្ធដារ
៥៥.ប្រព័ន្ធគ្រប់គ្រងសវនកម្មអាករលើតម្លៃបន្ថែម
៥៦.ប្រព័ន្ធគាំទ្រការបង់ពន្ធមធ្យោបាយដឹកជញ្ជូន
៥៧.ប្រព័ន្ធគ្រប់គ្រងការស្នើសុំលិខិតបញ្ជាក់និងវិញ្ញាបនបត្រ
៥៨.ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធTOIអនឡាញ
៥៩.កម្មវិធីបញ្ជូនឯកសារអេឡិចត្រូនិក
៦០.កម្មវិធីដឹកជញ្ជូនរបស់អគ្គនាយកដ្ឋានពន្ធដារ
៦១.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មាននិងប្រគល់ឯកសារពន្ធដារ

### ឆ្នាំ២០២២

៦២.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធតែមប្រើ
៦៣.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធមធ្យោបាយ
៦៤.ប្រព័ន្ធគ្រប់គ្រងគណនីអ្នកប្រើប្រាស់តាមអនឡាញ
៦៥.ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្ម
៦៦.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធអចលនទ្រព្យ
៦៧.ប្រព័ន្ធគ្រប់គ្រងអត្រាប្តូរប្រាក់
៦៨.ប្រព័ន្ធស្នូលនៃអគ្គនាយកដ្ឋានពន្ធដារ(CoreSystem)
៦៩.ប្រព័ន្ធគ្រប់គ្រងកម្មវិធីក្លាយបត្រនាំសំណាង
៧០.ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក
៧១.ប្រព័ន្ធគ្រប់គ្រងទិន្នន័យឧបករណ៍វាស់ចំណុះស្រាបៀរនិងភេសជ្ជៈ
៧២.ប្រព័ន្ធគ្រប់គ្រងចំណាត់ថ្នាក់(MeritandDemerit_MDS)
៧៣.កម្មវិធីក្លាយបត្រនាំសំណាង
៧៤.កម្មវិធីសទ្ទានុក្រមពន្ធដារ
៧៥.កម្មវិធីផ្ទៀងផ្ទាត់ព័ត៌មានសិស្ស(សម្រាប់ការបណ្តុះបណ្តាល)

### ឆ្នាំ២០២៣

៧៦.កម្មវិធីអនុម័តតាមប្រព័ន្ធអេឡិចត្រូនិក
៧៧.ប្រព័ន្ធគ្រប់គ្រងការអនុម័តតាមប្រព័ន្ធអេឡិចត្រូនិក(សម្រាប់មន្ត្រី)
៧៨.ប្រព័ន្ធគ្រប់គ្រងនិងគាំទ្រកម្មវិធីទូរស័ព្ទដៃ-ពន្ធលើផ្ទាំងផ្សព្វផ្សាយ
៧៩.ប្រព័ន្ធកំណត់ផែនការចំណូលពន្ធ
៨០.កម្មវិធីលិខិតរដ្ឋបាលអេឡិចត្រូនិក
៨១.កម្មវិធីផ្ទាំងព័ត៌មានលិខិតរដ្ឋបាលអេឡិចត្រូនិក

### ឆ្នាំ២០២៤

៨២.ប្រព័ន្ធគ្រប់គ្រងសហគ្រាសដើម និងភ្នាក់ងារផ្គត់ផ្គង់បន្ត

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីនាក់ទងនឹងពន្ធដារ

## កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)




**ទស្សនាតាមផ្នែក៖**

- 03:49 : សម្រាប់បុគ្គលទូទៅ
- 07:33 : សម្រាប់ភ្នាក់ងារសេវាកម្មពន្ធដារ
- 11:46 : សម្រាប់អ្នកតំណាងសហគ្រាស

សូមស្កេន QR Code

## កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)



មុខងារបង់ពន្ធលើផ្ទាំងផ្សព្វផ្សាយ

**ទស្សនាតាមផ្នែក៖**

- 00:46 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:03 : ការចូលប្រើប្រាស់កម្មវិធី
- 02:38 : ការបំពេញលិខិតប្រកាសពន្ធលើផ្ទាំងផ្សព្វផ្សាយ

សូមស្កេន QR Code




មុខងារបន្ថែមយានយន្តថ្មី

**ទស្សនាតាមផ្នែក៖**

- 00:26 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : ការបំពេញបន្ថែមយានយន្តថ្មី

សូមស្កេន QR Code




មុខងារបង់ពន្ធអចលនទ្រព្យ រហ័ស

**ទស្សនាតាមផ្នែក៖**

- 01:00 : ការចូលប្រើប្រាស់កម្មវិធី
- 02:03 : របៀបបង់ពន្ធអចលនទ្រព្យ

សូមស្កេន QR Code

## ប្រព័ន្ធបង់ប្រាក់ពន្ធតាមអនឡាញ (E-Payment)




**ទស្សនាតាមផ្នែក៖**

- 00:30 : ការចូលប្រើប្រាស់កម្មវិធី
- 00:40 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 01:40 : របៀបបង់ពន្ធតាមអនឡាញ

សូមស្កេន QR Code

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីនាក់ទងនឹងពន្ធដារ

## ប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ សម្រាប់អ្នកជាប់ពន្ធមធ្យម និង ធំ (e-Filing)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការចុះឈ្មោះដើម្បីប្រើប្រាស់ប្រព័ន្ធ
- 01:54 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 07:05 : ការប្រកាសពន្ធប្រចាំខែ

សូមស្កេន QR Code




មុខងារ (Reverse Charge)

**ទស្សនាតាមផ្នែក៖**

- 00:50 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 01:30 : ការប្រកាសពន្ធ

សូមស្កេន QR Code

## កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)




**ទស្សនាតាមផ្នែក៖**

- 00:50 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 02:10 : ការចូលប្រើប្រាស់កម្មវិធី

សូមស្កេន QR Code



មុខងារប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

**ទស្សនាតាមផ្នែក៖**

- 00:40 : ការចូលប្រើប្រាស់កម្មវិធី
- 00:50 : ការប្រកាសពន្ធលើប្រាក់ចំណូល ប្រចាំឆ្នាំ

សូមស្កេន QR Code

## ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Tax System)




(Khmer Version) (English Version)

# QR Code វីដេអូណែនាំអំពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីទាក់ទងនឹងពន្ធដារ

## កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)




ទស្សនាតាមផ្នែក៖

- 00:20 : ការបង្កើតគណនីប្រើប្រាស់កម្មវិធី
- 01:50 : ការចូលប្រើប្រាស់កម្មវិធី
- 02:30 : ការបញ្ចូលវិក្កយបត្រថ្មី

សូមស្កេន QR Code

## ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ



មុខងារស្នើសុំអាជ្ញាប័ណ្ណភ្នាក់ងារសេវាកម្មពន្ធដារ

ទស្សនាតាមផ្នែក៖

- 01:00 : ការបង្កើតគណនីថ្មី
- 02:20 : ការចូលប្រើប្រាស់ប្រព័ន្ធ
- 02:55 : ការដាក់ពាក្យស្នើសុំនិងបោះពុម្ពវិញ្ញាបនបត្រពន្ធដារ

សូមស្កេន QR Code



មុខងារស្នើសុំការផ្អាកអាជីវកម្ម ឬបើកដំណើរការឡើងវិញ

ទស្សនាតាមផ្នែក៖

- 00:45 : ការស្នើសុំផ្អាកសកម្មភាពអាជីវកម្មបណ្ដោះអាសន្ន
- 02:40 : បន្តស្នើសុំផ្អាកសកម្មភាពអាជីវកម្ម
- 05:00 : ស្នើសុំបើកដំណើរការឡើងវិញ

សូមស្កេន QR Code

## កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track) ជំនាន់ថ្មី




ទស្សនាតាមផ្នែក៖

- 00:20 : ការប្រើប្រាស់កម្មវិធី
- 00:45 : មុខងារផ្សេងៗ

សូមស្កេន QR Code

## កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)




ទស្សនាតាមផ្នែក៖

- 00:40 : ការប្រើប្រាស់កម្មវិធី
- 02:00 : មុខងារផ្សេងៗ

សូមស្កេន QR Code

# ផ្នែកទី៣
# បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

១.	អនុក្រឹត្យ

២.	ប្រកាស

៣.	សេចក្តីណែនាំ

៤.	សេចក្តីជូនដំណឹង

# បច្ចុប្បន្នភាពច្បាប់
# លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ

សរុបក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងកែលម្អគោលនយោបាយសារពើពន្ធ តាមរយៈការដាក់ចេញឱ្យអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារ ដូចមានក្នុងតារាងនិងអត្ថបទខាងក្រោម៖

**បច្ចុប្បន្នភាពច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយសារពើពន្ធ រយៈពេល ៩ខែដើមឆ្នាំ២០២៤**

| បរិយាយ | រយៈពេល៦ខែ | ខែកក្កដា | ខែសីហា | ខែកញ្ញា | សរុបរួម |
|---|---|---|---|---|---|
| ច្បាប់ | ០០ | ០០ | ០០ | ០០ | ០០ |
| អនុក្រឹត្យ | ០៣ | ០២ | ០០ | ០០ | ០៥ |
| ប្រកាស | ១៥ | ០០ | ០១ | ០០ | ១៦ |
| សារាចរណែនាំ | ០០ | ០០ | ០០ | ០០ | ០០ |
| សេចក្តីណែនាំ | ០៦ | ០០ | ០១ | ០១ | ០៨ |
| សេចក្តីជូនដំណឹង | ០៧ | ០២ | ០០ | ០០ | ០៩ |
| សេចក្តីសម្រេច | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបរួម** | ៣១ | ០៤ | ០២ | ០១ | ៣៨ |

## ១.អនុក្រឹត្យ

### អនុក្រឹត្យ ស្តីពីការបង្កើតអង្គភាពសវនកម្មពន្ធដារ ពិសេសចំណុះអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ១៦០ អនក្រ.បក ស្តីពីការបង្កើតអង្គភាពសវនកម្មពន្ធដារពិសេសចំណុះអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ការបង្កើតអង្គភាពសវនកម្មពន្ធដារពិសេសនេះ ជាយន្តការជំរុញនិងពន្លឿនការដោះស្រាយបញ្ហានានារបស់អ្នកជាប់ពន្ធពាក់ព័ន្ធនឹងការងារសវនកម្មពន្ធដារឱ្យបានឆាប់រហ័ស ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ សំដៅកែលម្អបរិយាកាសធុរកិច្ចនិងការវិនិយោគ។ នៅក្នុងអនុក្រឹត្យមានចែងលម្អិតអំពីឋានៈ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អង្គភាពនេះ ព្រមទាំងមានចែងពីអន្តរប្បញ្ញត្តិមួយចំនួនទៀត៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

### អនុក្រឹត្យ ស្ដីពីការតែងតាំងប្រធានអង្គភាពសវនកម្មពន្ធដារពិសេស ចំណុះអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ ៧១៩ អនក្រ.តត ស្ដីពីការតែងតាំងប្រធានអង្គភាពសវនកម្មពន្ធដារពិសេសចំណុះអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ នៅក្នុងអនុក្រឹត្យនេះមានចែងសម្រេចតែងតាំងមុខតំណែងលោក **សៀង ស៊ីថា** ជាប្រធានអង្គភាពសវនកម្មពន្ធដារពិសេសចំណុះអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានឋានៈស្មើប្រធាននាយកដ្ឋានបន្ថែមលើមុខងារបច្ចុប្បន្ន៕

## ២.ប្រកាស

### ប្រកាស ស្ដីពីការនិរាករណ៍ប្រកាសលេខ ៣៦០ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការណែនាំអនុវត្តអនុក្រឹត្យស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នាថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ៥២៥ សហវ.ប្រក ស្ដីពីការនិរាករណ៍ប្រកាសលេខ ៣៦០ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការណែនាំអនុវត្តអនុក្រឹត្យស្ដីពីការលើកទឹកចិត្តផ្នែកពន្ធដារ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការចេញប្រកាសនេះក្នុងគោលបំណងនិរាករណ៍ប្រកាសលេខ ៣៦០ សហវ.ប្រក.អពដ ដើម្បីបញ្ចៀសការយល់ច្រឡំ និងបំបាត់ក្ដីបារម្ភរបស់ម្ចាស់អាជីវកម្មដែលមានចំណូលដុលក្រោម ២៥០ លានរៀល៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## ៣.សេចក្ដីណែនាំ

### សេចក្ដីណែនាំ ស្ដីពីការអនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះការជួលអចលនទ្រព្យ

នាថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្ដីណែនាំលេខ ៣៣០០០ អពដ ស្ដីពីការអនុវត្តកាតព្វកិច្ចសារពើពន្ធចំពោះការជួលអចលនទ្រព្យ។ ក្នុងគោលបំណងផ្ញើការណែនាំដល់លោក-លោកស្រីជាអភិបាល បណ្ណាធិការ ឬកម្មសិទ្ធិករ ដែលធ្វើសកម្មភាពជួលអចលនទ្រព្យ ដើម្បីអនុវត្តមានសង្គតិភាពស្របតាមបទប្បញ្ញត្តិស្ដីពីពន្ធលើប្រាក់ចំណូលនិងអាករលើតម្លៃបន្ថែម ត្រូវអនុវត្តដូចខាងក្រោម៖

- កិច្ចសន្យាជួលអចលនទ្រព្យ ដែលមានចែងអំពីការទុករយៈពេលសម្រាប់សាងសង់ រចនា ជួសជុល ឬកែលម្អ ហើយអំឡុងពេលនោះ ម្ចាស់អចលនទ្រព្យមិនគិតថ្លៃឈ្នួលឬគិតថ្លៃឈ្នួលក្នុងកម្រិតណាមួយ ពន្ធលើប្រាក់ចំណូល ពន្ធកាត់ទុកលើថ្លៃឈ្នួលអចលនទ្រព្យ និងអាករលើតម្លៃបន្ថែម ត្រូវអនុវត្តតាមកិច្ចសន្យានោះ។ ការទុករយៈពេលសម្រាប់សាងសង់ រចនា ជួសជុល ឬកែលម្អ មិនត្រូវលើសពី ១០% នៃរយៈពេលជួលសរុបក្នុងកិច្ចសន្យា។
- ក្នុងករណីមានកិច្ចសន្យាដូចមានចែងក្នុងចំណុចទី១ ខាងលើ ម្ចាស់អចលនទ្រព្យត្រូវដាក់ជូនរដ្ឋបាលសារពើពន្ធនូវកិច្ចសន្យាជួលអចលនទ្រព្យនោះក្នុងអំឡុងពេល ៣០ថ្ងៃ ក្រោយថ្ងៃចុះកិច្ចសន្យា។
- ប្រសិនបើរយៈពេលសម្រាប់សាងសង់ រចនា ជួសជុល ឬកែលម្អ ត្រូវបានពន្យារ ម្ចាស់អចលនទ្រព្យ ត្រូវស្នើសុំមករដ្ឋបាលសារពើពន្ធដើម្បីពិនិត្យនិងសម្រេច៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្តីណែនាំ ស្តីពីការនិរាករណ៍សេចក្តីណែនាំលេខ ១៨៤១២ អពដ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាស មីក្រូ តូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

នាថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីណែនាំលេខ ៣០០៣៨ អពដ ស្តីពីការនិរាករណ៍សេចក្តីណែនាំលេខ ១៨៤១២ អពដ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាស មីក្រូ តូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ ការចេញសេចក្តីណែនាំនេះ គឺដើម្បីជម្រាបជូនអង្គភាពក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារទាំងអស់ ឱ្យបានជ្រាបថា អគ្គនាយកដ្ឋានពន្ធដារសម្រេចនិរាករណ៍សេចក្តីណែនាំលេខ ១៨៤១២ អពដ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤ ស្តីពីការអនុវត្តការលើកទឹកចិត្តផ្នែកពន្ធដារចំពោះសហគ្រាស មីក្រូ តូច និងមធ្យម សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ រហូតដល់មានការណែនាំការអនុវត្តជាថ្មី៕

# ៤.សេចក្តីជូនដំណឹង

## សេចក្តីជូនដំណឹង ស្តីពីការអនុវត្តកម្មវិធីសវនកម្មពន្ធដារឆ្នាំ២០២៤

នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ២៤១៤៥ អពដ ស្តីពីការអនុវត្តកម្មវិធីសវនកម្មពន្ធដារឆ្នាំ២០២៤ ។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជូនដំណឹងដល់អ្នកជាប់ពន្ធឱ្យបានជ្រាបថា អគ្គនាយកដ្ឋានពន្ធដារនឹងចុះធ្វើសវនកម្មដល់ទីកន្លែងលើសហគ្រាសចំនួន ៣ ០០៦ ក្នុងឆ្នាំ២០២៤នេះ ដែលលិខិតជូនដំណឹងស្តីពីការចុះធ្វើសវនកម្មពន្ធដារនឹងត្រូវផ្ញើជូនដល់សហគ្រាសនីមួយៗ ដើម្បីត្រៀមខ្លួនក្នុងការផ្តល់កិច្ចសហការជាមួយរដ្ឋបាលសារពើពន្ធ។ ជាមួយគ្នានេះ សហគ្រាសអាចត្រូវបានចុះធ្វើសវនកម្មដល់ទីកន្លែងតែម្តងក្នុងរង្វង់ ៣ឆ្នាំ លើកលែងតែករណីដែលអគ្គនាយកដ្ឋានពន្ធដារ រកឃើញថាមានហានិភ័យឬភាពមិនប្រក្រតី ហើយសហគ្រាសក៏អាចស្នើសុំមកអគ្គនាយកដ្ឋានពន្ធដារឱ្យមានការធ្វើសវនកម្មដើម្បីផ្ទៀតផ្ទាត់ការបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងរង្វង់ ៣ឆ្នាំនេះផងដែរ៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

## សេចក្តីជូនដំណឹង ស្តីពីការរំលឹកការប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០២៤

នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានចេញសេចក្តីជូនដំណឹងលេខ ២៧១៩៩ អពដ ស្តីពីការរំលឹកការប្រកាសបង់ពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០២៤។ ការចេញសេចក្តីជូនដំណឹងនេះ គឺដើម្បីជូនដំណឹងដល់ម្ចាស់អចលនទ្រព្យទាំងអស់ ដែលមានអចលនទ្រព្យស្ថិតនៅរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្តទាំងអស់ឱ្យបានជ្រាបថា ការប្រមូលនិងបង់ពន្ធលើអចលនទ្រព្យនឹងត្រូវបិទបញ្ចប់នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤ ខាងមុខនេះ។ ម្ចាស់អចលនទ្រព្យដែលមិនទាន់បានប្រកាសនិងបង់ប្រាក់ពន្ធអាចអញ្ជើញមកធ្វើការប្រកាសបង់ពន្ធនៅសាខាពន្ធដារខេត្ត-ខណ្ឌដែលអចលនទ្រព្យស្ថិតនៅ ឬនៅតាមបណ្តាសាខាធនាគារពាណិជ្ជដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬអាចបង់ពន្ធតាមកម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) ដែលអាចទាញយកពី App Store សម្រាប់ iOS ឬ Play Store សម្រាប់ Android៕

ដើម្បីទទួលបានឯកសារ ឬអានលម្អិត សូមស្កេន QR Code

# ផ្នែកទី៤
# កិច្ចសហប្រតិបត្តិការក្របខ័ណ្ឌជាតិ-អន្តរជាតិ

១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ
២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន
៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

# ១. សកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ

## កិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធ ប្រចាំខែកក្កដា និងសម្រាប់រយៈពេល ៧ខែ ឆ្នាំ២០២៤ ព្រមទាំងទិសដៅ សម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៥ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែកក្កដា និងសម្រាប់រយៈពេល ៧ខែឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលបានរៀបចំដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានវត្តមានចូលរួមរបស់ឯកឧត្តម-លោកជំទាវអគ្គនាយករង ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្នាក់ដឹកនាំ នាយកដ្ឋានថ្នាក់កណ្តាល ទីចាត់ការពន្ធដាររាជធានីភ្នំពេញ សាលាជាតិពន្ធដារ សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **គង់ វិបុល** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ដែលបានចូលរួមនាថ្ងៃនេះ។ ចំពោះលទ្ធផលប្រមូលពន្ធអាករ ក្នុងខែកក្កដា ឆ្នាំ២០២៤ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានបង្ហាញថាចំណូលពន្ធអាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **៩៦០,៧៩ ប៊ីលានរៀល (ប្រមាណជា ២៣៧,២៣ លានដុល្លារ)** ។ សរុបរយៈពេល ៧ខែ ឆ្នាំ២០២៤ ចំណូលពន្ធអាករដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **៨ ៧២៨,៧១** ប៊ីលានរៀល **(ប្រមាណជា ២ ១៥៥,២៤ លានដុល្លារ)**។ ឯកឧត្តមក៏បានថ្លែងប្រកាសអំពីលទ្ធផលការងារសំខាន់ៗរបស់អគ្គនាយកដ្ឋានពន្ធដារដែលសម្រេចបានក្នុងខែកក្កដា និងរយៈពេល ៧ខែឆ្នាំ២០២៤ និងដាក់ចេញនូវវិធានការនិងយុទ្ធសាស្ត្រសំខាន់ៗ ជាទិសដៅសម្រាប់អនុវត្តបន្តក្នុង

ឆ្នាំ២០២៤។ ចំពោះលទ្ធផលការងារសំខាន់ៗ និងវិធានការពិស្តារជាមួយនឹងយុទ្ធសាស្ត្រសំខាន់ៗ ត្រូវបានបរិយាយសរុបរួមជាមួយអត្ថបទកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលពន្ធប្រចាំខែសីហា និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ខាងក្រោម៕



*ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*



*លោកជំទាវ **ប៊ិន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



*ឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



*ឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



*លោក **លីម ដឹលុច** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

# កិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធ ប្រចាំខែសីហា និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ ព្រមទាំងទិសដៅ សម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ



*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃអង្គារ ទី១៧ ខែកញ្ញា ឆ្នាំ២០២៤ នៅសាលប្រជុំសាលាជាតិពន្ធដារ នៃអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារគ្រប់គ្រងប្រមូលចំណូលពន្ធប្រចាំខែសីហា និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ ព្រមទាំងទិសដៅសម្រាប់អនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានវត្តមានចូលរួមផ្ទាល់របស់ឯកឧត្តមអគ្គនាយករង ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្ដាល ទីចាត់ការពន្ធដាររាជធានីភ្នំពេញ សាលាជាតិពន្ធដារ អង្គភាពសវនកម្មពន្ធដារពិសេស សាខាពន្ធដារខណ្ឌ និងការចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ (Zoom Meeting) របស់ប្រធានសាខាពន្ធដារខេត្ត ព្រមទាំងថ្នាក់ដឹកនាំនាយកដ្ឋានថ្នាក់កណ្ដាល សាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីរាជការពន្ធដារពាក់ព័ន្ធទាំងអស់ ក្រោមចំណុះរបស់អគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្ដើម ឯកឧត្តម **គង់ វិបុល** បានស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោក-លោកស្រីទាំងអស់នាថ្ងៃដ៏មានសារៈសំខាន់នេះ។ ចំពោះលទ្ធផលប្រមូលពន្ធអាករ ក្នុងខែសីហា ឆ្នាំ២០២៤ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីបានបង្ហាញថា ចំណូលពន្ធអាករគ្រប់ប្រភេទដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្ដែង តាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន **៩៧០,៥០ ប៊ីលានរៀល** (ប្រមាណជា **២៣៩,៦៣ លានដុល្លារ**) និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ បានសរុបចំនួន **៩ ៦៩៩,៤០ ប៊ីលានរៀល** (ប្រមាណជា **២ ៣៩៤,៩១ លានដុល្លារ**)។

## លទ្ធផលការងារសំខាន់ៗរបស់អគ្គនាយកដ្ឋានពន្ធដារសម្រេចបាន ក្នុងខែសីហា និងសម្រាប់រយៈពេល៨ខែ ឆ្នាំ២០២៤៖

ជាមួយគ្នានេះ ឯកឧត្តម **គង់ វិបុល** បានរាយការណ៍អំពីសមិទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានពន្ធដារសម្រេចបាន ក្នុងខែសីហា និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ ព្រមទាំងទិសដៅអនុវត្តបន្តរបស់អគ្គនាយកដ្ឋានពន្ធដារ មានដូចខាងក្រោម៖

- បាននិងកំពុងបន្តកិច្ចសហការល្អ និងបន្តដោះស្រាយនូវកង្វល់ពាក់ព័ន្ធនឹងពន្ធដារនានាជូនវិស័យឯកជន ព្រមទាំងបានរៀបចំកិច្ចប្រជុំក្រុមការងារអគ្គនាយកដ្ឋានពន្ធដារនិងផ្នែកឯកជន ដោយមានការចូលរួមពីអតីតសហប្រធាន និងសហប្រធានថ្មីផ្នែកឯកជន សមាគម សភាពាណិជ្ជកម្មសំខាន់ៗ និងតំណាងនៃសហគ្រាសធំៗមួយចំនួន
- បានពិនិត្យនិងអនុម័តការស្នើសុំចុះបញ្ជីពន្ធដារ ក្នុងខែសីហា ឆ្នាំ២០២៤ ចំនួន **១ ១៨៦ សហគ្រាស** (ចុះបញ្ជីជោគជ័យ ចំនួន **៩៦៨ សហគ្រាស** ក្នុងនោះតាមថ្នាល CamDX ចំនួន **៩០៣ សហគ្រាស**) និងសរុបរយៈពេល ៨ខែ ឆ្នាំ២០២៤ ចំនួន **៨ ៥២៨ សហគ្រាស** (ចុះបញ្ជីជោគជ័យចំនួន **៧ ១៥២សហគ្រាស** ក្នុងនោះតាមថ្នាល CamDX ចំនួន **៦ ៦៥០ សហគ្រាស**)
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងវគ្គបណ្តុះបណ្តាល ក្នុងគោលដៅពង្រឹងការយល់ដឹងអំពីពន្ធដារពាក់ព័ន្ធនឹងច្បាប់និងបទប្បញ្ញត្តិ ទំនើបកម្មពន្ធដារ និងវឌ្ឍនភាពថ្មីៗ ជាពិសេសពាក់ព័ន្ធនឹងការផ្តល់សេវាអ្នកជាប់ពន្ធ ក្នុងខែសីហា ចំនួន **៧៤ លើក** មានសិក្ខាកាមចូលរួមចំនួន **៨ ១៦០ រូប** និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ បានសរុបចំនួន **៥៤៥ លើក** មានសិក្ខាកាមចូលរួមចំនួន **៧២ ៨៤៦ រូប**
- បានផ្តល់កិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធទាំងស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងវិស័យឯកជននិងអង្គការសមាគម ក្នុងខែសីហា ឆ្នាំ២០២៤ មានសរុបចំនួន **៤៨ លើក** ក្នុងនោះជាមួយស្ថាប័នជាតិ ចំនួន **៤១ លើក**, និងវិស័យឯកជន និងអង្គការសមាគម ចំនួន **៧ លើក** និងសរុបរយៈពេល ៨ខែ ឆ្នាំ២០២៤ មានចំនួន **៣៣៥ លើក** ក្នុងនោះជាមួយ ស្ថាប័នជាតិ ចំនួន **២៨៩ លើក**, ស្ថាប័នអន្តរជាតិ **៤ លើក** និងវិស័យឯកជននិង អង្គការសមាគមចំនួន **៤២ លើក**
- ក្នុងខែសីហា ឆ្នាំ២០២៤ បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធ-កម្មវិធីចំនួន **១១** (ស្មើនឹង ២១ លើក) និងសរុបរយៈពេល ៨ខែ ឆ្នាំ២០២៤ បានធ្វើបច្ចុប្បន្នភាពប្រព័ន្ធ-កម្មវិធីចំនួន **៣៤** (ស្មើនឹង ២០៣ លើក)
- ក្នុងរយៈពេល ៨ខែ ឆ្នាំ២០២៤ បានផ្តល់សេវាពិគ្រោះយោបល់ជូនអ្នកជាប់ពន្ធតាមគ្រប់រូបភាពចំនួន **៦៨ ១៦៥ ករណី** ក្នុងនោះ តាមរយៈមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (GDT Call Center-1277) ចំនួន **៤៣ ៩៥៣ ករណី**, កម្មវិធីជជែកផ្ទាល់តាមសារឆ្លើយឆ្លងជាមួយអ្នកជាប់ពន្ធ (GDT Live Chat) ចំនួន **២០ ១០៣ ករណី**, បណ្តាញទំនាក់ទំនងសង្គម Facebook ចំនួន **៣ ១៦៩ ករណី**, កម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ (GDT E-Learning) ចំនួន **២៥ លើក**, ព័ត៌មានពន្ធដារកម្ពុជា (GDT News Channel) ចំនួន **៨៨៤ ករណី** និងកម្មវិធីពន្ធដារកម្ពុជា (GDT Facebook Live) ចំនួន **៣១ លើក**
- បានធ្វើសវនកម្មលើសហគ្រាសក្នុងខែសីហា ឆ្នាំ២០២៤ ចំនួន **៦២៣ ករណី** និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ សរុបចំនួន **៧ ៦៤៣ ករណី**
- បានដោះស្រាយសំណុំឯកសារបណ្តឹងតវ៉ាលើករណីសវនកម្មពន្ធដារក្នុងខែសីហា ឆ្នាំ២០២៤ មានចំនួន **៤០ ករណី** និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ សរុបចំនួន **៥៩៨ ករណី**
- បានរៀបចំ និងចូលរួមរៀបចំកែលម្អគោលនយោបាយសារពើពន្ធតាមរយៈការចូលរួមរៀបចំលិខិតបទដ្ឋានគតិយុត្តក្នុងខែសីហា ឆ្នាំ២០២៤ចំនួន**២** (ប្រកាសចំនួន ១ និងសេចក្តីណែនាំចំនួន ១) និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ សរុបចំនួន **៣៧** (អនុក្រឹត្យចំនួន ៥, ប្រកាសចំនួន ១៦, សេចក្តីណែនាំចំនួន ៧ និង សេចក្តីជូនដំណឹងចំនួន ៩)
- បានពិនិត្យ និងសម្រេចលើការស្នើសុំអត្ថប្រយោជន៍ពីការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement - DTA) ក្នុងខែសីហា ឆ្នាំ២០២៤ បានចំនួន **៤១ សហគ្រាស** និងសម្រាប់រយៈពេល ៨ខែ ឆ្នាំ២០២៤ បានសរុបចំនួន **៣៦១ សហគ្រាស** ដោយគិតត្រឹមខែសីហា ឆ្នាំ២០២៤ កម្ពុជាបាននិងកំពុងអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (DTA) ជាមួយរដ្ឋបាលសារពើពន្ធ

ចំនួន ១១ ក្នុងនោះមានរដ្ឋបាលសារពើពន្ធថៃ, សិង្ហបុរី, ព្រុយណេ, ចិន, វៀតណាម, តំបន់រដ្ឋបាលពិសេសហុងកុង, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី, កូរ៉េខាងត្បូង, ម៉ាកាវ និងតួកគី

- ក្នុងឆ្នាំ២០២៤ បានផ្ដល់សេវាគាំទ្រអេឡិចត្រូនិក e-Tax Service បានចំនួន **២៣ ២៨៤ ករណី** ក្នុងគោលដៅដោះស្រាយបញ្ហា និងការគាំទ្រការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីនានារបស់អគ្គនាយកដ្ឋានពន្ធដារជូនអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារ។

**ជាទិសដៅសម្រាប់អនុវត្តបន្តក្នុងឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវវិធានការនិងយុទ្ធសាស្ត្រសំខាន់ៗដូចខាងក្រោម៖**

- បន្តពង្រឹងការអនុវត្តឱ្យមានប្រសិទ្ធភាពនូវវិធានការនានាពាក់ព័ន្ធនឹងពន្ធដារ ដែលបានដាក់ចេញក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចធិបតី នាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ និងវិធានការលើកទឹកចិត្តផ្នែកពន្ធដារដែលបានលើកឡើងក្នុងសេចក្ដីថ្លែងការណ៍ពិសេសរបស់ **សម្ដេចធិបតី នាយករដ្ឋមន្ត្រី** ស្ដីពីសមិទ្ធផល ១ឆ្នាំ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា កាលពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤
- បន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រង និងការប្រមូលចំណូលពន្ធ ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក្នុងការពង្រឹងការអនុវត្តវិធានការសំខាន់ៗពាក់ព័ន្ធនឹង ១.អាករពិសេសលើវិស័យភេសជ្ជៈ, ២.ការគ្រប់គ្រងប្រមូលបំណុលពន្ធ ដោយឈរលើគោលការណ៍ទន់ភ្លន់ តែម៉ឺងម៉ាត់ និងច្បាស់លាស់, ៣.ការបញ្ចប់ករណីសវនកម្មដែលនៅសេសសល់ និង៤.អត្រាអាករពិសេសសម្រាប់ផលិតផលថ្នាំជក់ផលិតនិងចែកចាយក្នុងស្រុក
- បន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងកម្មវិធីប្រកបដោយស្មារតីបុរេសកម្មតាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាននិងហេដ្ឋារចនាសម្ព័ន្ធគាំទ្រនិងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យមានភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ តាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់គ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងងាយស្រួលក្នុងការអនុវត្ត
- បន្តរៀបចំការបណ្ដុះបណ្ដាលជូនមន្ត្រី និងផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនអ្នកជាប់ពន្ធនិងសាធារណជនអំពីសៀវភៅណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្ដីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្ដីពីពន្ធដារ
- បន្តផ្សព្វផ្សាយ និងពង្រឹងការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤
- បន្តពង្រឹងតម្លាភាព និងគណនេយ្យភាពនៃការបង់ពន្ធរបស់សហគ្រាសក្នុងវិស័យផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិស្រា ដោយបន្តពង្រឹងអនុវត្តយន្តការបំពាក់កាមេរ៉ាសុវត្ថិភាពនៅតាមរោងចក្រផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិស្រាឱ្យបានរួចរាល់គ្រប់សហគ្រាស ការចុះត្រួតពិនិត្យឧបករណ៍វាស់ចំណុះ (Flowmeter) ក្នុងខ្សែច្រវាក់ផលិតកម្មដល់ទីតាំង ដោយថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ និងការបន្តពង្រឹងការអនុវត្តការងារ និងវត្តមានរបស់មន្ត្រីប្រចាំការ
- បន្តពង្រឹងការងារចុះបញ្ជីពន្ធដារនិងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងបន្តកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធដើម្បីចូលរួមកែលម្អនិងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាពនិងមានភាពគ្រប់ជ្រុងជ្រោយ តាមរយៈការពិនិត្យនិងស្វែងរក

ដំណោះស្រាយចំពោះបញ្ហាប្រឈមនានា

- បន្តពង្រឹងកិច្ចសហការជាមួយវិស័យឯកជន ជាពិសេសក្នុងក្របខ័ណ្ឌនៃកិច្ចសហការជាមួយវិស័យឯកជន និងសភាពាណិជ្ជកម្មនានា
- បន្តជំរុញលើការងាររៀបចំ ចរចា និងពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា (DTA) ជាមួយបណ្តាប្រទេសនានា
- បន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាព ដើម្បីគាំទ្រការអនុវត្តវិធានការនានាពាក់ព័ន្ធនឹងពន្ធដារ ដូចមានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ២០២៣-២០២៨
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធថ្មីជូនដល់អ្នកជាប់ពន្ធ សាធារណជន ព្រមទាំងក្រុមការងារវិស័យឯកជន និងអង្គការ សមាគមនានាតាមគ្រប់រូបភាព ព្រមទាំងបន្តរៀបចំធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារឱ្យស្របតាមច្បាប់ស្តីពីសារពើពន្ធ
- ជំរុញនិងខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងត្រូវមានភាពទន់ភ្លន់តែម៉ឺងម៉ាត់ និងច្បាស់លាស់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធនិងការគ្រប់គ្រងប្រមូលចំណូលពន្ធ ហើយចៀសវាងជាដាច់ខាតនូវរាល់អំពើអសកម្មនានា ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិនាមរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរាជរដ្ឋាភិបាល
- បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់ និងការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ តាមគ្រប់រូបភាព ជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់និងដោះស្រាយការលំបាកនិងចម្ងល់នានារបស់ប្រជាពលរដ្ឋ
- បន្តពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពរបស់ក្រុមការងារអ្នកនាំពាក្យនិងប្រតិកម្មរហ័សនៃអគ្គនាយកដ្ឋានពន្ធដារ និងការចូលរួមដោយសកម្មជាមួយក្រុមការងារតាមដានសាធារណមតិនិងប្រតិកម្មរហ័សរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីតាមដានបញ្ហាសាធារណមតិ និងផ្សព្វផ្សាយឱ្យសាធារណជនបានជ្រួតជ្រាបកាន់តែច្បាស់ពីការខិតខំប្រឹងប្រែងកសាងសមិទ្ធផលយ៉ាងសន្ធឹកសន្ធាប់ ដែលរាជរដ្ឋាភិបាលបានសម្រេចជូនជាតិមាតុភូមិ៕



# កិច្ចប្រជុំពិភាក្សាជាមួយគណៈប្រតិភូអាជ្ញាធរសវនកម្មជាតិ លើកំណត់សម្គាល់សវនកម្មនៅអគ្គនាយកដ្ឋានពន្ធដារ (បណ្តោះអាសន្ន) សម្រាប់ឆ្នាំ២០២៣




នាព្រឹកថ្ងៃព្រហស្បតិ៍ ទី២៩ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយគណៈប្រតិភូអាជ្ញាធរសវនកម្មជាតិ លើកំណត់សម្គាល់សវនកម្មនៅអគ្គនាយកដ្ឋានពន្ធដារ (បណ្តោះអាសន្ន) សម្រាប់ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គន់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម **សំរិត សាត** នាយកខុទ្ទកាល័យ នៃអាជ្ញាធរសវនកម្មជាតិ ដោយមានការចូលរួមពីឯកឧត្តម-លោកអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកជំទាវអគ្គលេខាធិការរងនៃអាជ្ញាធរសវនកម្មជាតិ ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារនិងអាជ្ញាធរសវនកម្មជាតិ៕


ឯកឧត្តម ***សំរិត សាត***
*នាយកខុទ្ទកាល័យ នៃអាជ្ញាធរសវនកម្មជាតិ*


*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជា*
*ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*





# កិច្ចប្រជុំពិភាក្សាលើការងារធ្វើសវនកម្មឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង



នាព្រឹកថ្ងៃអង្គារ ទី១៣ខែសីហា ឆ្នាំ២០២៤អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកិច្ចប្រជុំពិភាក្សាលើការងារធ្វើសវនកម្មឆ្នាំ២០២៤ របស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រោមអធិបតីភាពលោកជំទាវ **ប៊ុន នារី** អគ្គនាយករង និងឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តមបណ្ឌិត **ជា វុធណា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ និងគណៈប្រតិភូនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង៕



*ឯកឧត្តមបណ្ឌិត **ជា វុធណា***
*ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង*



*លោកជំទាវ **ប៊ុន នារី***
*អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*





# ដំណើរទស្សនកិច្ចសិក្សាឈ្វេងយល់អំពីការគ្រប់គ្រងធនធានមនុស្ស នៅអគ្គនាយកដ្ឋានពន្ធដាររបស់គណៈប្រតិភូនៃកំពង់ផែស្វយ័តភ្នំពេញ




នាព្រឹកថ្ងៃពុធ និងព្រហស្បតិ៍ ទី១០-១១ ខែកក្កដា ឆ្នាំ២០២៤ តបតាមការស្នើសុំរបស់ឯកឧត្តម **ហ៊ី បាវី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកនៃកំពង់ផែស្វយ័តភ្នំពេញ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីទទួលដំណើរទស្សនកិច្ចសិក្សាឈ្វេងយល់អំពីការគ្រប់គ្រងធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពឯកឧត្តម **លឹម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយថ្នាក់ដឹកនាំ មន្ត្រីពាក់ព័ន្ធ និងសមាជិកនៃគណៈកម្មការគ្រប់គ្រងកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្សនៃអគ្គនាយកដ្ឋានពន្ធដារសរុបចំនួន **២១ រូប**។ រីឯគណៈប្រតិភូនៃកំពង់ផែស្វយ័តភ្នំពេញ ដឹកនាំដោយលោកជំទាវ **ជួន សុខេម** អគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ អ្នកស្រី **ហ៊ី ផានិន** អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ អ្នកស្រី **សេខ គន្ធា** អគ្គនាយករងបច្ចេកទេស ថ្នាក់ដឹកនាំ និងថ្នាក់គ្រប់គ្រងនៃកំពង់ផែស្វយ័តភ្នំពេញចំនួន **៤២ រូប**។ ដំណើរទស្សនកិច្ចសិក្សានេះ បានប្រព្រឹត្តទៅក្នុងគោលបំណងសិក្សាឈ្វេងយល់អំពីទិដ្ឋភាពទាំងស្រុងនៃការអនុវត្តកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយគិតចាប់ពីចំណុចចាប់ផ្តើមដំបូងក្នុងឆ្នាំ២០១២ រហូតមកទល់ពេលបច្ចុប្បន្ននេះ ក្រោមបរិបទនៃការកសាងនិងអភិវឌ្ឍន៍សមត្ថភាពស្ថាប័ននៃអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម លោកជំទាវ **ជួន សុខេម** អគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ និងជាប្រធានគណៈប្រតិភូនៃកំពង់ផែស្វយ័តភ្នំពេញបានសម្តែងនូវសេចក្តីសោមនស្សរីករាយ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការផ្តល់ឱកាសពីឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដែលបានអនុញ្ញាតឱ្យគណៈប្រតិភូនៃកំពង់ផែស្វយ័តភ្នំពេញចុះទស្សនកិច្ចសិក្សានៅអគ្គនាយកដ្ឋានពន្ធដារ។ លោកជំទាវបានលើកឡើងថា កំពង់ផែស្វយ័តភ្នំពេញបានជ្រាបច្បាស់ជាហូរហែ និងបានទទួលស្គាល់អំពីសមិទ្ធផល និងភាពជោគជ័យនៃកម្មវិធីកែទម្រង់ដ៏មុតស្រួចរបស់អគ្គនាយកដ្ឋានពន្ធដារ ជាពិសេសការធ្វើទំនើបកម្មនិងបរិវត្តកម្មរដ្ឋបាលសារពើពន្ធ និងការអនុវត្តកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្សប្រកបដោយ

ប្រសិទ្ធភាព និងគុណភាពខ្ពស់ ស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រកែទម្រង់ស៊ីជម្រៅមុតស្រួច ដែលជាលទ្ធផលមានការទទួលស្គាល់យ៉ាងទូលំទូលាយពីសំណាក់ថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ ព្រមទាំងបណ្ដារដ្ឋបាលសារពើពន្ធនៅក្នុងតំបន់ផងដែរ។

បន្ទាប់មក ឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ បានសម្ដែងគារវកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅចំពោះវត្តមានរបស់គណៈប្រតិភូនៃកំពង់ផែស្វយ័តភ្នំពេញ ដែលបានអញ្ជើញធ្វើទស្សនកិច្ចសិក្សានៅអគ្គនាយកដ្ឋានពន្ធដារ និងបានសម្ដែងនូវជំហរទទួលស្គាល់អគ្គនាយកដ្ឋានពន្ធដារជាស្ថាប័នរដ្ឋមួយដែលមានសមត្ថភាពខ្ពស់លើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយជោគជ័យ ដែលជាផ្នែកមួយដ៏សំខាន់នៃការពង្រឹងស្ថាប័នឱ្យមានសមត្ថភាពខ្ពស់ក្នុងការចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល។ បន្ទាប់ពីមានមតិស្វាគមន៍រួច ឯកឧត្តមបានជម្រាបជូនគណៈប្រតិភូអំពីកម្មវិធីទទួលដំណើរទស្សនកិច្ចទាំងស្រុង ដែលមានរយៈពេល ២ថ្ងៃ ដោយថ្ងៃទីមួយ គឺផ្ដោតទៅលើការធ្វើបទបង្ហាញអំពីសារៈតារនៃការចាប់ផ្ដើមអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅមុតស្រួចរបស់អគ្គនាយកដ្ឋានពន្ធដារដើម្បីធ្វើទំនើបកម្ម និងបរិវត្តកម្មឱ្យក្លាយជារដ្ឋបាលសារពើពន្ធទំនើប ដោយផ្ដោតសំខាន់ទៅលើការកសាង និងពង្រឹងសសរស្តម្ភសំខាន់ចំនួនបួននៃការអភិវឌ្ឍស្ថាប័ន (4 Key Pillars of Institutional Development) រួមមាន៖ សសរស្តម្ភទីមួយ គឺការកែលម្អនិងពង្រឹងរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងអង្គភាពទាំងមូល សសរស្តម្ភទីពីរ គឺការបង្កើតឱ្យមានបែបបទការងារច្បាស់លាស់សម្រាប់ការអនុវត្តការងារ ដោយប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន សសរស្តម្ភទីបី គឺការបង្កើតនិងលើកស្ទួយវប្បធម៌ វិន័យ និងក្រមវិជ្ជាជីវៈជារដ្ឋបាលសារពើពន្ធ និងសសរស្តម្ភទីបួន គឺការគ្រប់គ្រងនិងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស។

ដោយពេលវេលាសម្រាប់ទទួលដំណើរទស្សនកិច្ចសិក្សានេះមានកំណត់ ឯកឧត្តមបានបញ្ជាក់ជូនគណៈប្រតិភូថា អគ្គនាយកដ្ឋានពន្ធដារមិនអាចមានលទ្ធភាពចែករំលែកនូវបទពិសោធនៃការអនុវត្តកម្មវិធីកែទម្រង់ទាំងស្រុងរបស់ខ្លួនក្រោមបរិបទសសរស្តម្ភទាំងបួនបានទេ គឺសូមធ្វើការផ្ដោតទៅលើតែការចែករំលែកបទពិសោធនៃការអនុវត្តកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្ស ដែលជាសសរស្តម្ភទីបួនតែប៉ុណ្ណោះ។ កម្មវិធីកែទម្រង់ផ្នែកធនធានមនុស្ស ក៏ដូចជាការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ គឺជាការរួមចំណែកពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាល ពីដំណាក់កាលទី១ រហូតដល់ទី៤ ព្រមទាំងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១។

បន្ទាប់ពីបានលើកឡើងត្រួសៗអំពីទិដ្ឋភាពរួមទាំងស្រុងនូវដំណើរដើមទងនៃកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្សនៃអគ្គនាយកដ្ឋានពន្ធដារដែលជារបៀបវារៈទី១ ឯកឧត្តមបានស្នើឱ្យក្រុមការងារបន្តអនុវត្តតាមរបៀបវារៈជាបន្តបន្ទាប់ដែលមាន៖ ១.ការចុះទស្សនកិច្ចផ្ទាល់នៅតាមកន្លែងការងារ រួមមានបញ្ជរផ្ដល់សេវាជូនអ្នកជាប់ពន្ធ ការិយាល័យធ្វើការ និងបង្ហាញការចូលប្រើប្រាស់ប្រព័ន្ធរបស់មន្ត្រីជាក់ស្ដែង ២.ការធ្វើបទបង្ហាញស្ដីពីការប្រើប្រាស់ប្រព័ន្ធនិងកម្មវិធីរបស់អគ្គនាយកដ្ឋានពន្ធដារ រួមមាន ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស កម្មវិធីគ្រប់គ្រងលិខិតរដ្ឋបាលពន្ធដារ កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ប្រព័ន្ធគ្រប់គ្រងការតាមដានឯកសារ និងកម្មវិធីទូរស័ព្ទដៃត្រួតពិនិត្យនិងតាមដានឯកសារ ដោយលោក **អៀ ឃឹមតិច** ៣.ការធ្វើបទបង្ហាញស្ដីពីប្រព័ន្ធកំណត់ចំណាត់ថ្នាក់នៃកម្រិតប្រសិទ្ធភាព ក្នុងការគ្រប់គ្រង និងការទទួលខុសត្រូវរបស់ប្រធានអង្គភាព ដោយលោក **ព្រាប បូណា** ៤.ការធ្វើបទបង្ហាញស្ដីពីកម្មវិធីបណ្ដុះបណ្ដាលរបស់អគ្គនាយកដ្ឋានពន្ធដារ ដោយលោក **ពៅ បូណា** និង៥.ការធ្វើបទបង្ហាញស្ដីពីគោលការណ៍ស្ដីពីការគ្រប់គ្រងចាត់ចែងចំនួនមន្ត្រី ដោយលោក **ឡូវ សេងហ៊ុន**។

បន្ទាប់ពីការចុះធ្វើទស្សនកិច្ចផ្ទាល់នៅតាមកន្លែងការងារ រួមមាន បញ្ជរផ្ដល់សេវាអ្នកជាប់ពន្ធ និងការិយាល័យធ្វើការដែលមានលក្ខណៈទំនើបប្រកបដោយរបៀបរៀបរយល្អ និងបន្ទាប់ពីបានបញ្ចប់ការធ្វើបទបង្ហាញ និងពិភាក្សាលើរបៀបវារៈទាំងអស់រួចនៅថ្ងៃទី២ ប្រធានគណៈប្រតិភូនៃកំពង់ផែស្វយ័តភ្នំពេញបានសម្ដែងនូវចំណាប់អារម្មណ៍វាយតម្លៃខ្ពស់ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ការផ្ដល់នូវបដិសណ្ឋារកិច្ចដ៏កក់ក្ដៅ ការចែករំលែកបទពិសោធនៃ

ដំណើរដើមទងទាំងស្រុងនៃកម្មវិធីកែទម្រង់ស៊ីជម្រៅមុតស្រួច ជាពិសេសលើផ្នែកធនធានមនុស្ស ព្រមទាំងសមិទ្ធផលជាក់ស្តែង។ លោកជំទាវ បានលើកឡើងទៀតថា ជួសមុខឱ្យគណៈប្រតិភូ និងជាពិសេសគឺក្នុងនាមជាតំណាងរបស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកនៃកំពង់ផែស្វយ័តភ្នំពេញ លោកជំទាវ សូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះសមិទ្ធផលដែលជាស្នាដៃដ៏ល្អថ្លៃថ្លានៃការអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅមុតស្រួចក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះរបស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមការដឹកនាំរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ប្រកបដោយភាពអង់អាចក្លាហាន និងឆន្ទៈមោះមុតឥតរាថយ ដើម្បីកែទម្រង់ផង និងដើម្បីគ្រប់គ្រងការប្រមូលចំណូលពន្ធសម្រាប់ថវិកាជាតិដែលបានកំណត់ដោយច្បាប់។ លោកជំទាវ បានប្តេជ្ញាចិត្តថានឹងនាំ និងរាយការណ៍ជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកនៃកំពង់ផែស្វយ័តភ្នំពេញ ព្រមទាំងថ្នាក់ដឹកនាំទាំងអស់ អំពីលទ្ធផលនៃដំណើរទស្សនកិច្ចសិក្សានេះ ដើម្បីពិនិត្យលទ្ធភាពទទួលយកទៅអនុវត្តជាក់ស្តែងនូវចំណេះដឹង បទពិសោធ និងឧត្តមានុវត្តន៍នៃកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្សរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីអភិវឌ្ឍសមត្ថភាពស្ថាប័ននៃកំពង់ផែស្វយ័តភ្នំពេញ ជាពិសេសផ្នែកគ្រប់គ្រងនិងអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដែលជាសសរស្តម្ភមួយដ៏សំខាន់នៃការអភិវឌ្ឍសមត្ថភាពស្ថាប័ន៕





# សិក្ខាសាលាផ្សព្វផ្សាយស្ដីពី "ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារក្នុងវិស័យអប់រំ"




នាព្រឹកថ្ងៃសុក្រទី១៩ខែកក្កដាឆ្នាំ២០២៤នៅសាលប្រជុំសមាគមសហព័ន្ធសេវាអប់រំនៅកម្ពុជាអគ្គនាយកដ្ឋានពន្ធដារ (អពដ) បានសហការជាមួយសមាគមសហព័ន្ធសេវាអប់រំនៅកម្ពុជា (FESC) រៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី **"ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារក្នុងវិស័យអប់រំ"** ក្រោមអធិបតីភាពលោកបណ្ឌិត **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និងលោកបណ្ឌិត **គង់ សំឡៀង** ប្រធានសមាគម FESC ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញពាក់ព័ន្ធនៃអពដ ថ្នាក់ដឹកនាំនិងសមាជិកនៃសមាគមដែលជាតំណាងក្រុមហ៊ុនចូលរួមដោយផ្ទាល់ និងតាមអនឡាញ (Zoom Meeting) សរុបចំនួន **១៦២ រូប**។

ជាកិច្ចស្វាគមន៍ លោកបណ្ឌិតប្រធានសមាគម FESC បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោកបណ្ឌិតប្រធាននាយកដ្ឋាន និងមន្ត្រីជំនាញពាក់ព័ន្ធនៃអពដ និងក្រុមការងារនៃសមាគម ដែលបានសហការរៀបចំសិក្ខាសាលានេះឡើង ព្រមទាំងអរគុណដល់សមាជិកទាំងអស់ដែលបានចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នាឱកាសនេះ។ លោកបណ្ឌិតបានលើកឡើងថា គោលដៅក្នុងការរៀបចំសិក្ខាសាលានេះឡើង គឺដើម្បីបង្កើនកិច្ចសហការល្អរវាងស្ថាប័នរដ្ឋ និងវិស័យឯកជនលើផ្នែកពន្ធដារ ព្រមទាំងដើម្បីឈ្វេងយល់ឱ្យកាន់តែច្បាស់នូវការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ ការលើកទឹកចិត្តផ្នែកពន្ធដារចំពោះវិស័យអប់រំក្នុងគោលដៅជំរុញការអភិវឌ្ឍធនធានមនុស្ស និងការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈ។ លោកបណ្ឌិត ក៏បានលើកឡើងបន្ថែមដែរថា សមាគមសហព័ន្ធសេវាអប់រំនៅកម្ពុជា គឺជាសមាគមដែលប្រមូលផ្តុំទៅដោយគ្រឹះស្ថានសិក្សាឯកជនកម្រិតមត្តេយ្យដល់ថ្នាក់ទី១២ ដែលមានសមាជិកប្រមាណជាង **១៣០ ស្ថាប័ន** ទូទាំងប្រទេស ហើយសមាគមមានចក្ខុវិស័យចង់ឱ្យធនធានមនុស្សក្នុងប្រទេសកម្ពុជាមានចំណេះដឹង ជំនាញ និងមានភាពជាអ្នកដឹកនាំ។ លោកបណ្ឌិតក៏បានសង្កត់បន្ថែមផងដែរថា សមាគមតែងតែចូលរួមអនុវត្តគោលនយោបាយផ្សេងៗរបស់រាជរដ្ឋាភិបាល រួមទាំងស្ថាប័នរដ្ឋនានា ជាពិសេស អគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលដៅធានាឱ្យបាននូវចីរភាព និងវឌ្ឍនភាពនៃសេដ្ឋកិច្ចនៅប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង។

ជាកិច្ចបន្ទាប់ លោកបណ្ឌិតប្រធាននាយកដ្ឋាន ក៏បានថ្លែងសុន្ទរកថាបើកសិក្ខាសាលានិងបានសម្ដែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅចំពោះវត្តមានចូលរួមរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលបាន

ចូលរួមក្នុងសិក្ខាសាលាដ៏មានសារៈសំខាន់នាព្រឹកនេះ ជាពិសេស លោកបណ្ឌិតប្រធានសមាគម ថ្នាក់ដឹកនាំ និងក្រុមការងារ ដែលបានសហការរៀបចំសិក្ខាសាលានេះឡើង ដោយផ្តោតសំខាន់លើប្រធានបទស្តីពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារក្នុងវិស័យអប់រំ។ លោកបណ្ឌិតបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅកាន់អ្នកជាប់ពន្ធទាំងអស់ ដែលបានចូលរួមសិក្ខាសាលាថ្ងៃនេះ ដែលសបញ្ជាក់ឱ្យឃើញពីការចង់ចេះ ចង់ដឹង និងចង់អនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ។ ជាមួយគ្នានេះ លោកបណ្ឌិតក៏បានបញ្ជាក់បន្ថែមផងដែរថា អពដ ជាអង្គភាពសាធារណៈមួយឈានមុនគេ ក្នុងការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើនដូចជាប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ ប្រព័ន្ធគ្រប់គ្រងការបង់ប្រាក់ពន្ធតាមអនឡាញ និងកម្មវិធីអេឡិចត្រូនិកផ្សេងៗទៀត ដាក់ស្តែងថ្មីៗនេះ អពដក៏បានដាក់ឱ្យប្រើប្រាស់នូវកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) ដែលអ្នកជាប់ពន្ធអាចដាក់លិខិតរដ្ឋបាល លិខិតតវ៉ា ឬលិខិតផ្សេងៗតាមអនឡាញបាន ដែលការកែទម្រង់នេះគឺស្ថិតក្រោមការដឹកនាំប្រកបដោយបញ្ញាវាងវៃ ប៉ុរសេកម្ម និងប៉ិនប្រសប់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ដែលតាមរយៈការផ្តល់សេវាល្អនេះហើយ ដែលអាចឱ្យ អពដ ប្រមូលចំណូលបានលើសផែនការគិតចាប់ពីឆ្នាំ២០១២ រហូតមកដល់បច្ចុប្បន្ននេះ។ ទន្ទឹមនឹងនេះ លោកបណ្ឌិតបានបញ្ជាក់ផងដែរថា សិក្ខាសាលានេះជាផ្នែកមួយនៃយុទ្ធសាស្ត្រស្នូលរបស់ អពដ ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធឱ្យយល់ច្បាស់ពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ព្រោះប្រព័ន្ធពន្ធដារជារបបស្វ័យប្រកាស ដែលអ្នកជាប់ពន្ធត្រូវគណនា បំពេញលិខិតប្រកាស និងបង់ប្រាក់ពន្ធដោយខ្លួនឯង ហើយ អពដ សូមស្វាគមន៍ដល់សមាគមនិងអ្នកជាប់ពន្ធទាំងអស់ ក្នុងការអញ្ជើញឱ្យមន្ត្រីជំនាញនៃអពដ ធ្វើបទបង្ហាញអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ដែលអ្នកជាប់ពន្ធនៅមានភាពមិនច្បាស់លាស់ក្នុងការអនុវត្ត។ ជាចុងក្រោយ លោកបណ្ឌិតបានក្រើនរំលឹកដល់អ្នកជាប់ពន្ធទាំងអស់ថា ការឈ្វេងយល់អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកជាប់ពន្ធ ដើម្បីអាចអនុវត្តឱ្យបានត្រឹមត្រូវ និងចៀសវាងបានពីការអនុវត្តខុសច្បាប់ដែលនាំឱ្យមានការដាក់ទណ្ឌកម្មផ្សេងៗដោយរដ្ឋបាលសារពើពន្ធ ហើយរដ្ឋបាលសារពើពន្ធមិនមានបំណងចង់ដាក់ទណ្ឌកម្មដល់អ្នកជាប់ពន្ធនោះទេ ដូច្នេះហើយទើបខិតខំប្រឹងប្រែងក្នុងការផ្តល់សេវា ឬការប្រឹក្សាយោបល់អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ តាមមធ្យោបាយគ្រប់ប្រភេទ ដោយផ្ទាល់និងតាមអនឡាញជូនដល់អ្នកជាប់ពន្ធជាប្រចាំដោយយកចិត្តទុកដាក់ខ្ពស់និងឥតគិតថ្លៃ៕



## ពិធីសំណេះសំណាល
## ជាមួយក្រុមនិស្សិតជាប់ជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលសាធារណរដ្ឋឆែក




នាព្រឹកថ្ងៃអង្គារ ទី៣០ ខែកក្កដា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ បានរៀបចំពិធីសំណេះសំណាលជាមួយក្រុមនិស្សិត ជាប់ជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលសាធារណរដ្ឋឆែក ចំនួន **១៥ រូប** សម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ ក្រោមអធិបតីភាពឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីលោកអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក លោកអនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ លោកស្រីនាយករងសាលាជាតិពន្ធដារ មន្ត្រីរាជការពន្ធដារពាក់ព័ន្ធ និងក្រុមនិស្សិតជាប់ជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលសាធារណរដ្ឋឆែក។

ជាកិច្ចចាប់ផ្តើម តំណាងនិស្សិតជាប់ជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលសាធារណរដ្ឋឆែកបានសម្តែងគារវកិច្ចចំពោះគណៈអធិបតី ដែលមានវត្តមាននាព្រឹកនេះ។ ទន្ទឹមនឹងនេះដែរ តំណាងនិស្សិតជាប់ជ័យលាភីអាហារូបករណ៍ក៏បានសម្តែងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី សម្រាប់ការចូលជួបសម្តែងការគួរសម និងទទួលយកនូវអនុសាសន៍ណែនាំរបស់ឯកឧត្តម **លីម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋាពន្ធដារ និងបានរាយការណ៍សង្ខេបអំពីការផ្តល់អាហារូបករណ៍របស់រដ្ឋាភិបាលសាធារណរដ្ឋឆែកដល់និស្សិតកម្ពុជា ព្រមទាំងបានធ្វើបទឧទ្ទេសនាមសង្ខេបម្តងម្នាក់ៗអំពីមុខជំនាញផ្ទាល់ខ្លួនដែលត្រូវបន្តការសិក្សា និងសេចក្តីរំពឹងទុកសម្រាប់ជួយអភិវឌ្ឍប្រទេសជាតិ ក្រោយពេលបញ្ចប់ការសិក្សារបស់ខ្លួនជូនអង្គពិធីទាំងមូលផងដែរ។

ជាកិច្ចបន្ទាប់ ក្នុងនាមជាតំណាងរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ឯកឧត្តមអគ្គនាយករងបានសម្តែងនូវការកោតសរសើរ និងចូលរួមអបអរសាទរចំពោះនិស្សិតជាប់ជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលសាធារណរដ្ឋឆែក (Czech Government Scholarship) ទាំង **១៥ រូប** (នារី ៧ រូប និងបុរស ៨ រូប) ដែលជាមន្ត្រីរាជការពីបណ្តាក្រសួង-ស្ថាប័នសាធារណៈ និងជាបុគ្គលិកពីវិស័យឯកជននិងអង្គការក្រៅរដ្ឋាភិបាល។ ឯកឧត្តមអគ្គនាយករង ក៏បានលើកឡើងថា ពិធីសំណេះសំណាលបែបនេះ គឺជាឱកាសច្រើនលើកច្រើនសារបស់ឯកឧត្តម ដែលត្រូវបានចាត់តាំង

ដើម្បីជួបជាមួយក្រុមនិស្សិតជាប់ជ័យលាភី និងផ្តល់អនុសាសន៍ណែនាំមុនពេលចេញដំណើរទៅបន្តការសិក្សានៅក្រៅប្រទេសដូចជា ប្រទេសជប៉ុន អូស្ត្រាលី និងនូវែលសេឡង់ ជាដើម។ ជាមួយគ្នានេះដែរ ឯកឧត្តមអគ្គនាយករង បានពញ្ញាក់ស្មារតីដល់ក្រុមនិស្សិតអំពីសារៈសំខាន់នៃការទទួលជ័យលាភីអាហារូបករណ៍ទៅបន្តការសិក្សានៅសាធារណរដ្ឋឆែក គឺពិតជាឯកសិទ្ធិមួយដ៏ឧត្តុង្គឧត្តម (A Great Privilege) របស់និស្សិតជាប់ជ័យលាភីអាហារូបករណ៍ទាំងអស់គ្នា។ ឯកឧត្តមអគ្គនាយករង បានធ្វើការពន្យល់ត្រួសៗអំពីអត្ថន័យខ្លឹមសារនៃអ្វីដែលហៅថា ឯកសិទ្ធិ (Privilege) នេះ តាមរយៈការបញ្ជាក់ថា ឯកសិទ្ធិ គឺជាការទទួលបាននូវឱកាស ឬអំណោយពិសេសណាមួយពីអ្នកផ្តល់ជូន ដែលគេមានបំណងដាក់លាក់ច្បាស់លាស់ឱ្យអ្នកទទួលឯកសិទ្ធិនោះយកទៅប្រើប្រាស់ឱ្យបានសមស្របសម្រាប់បម្រើផលប្រយោជន៍រួម។ ត្រង់ចំណុចនេះ ឯកឧត្តមអគ្គនាយករង បានបញ្ជាក់ថា ឯកសិទ្ធិ គឺជាការផ្តល់ជូន ឬជាអំណោយពិសេសដែលអ្នកទទួលបានឯកសិទ្ធិនេះត្រូវតែមានការដឹងគុណ (Gratitude) ដល់ប្រភពដែលនាំឱ្យមានការផ្តល់ជូននូវឯកសិទ្ធិនេះ។ ពាក់ព័ន្ធនឹងចំណុចនេះ ឯកឧត្តមអគ្គនាយករង បានផ្តែផ្តាំឱ្យក្រុមនិស្សិតជាប់ជ័យលាភីទាំងអស់ត្រូវចេះដឹងគុណតាមរយៈការប្រើប្រាស់ឯកសិទ្ធិនេះឱ្យបានល្អប្រសើរ ដើម្បីផលប្រយោជន៍ខ្លួនឯង គ្រួសារ និងប្រទេសជាតិយើងស្របតាមគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជាយើង ក៏ដូចជារដ្ឋាភិបាលសាធារណរដ្ឋឆែក ដែលជាប្រភពនៃការផ្តល់ឯកសិទ្ធិនេះ។ ក្រៅពីនេះ ឯកឧត្តមអគ្គនាយករងបានចែករំលែកនូវគតិបណ្ឌិតជាច្រើន ដើម្បីផ្តល់ជូនក្រុមនិស្សិតជាប់ជ័យលាភីទាំងអស់ជាជំនួយស្មារតីសម្រាប់យកទៅគិតពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ ក្នុងដំណើរការសិក្សានៅទីនោះឱ្យបានជោគជ័យ និងពាំនាំយកនូវចំណេះដឹង និងបទពិសោធល្អៗត្រឡប់មកបម្រើផលប្រយោជន៍ប្រទេសជាតិយើងឱ្យបានរីកចម្រើនរុងរឿងតរៀងទៅមុខទៀត។

បន្ថែមពីលើនេះ ក្នុងនាមជាតំណាងរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ឯកឧត្តមអគ្គនាយករង បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលសាធារណរដ្ឋឆែក ដែលតែងតែផ្តល់ការយកចិត្តទុកដាក់ខ្ពស់ជាប្រចាំជាច្រើនឆ្នាំកន្លងមកនេះ ក្នុងការជួយជ្រោមជ្រែងនិងផ្តល់ការគាំទ្រចំពោះកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរបស់ប្រទេសកម្ពុជាតាមរយៈការផ្តល់ជាអាហារូបករណ៍ជូនដល់ប្រជាពលរដ្ឋកម្ពុជាឱ្យបន្តការសិក្សាថ្នាក់អនុបណ្ឌិត និងបណ្ឌិតនៅតាមបណ្តាសាកលវិទ្យាល័យនានាក្នុងសាធារណរដ្ឋឆែកលើមុខជំនាញចាំបាច់និងសំខាន់ៗជាច្រើន ដែលជាមូលដ្ឋានគ្រឹះសម្រាប់អភិវឌ្ឍន៍ប្រទេសជាតិ។

ឯកឧត្តមអគ្គនាយករង ក៏បានធ្វើបទបង្ហាញត្រួសៗជូនក្រុមនិស្សិតជាប់ជ័យលាភីអំពីសាវតានៃអគ្គនាយកដ្ឋានពន្ធដារ យុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ដំណើរវិវត្តនៃរដ្ឋបាលសារពើពន្ធ អភិក្រមការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានពន្ធដារ ការធ្វើបរិវត្តកម្មនៃអគ្គនាយកដ្ឋានពន្ធដារក្លាយជារដ្ឋបាលសារពើពន្ធទំនើបទាន់សម័យមកដល់ពេលបច្ចុប្បន្ន និងជាពិសេសគឺការសម្រេចបានលទ្ធផលកំណើនចំណូលពន្ធជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំក្នុងរយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ សម្រាប់ដាក់ចូលថវិកាជាតិ ដើម្បីជាប្រយោជន៍ដល់ការបន្តអភិវឌ្ឍន៍ប្រទេសជាតិយើងជានិរន្តរ៍។ ឯកឧត្តមអគ្គនាយករង បានគូសបញ្ជាក់បន្ថែមជូនក្រុមនិស្សិតជាប់ជ័យលាភីថា កត្តាគន្លឹះសំខាន់ៗដែលជាមូលដ្ឋានគ្រឹះនាំឱ្យឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីសម្រេចបានជោគជ័យក្នុងការដឹកនាំអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់អគ្គនាយកដ្ឋានពន្ធដារស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាបន្តបន្ទាប់កន្លងមកនេះ គឺការប្រកាន់ជំហរប្រសិទ្ធភាពនៃការដឹកនាំ និងគ្រប់គ្រងអង្គភាព (Effective Leadership and Management) អភិក្រមការងារសំខាន់ៗរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលកម្ពុជា និងគោលការណ៍ដែលជាឧត្តមានុវត្តន៍អន្តរជាតិស្តីពីអភិបាលកិច្ចនិងរដ្ឋបាលកិច្ចល្អ និងគុណាធិបតេយ្យជាដើម ជាពិសេស អភិក្រមសំខាន់ៗទាំងប្រាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** គឺ **"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់"** និងប្រកាន់ជំហរនៃភាពហ្មត់ចត់ ដូច

ទ្រឹស្តីរបស់សម្តេចដែលមានប្រសាសន៍ថា "**ទម្លាប់ហ្មត់ចត់លើកិច្ចការតូចតាច ទើបអាចមានឱកាសទទួលកិច្ចការធំបាន**"។ ជាការឆ្លើយតប ក្រុមនិស្សិតជាប់ជ័យលាភីទាំងអស់បានសម្តែងនូវការកោតសរសើរចំពោះសមិទ្ធផលជោគជ័យ នៃការកែទម្រង់ស៊ីជម្រៅមុតស្រួចរបស់អគ្គនាយកដ្ឋានពន្ធដារកន្លងមក ក្រោមការដឹកនាំរបស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងបានបង្ហាញនូវចំណាប់អារម្មណ៍ខ្លាំងចំពោះការចែករំលែកចំណេះដឹង និងបទពិសោធបន្ថែមរបស់ឯកឧត្តមអគ្គនាយករង ដែលជាជំនួយស្មារតីសម្រាប់យកទៅគិតពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការសិក្សានៅទីនោះ និងសម្រាប់អនុវត្តនៅក្នុងជីវិតឱ្យបានជោគជ័យ ដើម្បីបម្រើផលប្រយោជន៍ប្រទេសជាតិយើងឱ្យបានរីកចម្រើន រុងរឿងបន្ថែមទៀត៕



*ឯកឧត្តម **លឹម ហ៊ុយជីវ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



*លោកស្រី **ឆាយ៉ា ធព័ណ្ណ***
*នាយករង សាលាជាតិពន្ធដារ*



*លោក **ឆាយ ជាហេង***
*អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ*



*លោក **លាន សំអាង** អនុប្រធានការិយាល័យ*
*នៃសាលាជាតិពន្ធដារ*



*លោក **ពៅ ប៊ូណា** ប្រធានការិយាល័យ*
*នាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក នៃអគ្គនាយកដ្ឋានពន្ធដារ*

# ២. កិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័ន

## កិច្ចប្រជុំជំនួបពិភាក្សាការងារជាមួយក្រុមបេសកជន នៃមូលនិធិរូបិយវត្ថុអន្តរជាតិ (The 2024 Article IV Consultation)



នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៩ ខែកញ្ញា ឆ្នាំ២០២៤ នៅអគ្គនាយកដ្ឋានពន្ធដារ លោកជំទាវ **ម៉ុន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជ-រដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ (អពដ) អមដោយលោក **សេខ ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ (ន.នគសអ) បានទទួលជួបពិភាក្សាការងារប្រចាំឆ្នាំ២០២៤ (The 2024 Article IV Consultation) ជាមួយក្រុមបេសកជននៃមូលនិធិរូបិយវត្ថុអន្តរជាតិ (International Monetary Fund – IMF) ដឹកនាំដោយលោក Kenichiro Kashiwase ប្រធានក្រុមបេសកជន IMF ទទួលបន្ទុកប្រទេសកម្ពុជា និងសេដ្ឋវិទូជាន់ខ្ពស់របស់ក្រុមបេសកជន IMF ព្រមទាំងមានវត្តមានចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើម លោកជំទាវអគ្គនាយករងបានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់លោក លោកស្រី នៃក្រុមបេសកជន IMF សម្រាប់ការអញ្ជើញមកបំពេញបេសកកម្មការងារនៅអគ្គនាយកដ្ឋានពន្ធដារ ហើយបន្ថែមពីលើនេះ លោកជំទាវអគ្គនាយករង បានគូសបញ្ជាក់អំពីកិច្ចសហប្រតិបត្តិការដ៏ល្អរវាងអគ្គនាយកដ្ឋានពន្ធដារ និងមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលតែងតែជួបប្រជុំពិភាក្សាជាប្រចាំ ដើម្បីពិភាក្សាអំពីការវិវត្តនៃទស្សនវិស័យម៉ាក្រូសេដ្ឋកិច្ច ស្ថានភាពនៃកិច្ចការប្រមូលចំណូលពន្ធ និងគោលនយោបាយនានាពាក់ព័ន្ធនឹងពន្ធដារ ក៏ដូចជាការផ្តល់នូវអនុសាសន៍ល្អៗនាពេលកន្លងមក។

ជាកិច្ចឆ្លើយតប លោកប្រធានក្រុមបេសកជន IMF បានសម្តែងនូវការអរគុណដល់អគ្គនាយកដ្ឋានពន្ធដារ ដែលបានចំណាយ ពេលវេលាជួបប្រជុំពិភាក្សាការងារជាមួយក្រុមបេសកជន IMF ហើយបានសាទរចំពោះលទ្ធផលល្អប្រសើរនៃកិច្ចការងារកែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងគោលដៅធានាដល់ការប្រមូលចំណូលពន្ធសម្រាប់រាជរដ្ឋាភិបាល ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវបរិយាកាសធុរកិច្ចនៅកម្ពុជា។

ជាកិច្ចបន្ត លោកជំទាវអគ្គនាយករងបានអនុញ្ញាតឱ្យលោក **ខាន់ បញ្ញាឫទ្ធិ** អនុប្រធានការិយាល័យគោលនយោបាយសារពើពន្ធនៃន.នគសអនៃអគ្គនាយកដ្ឋានពន្ធដារធ្វើបទបង្ហាញជូនដល់អង្គប្រជុំដោយផ្តោតលើប្រធានបទសំខាន់ៗ ដូចខាងក្រោម៖

- ការគ្រប់គ្រងប្រមូលចំណូលពន្ធដារសម្រាប់ឆ្នាំ២០២៤ និងទស្សនវិស័យសម្រាប់ឆ្នាំ២០២៥
- វិធានការ និងគោលនយោបាយពន្ធដារថ្មីៗ និងសម្រាប់រយៈពេលមធ្យម
- ការធ្វើសវនកម្មពន្ធដារលើសហគ្រាសធុនធំ និងមធ្យម ព្រមទាំងវិធានការពង្រឹងអនុលោមភាពសារពើពន្ធ
- ស្ថានភាពនៃការលើកទឹកចិត្តផ្នែកពន្ធដារ
- យុទ្ធសាស្ត្រ និងវិធានការពន្ធដារសម្រាប់រយៈពេលមធ្យម។

ក្រោយការធ្វើបទបង្ហាញ អង្គប្រជុំបានបន្តពិភាក្សាលើចំណុចមួយចំនួន ដូចជា ការរៀបចំកត់ត្រាទិន្នន័យទាក់ទិននឹងបន្ទុកសារពើពន្ធ (Tax Expenditure) ស្ថានភាពនៃការលើកទឹកចិត្តផ្នែកពន្ធដារថ្មីៗ និងវឌ្ឍនភាពនៃការរៀបចំយុទ្ធសាស្ត្រកៀរគរចំណូល ២០២៤-២០២៨ របស់រាជរដ្ឋាភិបាលជាដើម។ បន្ថែមពីលើនេះ ក្រុមការងារ អពដ បានបន្តលើកឡើងអំពីកិច្ចខិតខំប្រឹងប្រែងរបស់អគ្គនាយកដ្ឋានពន្ធដារក្នុងការពង្រឹងអនុលោមភាពសារពើពន្ធ ដើម្បីបង្កើតឱ្យមាននូវការប្រកួតប្រជែងស្មើភាពសម្រាប់សហគ្រាសទាំងអស់ ក៏ដូចជាបង្កើនការទាក់ទាញការវិនិយោគមកកាន់កម្ពុជា ដែលក្នុងន័យនេះ អពដ បានត្រៀមខ្លួនរួចជាស្រេចក្នុងការបន្តធ្វើកំណែទម្រង់ និងពង្រឹងរដ្ឋបាលសារពើពន្ធដោយបានរៀបចំរួចរាល់នូវផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ របស់ខ្លួន ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាល ទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា ដែលការធ្វើកំណែទម្រង់និងពង្រឹងអភិបាលកិច្ចគឺជាស្នូលសំខាន់។

ជាចុងក្រោយ លោកប្រធានក្រុមបេសកជន IMF បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រុមការងាររបស់ អពដ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការទទួលជួបប្រជុំពិភាក្សា ផ្តល់នូវព័ត៌មានលម្អិត និងបកស្រាយប្រកបដោយភាពច្បាស់លាស់។ ជាកិច្ចបញ្ចប់ លោកជំទាវអគ្គនាយករងបានធ្វើការវាយតម្លៃខ្ពស់ចំពោះកិច្ចប្រជុំពិភាក្សានេះ ព្រមទាំងបានជូនពរក្រុមបេសកជន IMF ទទួលបាននូវភាពជោគជ័យសម្រាប់ការបំពេញបេសកកម្មការងារនៅក្នុងព្រះរាជាណាចក្រកម្ពុជា៕



# ៣. កិច្ចសហប្រតិបត្តិការជាមួយវិស័យឯកជន អង្គការ សមាគម និងស្ថាប័នអន្តរជាតិ

## ឯកឧត្តម គង់ វិបុល អញ្ជើញចូលរួម ក្នុងកម្មវិធី Vertiv Asia Channel Summit 2024 ដើម្បីសិក្សាស្វែងយល់ និងផ្លាស់ប្តូរបទពិសោធពីដំណើរបរិវត្តកម្មឌីជីថល




នាព្រឹកថ្ងៃអង្គារ ទី២ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារ សូហ្វីតែល អង្គរ ភូគីត្រា ហ្គោហ្វ & ស្ប៉ារីហ្សត ខេត្តសៀមរាប ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានអញ្ជើញចូលរួមក្នុងកម្មវិធី Vertiv Asia Channel Summit 2024 អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ។ កម្មវិធីនេះរៀបចំឡើងក្នុងគោលបំណងផ្លាស់ប្តូរ និងចែករំលែកបទពិសោធថ្មីៗពាក់ព័ន្ធនឹងការធ្វើទំនើបកម្ម និងសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានទៅវិញទៅមក ទាំងនៅអគ្គនាយកដ្ឋានពន្ធដារ និងក្រុមហ៊ុនអន្តរជាតិធំៗពាក់ព័ន្ធក្នុងឧស្សាហកម្មបច្ចេកវិទ្យា។

ក្នុងកម្មវិធីនេះផងដែរ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ក៏បានចែករំលែកបទពិសោធនៃការធ្វើកំណែទម្រង់របស់អគ្គនាយកដ្ឋានពន្ធដារចាប់ផ្តើមពីរដ្ឋបាលសារពើពន្ធដែលផ្តល់សេវាអ្នកជាប់ពន្ធដោយប្រើប្រាស់កម្លាំងពលកម្ម ឬសកម្មភាពផ្ទាល់របស់មន្ត្រី និងប្រើប្រាស់ក្រដាសស្នាមច្រើន ចំណាយពេលវេលាច្រើន និងមានហានិភ័យខ្ពស់លើការគ្រប់គ្រងទិន្នន័យទាំងសម្រាប់មន្ត្រីរាជការពន្ធដារ ក៏ដូចជាអ្នកជាប់ពន្ធតាមរយៈការរៀបចំលិខិតប្រកាសសារពើពន្ធដោយដៃ។ ចាប់តាំងពីឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារ បានខិតខំប្រឹងប្រែងធ្វើកំណែទម្រង់ និងបរិវត្តកម្មរដ្ឋបាលសារពើពន្ធ ( Tax Digital Transformation ) ស្របតាមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងយុទ្ធសាស្ត្រកៀរគរចំណូលនៅគ្រប់ដំណាក់កាល ជាពិសេស គឺការសិក្សាដកស្រង់បទពិសោធល្អៗពីរដ្ឋបាលសារពើពន្ធនៃបណ្តាប្រទេសអភិវឌ្ឍន៍ ក៏ដូចជាក្រុមហ៊ុនពាក់ព័ន្ធក្នុងវិស័យបច្ចេកវិទ្យាមួយចំនួន។

ក្នុងឱកាសនេះផងដែរ អគ្គនាយកដ្ឋានពន្ធដារក៏នឹងទទួលបានចំណេះដឹងនិងបទពិសោធថ្មីៗបន្ថែមទៀត ពីកម្មវិធី Vertiv Asia Channel Summit 2024 ដើម្បីបន្តកែទម្រង់និងបរិវត្តកម្មរដ្ឋបាលសារពើពន្ធ ឱ្យស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ដែលបានដាក់ចេញឱ្យអនុវត្តដោយរាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**។ ក្នុងចំណោម

គោលដៅយុទ្ធសាស្ត្រសំខាន់ៗនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ គឺក្លាយជារាជរដ្ឋាភិបាលឌីជីថលនៅឆ្នាំ២០៣៥ ដោយគ្រប់ស្ថាប័នរដ្ឋទាំងអស់ត្រូវតែជាស្ថាប័នឌីជីថល។ សម្រាប់អគ្គនាយកដ្ឋានពន្ធដារ និន្នាការនេះគឺស្របតាមគោលដៅយុទ្ធសាស្ត្ររួមរបស់រដ្ឋបាលសារពើពន្ធក្នុងតំបន់ និងពិភពលោកស្តីពីការធ្វើបរិវត្តកម្ម រដ្ឋបាលសារពើពន្ធជំនាន់ទី៣.០ (Tax Administration 3.0) ហើយដែលគោលបំណងចម្បងៗ នៅក្នុងផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ ២០២៤-២០២៨ គឺ៖ ១.បង្កើនអនុលោមភាពសារពើពន្ធ តាមរយៈការលើកកម្ពស់គុណភាព ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាព ក្នុងការផ្តល់សេវានិងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ២.បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក និង៣.បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ។ ជារួម គោលបំណងទាំង៣ចំណុចខាងលើ គឺផ្តោតទៅលើការធ្វើបរិវត្តកម្មអគ្គនាយកដ្ឋានពន្ធដារឱ្យទៅជារដ្ឋបាលសារពើពន្ធឌីជីថល ឬរដ្ឋបាលសារពើពន្ធជំនាន់ទី២.០ បូក ដើម្បីបង្កើនសមត្ថភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពក្នុងការគ្រប់គ្រងការប្រមូលចំណូលពន្ធប្រកបដោយនិរន្តរភាព។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គឺជាមុខងារគាំទ្រដ៏សំខាន់មួយនៅក្នុងផែនការយុទ្ធសាស្ត្ររបស់អគ្គនាយកដ្ឋានពន្ធដារ៕




*ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ*



# វេទិកាចូលរួមវេទិកាកិច្ចសហប្រតិបត្តិការរដ្ឋបាលសារពើពន្ធ នៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ លើកទី៥ (The 5th Belt and Road Initiative Tax Administration Cooperation Forum-BRITACOF)




នាថ្ងៃទី២៤-២៦ ខែកញ្ញា ឆ្នាំ២០២៤ លោកបណ្ឌិត **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ (ន.នគសអ) នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អមដោយលោក **បាន ឌី វិទូ** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន និងថ្នាក់ដឹកនាំមកពី ន.នគសអ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បានចូលរួមវេទិកាកិច្ចសហប្រតិបត្តិការរដ្ឋបាលសារពើពន្ធនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់និងផ្លូវ លើកទី៥ (The 5th Belt and Road Initiative Tax Administration Cooperation Forum-BRITACOF) នៃយន្តការនៃគំនិតផ្តួចផ្តើមខ្សែក្រវាត់ និងផ្លូវសម្រាប់កិច្ចសហប្រតិបត្តិការពន្ធដារ (Belt and Road Initiative Tax Administration Cooperation Mechanism-BRITACOM) នៅតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន (Hong Kong Special Administration Region of the People's Republic of China) ក្រោមប្រធានបទ "ការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែករដ្ឋបាលពន្ធដារសម្រាប់ការអភិវឌ្ឍខ្សែក្រវាត់ និងផ្លូវដែលមានគុណភាពខ្ពស់ (Deepening Tax Administration Cooperation for High-Quality Belt and Road Development)"។ វេទិកា BRITACOF លើកទី៥ នេះ បានសហការរៀបចំដោយនាយកដ្ឋានចំណូលក្នុងស្រុកតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន (Inland Revenue Department-IRD) ក្នុងនាមជាម្ចាស់ផ្ទះ និងលេខាធិការដ្ឋាន BRITACOM ព្រមទាំងមានការចូលរួមពីតំណាងយុត្តាធិការជាសមាជិក BRITACOM ប្រមាណជា ៣០ រដ្ឋបាលសារពើពន្ធ, អ្នកអង្កេតការណ៍, និងអង្គការអន្តរជាតិជាច្រើន ដែលមានចំនួនសរុបប្រមាណ **៤០០ រូប**។ ឯកឧត្តម **John KC Lee** នាយកប្រតិបត្តិតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន ក៏បានផ្តល់កិត្តិយសចូលរួមក្នុងពិធីបើកវេទិកា BRITACOF លើកទី៥ នេះផងដែរ។

វេទិកា BRITACOF លើកទី៥ នេះ មានគោលបំណងបង្កើតនូវវេទិកាសម្រាប់ប្រាស្រ័យទាក់ទងមួយ ដើម្បីដោះស្រាយបញ្ហាប្រឈមនានាក្នុងវិស័យពន្ធដារ ចែករំលែកឧត្តមានុវត្តន៍សំខាន់ៗ និងបង្ហាញអំពីវឌ្ឍនភាពការងាររបស់ភាគីពាក់ព័ន្ធទាំងអស់នៃ BRITACOM ដែលបានសម្រេចតាមបេសកកម្មដែលបានដាក់ចេញក្នុងផែនការសកម្មភាព Nur-Sultan (2022-2024) ដោយផ្តោតលើភាពប្រាកដប្រជានៃពន្ធ (tax certainty), ឌីជីថលូបនីយកម្មរដ្ឋបាលសារពើពន្ធ (tax administration digitalization), បរិយាកាសពន្ធ (tax environment), ការកសាងសមត្ថភាព (capacity building)។ល។

កិច្ចប្រជុំបានចាប់ផ្តើមដោយការរាយការណ៍ដោយសង្ខេបអំពីវឌ្ឍនភាពការងាររបស់ BRITACOM ដោយឯកឧត្តម **Wang Daoshu** ប្រធានលេខាធិការដ្ឋាននិងជាស្នងការរងនៃរដ្ឋបាលសារពើពន្ធចិន ដូចជា៖ ការរៀបចំសិក្ខាសាលា, ការរៀបចំដំណើរទស្សនកិច្ចរបស់សមាជិក BRITACOM ដោយលេខាធិការដ្ឋាន BRITACOM, ការរៀបចំប្រព័ន្ធកម្មវិធីសិក្សា (Curriculum System) សម្រាប់ក្រុមពង្រឹងសមត្ថភាពរដ្ឋបាលសារពើពន្ធនៃគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់និងផ្លូវ (Belt and Road Initiative Tax Administration Capacity Enhancement Group-BRITACEG), ការបង្កើតបណ្ឌិតសភាពន្ធ BRITACEG (Tax Academies), និងការបោះផ្សាយទិនានុប្បវត្តិស្តីពីពន្ធ ក្នុងក្របខ័ណ្ឌ BRITACOM ។ល។ និងលទ្ធផលការសម្រេចបានដោយក្រុមការងារ (Task Force) នីមួយៗនៃ BRITACOM ផងដែរ។

ចូលរួមក្នុងកិច្ចពិភាក្សា ក៏ដូចជាបង្ហាញនូវលទ្ធផលការងារសម្រេចបាន លោកបណ្ឌិត **សេខ ជាសិទ្ធ** ក្នុងនាមអគ្គនាយកដ្ឋានពន្ធដារដែលជាប្រធានក្រុមការងារ បានធ្វើបទបង្ហាញនិងរាយការណ៍ជូនអង្គសិក្ខាសាលាអំពីលទ្ធផលសំខាន់ៗដែលសម្រេចបានដោយក្រុមការងារ Improving Tax Environment រួមមាន៖ លទ្ធផលពីការវិភាគលើកម្រងសំណួរដែលទទួលបាន, ការធ្វើកំណែទម្រង់ទាក់ទិននឹងច្បាប់និងបទប្បញ្ញត្តិ ការផ្តល់សេវានិងនីតិវិធី។ល។ និងការផ្តល់អនុសាសន៍សម្រាប់ជំណាក់កាលបន្ទាប់ជូនរដ្ឋបាលសារពើពន្ធនៃសមាជិកទាំងអស់ព្រមទាំងអង្គវេទិកា។ សម្រាប់អគ្គនាយកដ្ឋានពន្ធដារ ក្នុងនាមជាប្រធានក្រុមការងារនេះ រួមទាំងរដ្ឋបាលសារពើពន្ធដែលជាប្រធានក្រុមការងារ ៣ ផ្សេងទៀតក៏ត្រូវបានប្រគល់រង្វាន់ជាផ្លាក "Commemorative Plaque" សម្រាប់ជាការរំលឹកអំពីភាពជោគជ័យ ក្នុងការដឹកនាំក្រុមការងារទាំង ៤ ដោយជោគជ័យផងដែរ។

ជាកិច្ចបញ្ចប់ អង្គវេទិកាបានសម្រេចដាក់ចេញនូវសេចក្តីថ្លែងការណ៍រួម (Joint Statement) នៃវេទិកា BRITACOF លើកទី៥, ផ្តល់ការអនុម័តលើរបាយការណ៍ប្រចាំឆ្នាំរបស់ BRITACOM និងរបាយការណ៍លទ្ធផលរបស់ក្រុមការងារទាំង ៤ នៃផែនការសកម្មភាព Nur-Sultan (2022-2024) និងបានដាក់ចេញផែនការសកម្មភាព Hong Kong (2025- 2027) សម្រាប់បន្តវឌ្ឍនភាពជាវិជ្ជមានរបស់ BRITACOM ទៅមុខបន្ថែមទៀត។ វេទិកា BRITACOF លើកទី៥ នេះ បានបញ្ចប់ប្រកបដោយលទ្ធផលផ្លែផ្កាជាមួយនឹងការទទួលបានជាគំនិតច្នៃប្រឌិតថ្មីៗ, បទពិសោធ និងឧត្តមានុវត្តន៍សំខាន់ៗ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការសិក្សា ឈ្វេងយល់ និងបង្កើនសមត្ថភាពរដ្ឋបាលសារពើពន្ធឱ្យកាន់តែប្រសើរឡើង៕

# ផ្នែកទី៥

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

១. កិច្ចការបណ្ដុះបណ្ដាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

២. ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

៣. សិក្ខាសាលាសំខាន់ៗ

# ការផ្សព្វផ្សាយ និងបញ្ជ្រាបវប្បធម៌បង់ពន្ធ

ក្នុងគោលដៅពង្រឹងការយល់ដឹងអំពីពន្ធដារ ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ការធ្វើទំនើបកម្មពន្ធដារ និងវឌ្ឍនភាពថ្មីៗ ជាពិសេសពាក់ព័ន្ធការផ្តល់សេវាអ្នកជាប់ពន្ធ ក្នុងខែកញ្ញា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **១០៥ លើក** មានសិក្ខាកាមចូលរួមចំនួន **៩ ៤៤៣ រូប** ក្នុងនោះ វគ្គបណ្តុះបណ្តាលចំនួន **៧៨ លើក** មានសិក្ខាកាមចូលរួមចំនួន **៧ ៣៤៨ រូប** និងសិក្ខាសាលាចំនួន **២៧ លើក** មានសិក្ខាកាមចូលរួមចំនួន **២ ០៩៥ រូប**។

សរុបរយៈពេល ៩ខែដើមឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយនិងវគ្គបណ្តុះបណ្តាលចំនួន **៦៥០ លើក** មានសិក្ខាកាមចូលរួមចំនួន **៨២ ២៨៩ រូប** ក្នុងនោះវគ្គបណ្តុះបណ្តាលចំនួន **២៧៧ លើក** មានសិក្ខាកាមចូលរួមចំនួន **៤៤ ៧៦៩ រូប** និងសិក្ខាសាលាចំនួន **៣៧៣ លើក** មានសិក្ខាកាមចូលរួមចំនួន **៣៧ ៥២០ រូប**៕

**របាយការណ៍ ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា ក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤**

| បរិយាយ | ចំនួនដង ក្នុងខែកក្កដា | ចំនួនសិក្ខាកាម ក្នុងខែកក្កដា | ចំនួនដង ក្នុងខែសីហា | ចំនួនសិក្ខាកាម ក្នុងខែសីហា | ចំនួនដង ក្នុងខែកញ្ញា | ចំនួនសិក្ខាកាម ក្នុងខែកញ្ញា | ចំនួនដង រយៈពេល៩ខែ | ចំនួនសិក្ខាកាម រយៈពេល៩ខែ |
|---|---|---|---|---|---|---|---|---|
| **I.សិក្ខាសាលា** | | | | | | | | |
| អ្នកជាប់ពន្ធ | ៣៥ | ៤ ៩១៥ | ២៧ | ១ ៦១៤ | ២៣ | ១ ៦៣៣ | ២៧៥ | ២៥ ៣០៥ |
| មន្ត្រីរាជការពន្ធដារ | ០០ | ០០ | ០៣ | ៦២៤ | ០១ | ២៦៤ | ៦៣ | ៩ ០៥៧ |
| សិស្ស-និស្សិត | ០០ | ០០ | ០២ | ៤១៧ | ០០ | ០០ | ០៣ | ៦១៧ |
| សាធារណជន | ០០ | ០០ | ០៥ | ៣៦២ | ០៣ | ១៩៨ | ៣២ | ២ ៥៤១ |
| មន្ត្រីធនាគារដៃគូ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ | ០០ |
| **សរុបសិក្ខាសាលា** | **៣៥** | **៤ ៩១៥** | **៣៧** | **៣ ០១៧** | **២៧** | **២ ០៩៥** | **៣៧៣** | **៣៧ ៥២០** |
| **II.វគ្គបណ្តុះបណ្តាល** | | | | | | | | |
| មន្ត្រីធនាគារដៃគូ | ០៥ | ២០០ | ០៩ | ៧៩៣ | ០៥ | ១ ៧៧១ | ៤៣ | ១១ ៧៦៤ |
| មន្ត្រីរាជការពន្ធដារ | ២៩ | ៣ ០៤៤ | ២៨ | ៤ ៣៥០ | ៧២ | ៥ ៤៦៦ | ២៣១ | ៣២ ៥៨៨ |
| អ្នកជាប់ពន្ធ | ០២ | ៣០៦ | ០០ | ០០ | ០១ | ១១១ | ០៣ | ៤១៧ |
| **សរុបវគ្គបណ្តុះបណ្តាល** | **៣៦** | **៣ ៥៥០** | **៣៧** | **៥ ១៤៣** | **៧៨** | **៧ ៣៤៨** | **២៧៧** | **៤៤ ៧៦៩** |
| **សរុបរួម** (I+II) | **៧១** | **៨ ៤៦៥** | **៧៤** | **៨ ១៦០** | **១០៥** | **៩ ៤៤៣** | **៦៥០** | **៨២ ២៨៩** |





# ១.កិច្ចការបណ្តុះបណ្តាល និងសិក្ខាសាលារបស់សាលាជាតិពន្ធដារ

## វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ

ក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ នេះ សាលាជាតិពន្ធដារនៃអគ្គនាយកដ្ឋានពន្ធដារ បានបន្តបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារជំនាន់ទី១៨ ជូនសិក្ខាកាមដែលបានចុះឈ្មោះចូលរៀន ចំនួន **៤៣ ក្រុម** សរុបចំនួន **៩០៧ នាក់**៕



## វគ្គបណ្តុះបណ្តាលខ្លីៗសម្រាប់អ្នកជាប់ពន្ធ និងសាធារណជនទូទៅ

ស្របតាមផែនការប្រតិបត្តិឆ្នាំ២០២៤ របស់សាលាជាតិពន្ធដារ នៅក្នុងត្រីមាសទី៣ នេះ សាលាជាតិពន្ធដារបានបន្តបើកវគ្គបណ្តុះបណ្តាលខ្លីៗ ស្តីពីកាតព្វកិច្ចសារពើពន្ធរបស់សហគ្រាសប្រកបអាជីវកម្មផ្គត់ផ្គង់អគ្គិសនី សរុបចំនួន **១ ក្រុម** ដែលមានសិក្ខាកាមចុះឈ្មោះសិក្សាចំនួន **៤៧ នាក់**៕



## សិក្ខាសាលាជូនភ្នាក់ងារសេវាកម្មពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជនទូទៅ




ក្នុងត្រីមាសទី៣ នេះ សាលាជាតិពន្ធដារបានរៀបចំសិក្ខាសាលាដោយផ្ទាល់ ក្រោមប្រធានបទ "**សៀវភៅណែនាំ ស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ**" និង "**សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ**" ជូនភ្នាក់ងារសេវាកម្មពន្ធដារ ចំនួន **២ លើក** ដែលមានអ្នកចូលរួមសរុបចំនួន **២៨៩ រូប** ក្រោមអធិបតីភាពឯកឧត្តម **លឹម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការពន្ធដារផងដែរ និងបានរៀបចំសិក្ខាសាលាជូនភ្នាក់ងារសេវាកម្មពន្ធដារតាមអនឡាញ ចំនួន **៥ លើក** មានដូចជា៖ ១.កម្មវិធីលិខិតរដ្ឋបាលអេឡិចត្រូនិក ២.ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ៣.ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ ៤.ការផ្ទេរថ្លៃ ៥.ពន្ធលើប្រាក់ចំណូល ដែលមានសិក្ខាកាមចូលរួមចំនួន **៦០៨ រូប** ក្រោមការដឹកនាំរបស់លោក **នាក់ ឌីម** ប្រធានការិយាល័យបណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃសាលាជាតិពន្ធដារ ហើយក៏បានរៀបចំសិក្ខាសាលាជូននិស្សិតតាមគ្រឹះស្ថានឧត្តមសិក្សាតាមអនឡាញនិងផ្ទាល់ ក្រោមប្រធានបទ អត្ថប្រយោជន៍នៃពន្ធ ប្រព័ន្ធពន្ធដារកម្ពុជា និងកម្មវិធីវិក្កយបត្រនាំសំណាង ចំនួន **៤ លើក** មាន សិក្ខាកាមចូលរួមចំនួន **៤០៦ រូប** ក្រោមការដឹកនាំរបស់លោក **នាក់ ឌីម** និងមានការចូលរួមពីមន្ត្រីសាលាជាតិពន្ធដារ និងថ្នាក់ដឹកនាំរបស់គ្រឹះស្ថានឧត្តមសិក្សា និងបានរៀបចំសិក្ខាសាលាជូនអ្នកជាប់ពន្ធ និងសាធារណជនទូទៅតាមអនឡាញ ក្រោមប្រធានបទ "**ការប្រើប្រាស់សេវាកម្មពាក់ព័ន្ធនឹងពន្ធដារពីសហគ្រាសភ្នាក់ងារសេវាកម្មពន្ធដារ**" "**កម្មវិធីបង់ប្រាក់ពន្ធតាមអនឡាញ ( GD Taxpayer App ) លើមុខងារបង់ពន្ធលើមធ្យោបាយដឹកជញ្ជូន**" និង "**ពន្ធលើអចលនទ្រព្យ កម្មវិធីទូរស័ព្ទដៃសម្រាប់ត្រួតពិនិត្យនិងតាមដានឯកសារ ( GDT Check and Track App ) និងកម្មវិធីវិក្កយបត្រនាំសំណាង ( GDT Lucky Draw App )**" ចំនួន **៥ លើក** មានសិក្ខាកាមចូលរួមចំនួន **៣៧៨ រូប** ក្រោមការដឹកនាំរបស់លោក **នាក់ ឌីម** តំណាងរបស់ថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមផងដែរពីថ្នាក់ដឹកនាំ និងមន្ត្រីនៃសាលាជាតិពន្ធដារ ព្រមទាំងអ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ សរុបចំនួន **៣៧៨ រូប**៕








2256-mom chhe...
Lor Rothpanhapi...
CHHAY_BONA_2...




សាខាសាកលវិទ្យាល័យវេស្ទើន ខេត្តកំពង់ចាម

# ២.ការស្រាវជ្រាវ អភិវឌ្ឍន៍កម្មវិធី និងបណ្ណាល័យ

## ការផ្តល់សេវាបណ្ណាល័យសាលាជាតិពន្ធដារ

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ សាលាជាតិពន្ធដារបានផ្តល់សេវាបណ្ណាល័យរួមមាន៖ ការចូលអាន ការខ្ចី និងការទទួលសងសៀវភៅ និងឯកសារផ្សេងៗ ជូនដល់មន្ត្រីរាជការ សិក្ខាកាម សិស្ស-និស្សិត និងសាធារណជនទូទៅ បានចំនួន **៨៥ រូប** (ស្រី ចំនួន ១៩ រូប)។ ក្រៅពីការងារផ្តល់សេវាទាំងនេះ សាលាជាតិពន្ធដារក៏បានខិតខំស្រាវជ្រាវប្រមូល និងបានទទួលសៀវភៅថ្មីៗពាក់ព័ន្ធច្បាប់និងលិខិតបទដ្ឋានគតិយុត្តពីអគ្គនាយកដ្ឋានពន្ធដារ និងស្ថាប័នផ្សេងៗ បានចំនួន **១៦៥ ក្បាល** បន្ថែមទៀត ដើម្បីបំពេញការខ្វះខាត ក៏ដូចជាតម្រូវការរបស់អ្នកអាន បន្ថែមលើឯកសារដែលមានស្រាប់ផងដែរ។ គិតមកដល់បច្ចុប្បន្ន បណ្ណាល័យសាលាជាតិពន្ធដាររក្សាទុកសៀវភៅច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងឯកសារសំខាន់ៗផ្សេងៗទៀត ជាច្រើនសរុបចំនួន **៧ ៦៤៣ ក្បាល** ក្នុងនោះឯកសាររឹងមានចំនួន **៥ ៦៥៣ ឯកសារ** និងឯកសារទន់មានចំនួន **១ ៩៩០ ឯកសារ**។





# ៣.សិក្ខាសាលាសំខាន់ៗ

## សិក្ខាសាលាស្ដីពី "ការផ្ទេរថ្លៃ និងសៀវភៅណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ"



នាព្រឹកថ្ងៃអង្គារ ទី៩ ខែកក្កដា ឆ្នាំ២០២៤ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា មានការរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្ដីពី "**ការផ្ទេរថ្លៃ និងសៀវភៅណែនាំស្ដីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានវត្តមានចូលរួមរបស់ឯកឧត្តម-លោកជំទាវ-លោកអគ្គនាយករង ថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងវត្តមានចូលរួមរបស់វិស័យឯកជន ឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាអភិបាល តំណាងសហគ្រាស ភ្នាក់ងារសេវាកម្មពន្ធដារ ចូលរួមផ្ទាល់ប្រមាណជាង **៦០០ រូប**។

ឯកឧត្តម **គង់ វិបុល** បានថ្លែងអំណរគុណចំពោះវត្តមានដ៏ច្រើនកុះកររបស់ឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាអភិបាល តំណាងសហគ្រាស ភ្នាក់ងារសេវាកម្មពន្ធដារ ដែលមានវត្តមាននាថ្ងៃនេះ គឺបានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ខ្ពស់ ក្នុងការឈ្វេងយល់និងចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធ ក្នុងគោលដៅពង្រឹងអនុលោមភាពសារពើពន្ធជាពិសេស តាមរយៈអនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត (Voluntary Compliance)។ អគ្គនាយកដ្ឋានពន្ធដារបាននិងបន្តយកចិត្តទុកដាក់ខ្ពស់ ក្នុងការពង្រឹងនិងសម្រួលពាណិជ្ជកម្មនិងការវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ មួយវិញទៀត អនុលោមទៅតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ដែលផ្ដោតលើការកែទម្រង់និងការពង្រឹងអភិបាលកិច្ចល្អ និងដើម្បីចូលរួមពង្រឹងអភិបាលកិច្ចសាជីវកម្មរបស់វិស័យឯកជន ព្រមទាំងដើម្បីបន្តពង្រឹងសមត្ថភាពការងារគ្រប់គ្រងនិងប្រមូលចំណូលពន្ធ។ រដ្ឋបាលសារពើពន្ធបាននិងកំពុងបន្តរៀបចំនិងបន្តលើកកម្ពស់ភាពស្អាតស្អំរបស់មន្ត្រី ព្រមទាំងបាននិងកំពុងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងនិងប្រតិបត្តិជាបន្តបន្ទាប់ ជាពិសេសការព្យាយាមវិវត្តខ្លួនទៅជារដ្ឋបាលសារពើពន្ធទំនើប ស្របតាមឧត្តមានុវត្តន៍តំបន់និងអន្តរជាតិ និងបរិការណ៍សង្គម-សេដ្ឋកិច្ចឌីជីថល។

**ខ្លឹមសារសំខាន់ៗនៃសុន្ទរកថាគន្លឹះរបស់ឯកឧត្តម គង់ វិបុល**

- សិក្ខាសាលានាថ្ងៃនេះ គឺជាផ្នែកមួយនៃការពង្រឹងការផ្សព្វផ្សាយនិងលើកកម្ពស់វប្បធម៌បង់ពន្ធ តាមរយៈការរៀបចំសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល ដោយគិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលានិងវគ្គបណ្តុះបណ្តាលសរុបចំនួន **៤០០ លើក** មានសិក្ខាកាមចូលរួមចំនួន **៥៦ ១៧៣ រូប** និងបានផ្តល់សេវាពិគ្រោះយោបល់តាមគ្រប់មធ្យោបាយសរុបចំនួន **៥១ ៩៥០ ករណី**
- ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំនិងផ្សព្វផ្សាយនូវសៀវភៅណែនាំស្តីពីបែបបទនីតិវិធីនៃការធ្វើសវនកម្មពន្ធដារ សម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ (SOP on Auditing) និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ (SOP on Investigation)
- លើកទឹកចិត្តដល់គ្រប់សហគ្រាស អ្នកជាប់ពន្ធ និងភ្នាក់ងារសេវាកម្មពន្ធដារ ចូលរួមពង្រឹងអនុលោមភាពសារពើពន្ធជាពិសេស អនុលោមភាពសារពើពន្ធដោយស្ម័គ្រចិត្ត (Voluntary Compliance) ជាជាងអនុលោមភាពសារពើពន្ធដោយបង្ខំ (Force Compliance)
- អគ្គនាយកដ្ឋានពន្ធដារ មានយន្តការសវនកម្ម ដែលជាម៉ែត្រវាស់នូវកម្រិតអនុលោមភាពសារពើពន្ធ ហើយបន្ថែមពីលើនេះមន្ត្រីពន្ធដារមានតួនាទីត្រូវបំពេញការងារក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ដែលកំណត់ដោយច្បាប់
- ជារូបភាពខ្លះៗ នៃការផ្ទេរថ្លៃ កន្លងមកពាក់ព័ន្ធនឹងការចុះបញ្ជីពន្ធដារមានបុគ្គលដែលជួលឱ្យគេឈរឈ្មោះជំនួស (ក្លែងបន្លំអត្តសញ្ញាណម្ចាស់ពិតប្រាកដ និងមិនមែនជាអ្នកទទួលផលពិតប្រាកដពីអាជីវកម្ម) អាចជាគោលដៅនៃការបង្កើតសហគ្រាសក្លែងក្លាយដើម្បីបំប៉ោងចំណាយ ក្លែងវិក្កយបត្រ និងគេចវេះពន្ធ
- ជំរុញឱ្យភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ពង្រឹងការផ្តល់សេវារបស់ខ្លួន ចៀសវាងការប្រកាសបង់ពន្ធជូនអ្នកជាប់ពន្ធខុស ឬយឺតយ៉ាវ ឬមានចន្លោះប្រហោងណាមួយជាយថាហេតុ និងដាច់ខាតត្រូវចៀសឱ្យផុតពីការពាក់ព័ន្ធនឹងអំពើគេចវេះពន្ធ
- អំពាវនាវដល់អ្នកជាប់ពន្ធចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយ តាមរយៈការប្រកាសនិងបង់ប្រាក់ពន្ធឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ព្រមទាំងចូលរួមរាយការណ៍នូវរាល់ករណីអសកម្ម ឬការគំរាមកំហែងពីសំណាក់មន្ត្រីពន្ធដារ
- បន្តជំរុញនិងបង្កើនល្បឿននៃការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធ (Digital Transformation of Tax Administration) ដើម្បីឱ្យអគ្គនាយកដ្ឋានពន្ធដារព្យាយាមសម្រេចឱ្យបាននូវដំណើរបរិវត្តកម្មរដ្ឋបាលសារពើពន្ធពីជំនាន់ទី១.៥ (Tax Administration 1.5) ទៅជំនាន់ទី២.៥ (Tax Administration 2.5) និងឈានទៅដល់រដ្ឋបាលសារពើពន្ធជំនាន់ទី៣.០ (Tax Administration 3.0) ដែលដំណើរនេះក៏ស្របទៅតាមនិន្នាការនិងតម្រូវការក៏លឿនរហ័សនៃការធ្វើបរិវត្តកម្ម រដ្ឋបាលសារពើពន្ធក្នុងតំបន់និងសកលលោក។

**សិក្ខាសាលានាថ្ងៃនេះបានផ្តោតលើប្រធានបទសំខាន់ៗចំនួន ២ រួមមាន៖**

- ទី១.ការផ្ទេរថ្លៃ (Transfer Pricing) ដោយ លោក **ត្រាំង ឡៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស៖ ខ្លឹមសារនៃបទបង្ហាញ បានលើកឡើងអំពី ១.អ្វីជាការផ្ទេរថ្លៃ ២.ការផ្ទេរថ្លៃក្នុងបរិការណ៍អន្តរជាតិ ៣.ការផ្ទេរថ្លៃក្នុងបរិការណ៍កម្ពុជា ៤.បញ្ហាដែលជួបប្រទះកន្លងមក និង៥.សេចក្តីណែនាំលេខ ១០៩៧៩ អពដ (ឆ្នាំ២០២២)
- ទី២.សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ (SOP on Auditing) ដោយលោក **ជួរ សៃ** អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស៖ ខ្លឹមសារនៃបទបង្ហាញបានលើកឡើងអំពី ១.មុខងារសវនកម្មពន្ធដារ ២.បែបបទ នីតិវិធី និងវំហូរការងារ ៣.សិទ្ធិ អំណាច និងកាតព្វកិច្ចរបស់រដ្ឋបាលសារពើពន្ធ អ្នកជាប់ពន្ធ និងតំណាងអ្នកជាប់ពន្ធ ៤.ក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈរបស់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ ៥.យន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ និង៦.យន្តការរាយការណ៍និងប្តឹង។

# សិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ" និង "សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារជូនភ្នាក់ងារសេវាកម្មពន្ធដារ"




នាព្រឹកថ្ងៃចន្ទ ទី៨ ខែកក្កដា ឆ្នាំ២០២៤ សាលាជាតិពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ "សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ" និង "សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ" ជូនភ្នាក់ងារសេវាកម្មពន្ធដារ ក្រោមអធិបតីភាពឯកឧត្តម **លឹម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ និងភ្នាក់ងារសេវាកម្មពន្ធដារ សរុបចំនួន **១៤៩ រូប**។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **លឹម ហ៊ុយជីវ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារបានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ដែលបានចូលរួមនិងបានផ្តល់មតិចំណាប់អារម្មណ៍អំពីសារៈសំខាន់នៃសិក្ខាសាលាផ្សព្វផ្សាយសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយបានលើកឡើងថាសិក្ខាសាលានេះ គឺជាការរៀបចំឡើងជាលើកទី២ ជូនភ្នាក់ងារសេវាកម្មពន្ធដារ បន្ទាប់ពីបានរៀបចំលើកទី១ កាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៤ កន្លងទៅនេះ។

ឯកឧត្តមអគ្គនាយករង ក៏បានបញ្ជាក់ជូនសិក្ខាកាមអំពីគោលបំណងចម្បងនៃការរៀបចំសិក្ខាសាលានេះឡើងដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីខ្លឹមសារទាំងស្រុងនៃសៀវភៅណែនាំទាំងពីរនេះ ជូនភ្នាក់ងារសេវាកម្មពន្ធដារ ដើម្បីជាចំណេះដឹងក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួនផង និងជួយផ្សព្វផ្សាយបន្តជូនអ្នកជាប់ពន្ធផង ក្នុងគោលដៅធានាឱ្យបាននូវអនុលោមភាពសារពើពន្ធ ក៏ដូចជាការផ្តល់សេវាអ្នកជាប់ពន្ធឱ្យបំពេញកាតព្វកិច្ចសារពើពន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន ដើម្បីលើកកម្ពស់វប្បធម៌នៃការបង់ពន្ធ។ បន្ថែមលើនេះ ឯកឧត្តម

អគ្គនាយករងក៏បានគូសបញ្ជាក់បន្ថែមថា ភ្នាក់ងារសេវាកម្មពន្ធដារគឺជាដៃគូដ៏ជិតស្និទ្ធរបស់អគ្គនាយកដ្ឋានពន្ធដារ ដែលជាទូតតំណាងរដ្ឋបាលសារពើពន្ធក្នុងការផ្តល់សេវាប្រឹក្សាយោបល់ ណែនាំ និងចង្អុលបង្ហាញដល់អ្នកជាប់ពន្ធក្នុងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារឱ្យបានត្រឹមត្រូវ។ ក្នុងន័យនេះ ភ្នាក់ងារសេវាកម្មពន្ធដារត្រូវបន្តអភិវឌ្ឍទាំងចំណេះដឹង និងជំនាញរបស់ខ្លួនឱ្យស្របតាមការវិវត្តរបស់អគ្គនាយកដ្ឋានពន្ធដារ ជាពិសេសផ្នែកច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ យន្តការ និងនីតិវិធីនៃការអនុវត្តការងារផងដែរ។

ឯកឧត្តមអគ្គនាយករងបានបញ្ជាក់ជូនសិក្ខាកាមថា ការរៀបចំចងក្រងសៀវភៅទាំងពីរនេះជាទម្រង់និយាមនីតិវិធីប្រតិបត្តិការងារ (Standard Operating Procedures - SOP) ដែលមានធាតុចូលគ្រប់ជ្រុងជ្រោយពីសំណាក់តំណាងវិស័យឯកជន គឺដើម្បីបង្កើតបាននូវភាពជាក់លាក់ ច្បាស់លាស់ និងត្រឹមត្រូវជាស្តង់ដាររួមសម្រាប់អនុវត្តការងារសេវនកម្មពន្ធដារ និងការងារស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលមានរំលេចអំពីជំហាន និងដំណើរបែបបទតាមលំដាប់លំដោយប្រកបដោយតម្លាភាពខ្ពស់។ នៅក្នុងសៀវភៅណែនាំទាំងពីរនេះ គឺមានចែងច្បាស់អំពីសិទ្ធិ អំណាច កាតព្វកិច្ច ក្រមសីលធម៌របស់សវនករពន្ធដារ និងមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក៏ដូចជារបស់អ្នកជាប់ពន្ធផងដែរ ហើយក៏មានចែងច្បាស់អំពីយន្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសវនកម្មពន្ធដារ និងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ ជារួម ការដាក់ឱ្យអនុវត្តសៀវភៅទាំងពីរនេះគឺដើម្បីចៀសវាងនូវការធ្វើសវនកម្ម ដែលមានលក្ខណៈសាំញ៉ាំនិងត្រួតគ្នាច្រើនលើកច្រើនសា និងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារឱ្យមានភាពច្បាស់លាស់ ក្នុងគោលបំណងបង្កើនសង្គតិភាព ប្រសិទ្ធភាព និងតម្លាភាពក្នុងការអនុវត្តការងារ ដែលទាំងនេះ នឹងជួយជាចំណែកលើកស្ទួយបរិយាកាសធុរកិច្ចឱ្យមានលក្ខណៈច្បាស់លាស់ និងអាចព្យាករបាន (more certain and predictable)។

សិក្ខាសាលានេះ ក៏បានការធ្វើបទបង្ហាញដោយវាគ្មិនដែលជាមន្ត្រីជំនាញមកពីនាយកដ្ឋានពាក់ព័ន្ធអំពីខ្លឹមសារនៃសៀវភៅណែនាំទាំងពីរខាងលើនេះ ដោយបានធ្វើការពន្យល់ និងបកស្រាយយ៉ាងក្បោះក្បាយអំពីខ្លឹមសារទាំងស្រុងនៃសៀវភៅណែនាំទាំងពីរនេះដល់សិក្ខាកាម ព្រមទាំងមានការចូលរួមលើកជាសំណួរយ៉ាងផុលផុសពីសិក្ខាកាមផងដែរ៕



# វគ្គបណ្តុះបណ្តាល ស្តីពី "បែបបទនៃការតាក់តែង និងប្រើប្រាស់លិខិតរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារ"




*ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**ការតាក់តែង និងប្រើប្រាស់លិខិតរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារ**" ជូនដល់សាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមអធិបតីភាព ឯកឧត្តម **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីលោកទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ថ្នាក់ដឹកនាំ មន្ត្រីរាជការពន្ធដារពាក់ព័ន្ធនៃនាយកដ្ឋានថ្នាក់កណ្តាល សាលាជាតិពន្ធដារ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ សាខាពន្ធដារខេត្ត-ខណ្ឌ ដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ សរុបចំនួន **៣៦០ រូប**។

ជាកិច្ចចាប់ផ្តើម លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម បានសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ចំពោះឯកឧត្តមអគ្គនាយករង និងថ្លែងអំណរគុណចំពោះសិក្ខាកាម ដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។ បន្ទាប់ពីនេះ លោកប្រធាននាយកដ្ឋានបានលើកឡើងអំពីគោលបំណងនៃការរៀបចំវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីពង្រឹងបន្ថែមលើការងាររៀបចំតាក់តែងនិងប្រើប្រាស់លិខិតរដ្ឋបាល ស្របនឹងសៀវភៅណែនាំស្តីពីគំរូទម្រង់និងបែបបទនៃការតាក់តែង និងប្រើប្រាស់លិខិតរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារជំនាន់ទី២ ដែលត្រូវបានដាក់ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានានូវប្រសិទ្ធភាពក្នុងការផ្តល់សេវាអ្នកជាប់ពន្ធឱ្យបានទាន់ពេលវេលា ស្របតាមបទដ្ឋានបច្ចេកទេសច្បាស់លាស់ និងមានសង្គតិភាពក្នុងការអនុវត្ត។

ជាកិច្ចបន្ទាប់ ឯកឧត្តមអគ្គនាយករងបានថ្លែងសុន្ទរកថាបើកវគ្គបណ្តុះបណ្តាល ដោយបានសម្តែងនូវកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ និងវាយតម្លៃខ្ពស់ចំពោះវត្តមានរបស់សិក្ខាកាម ដែលបានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់ ដែលឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការគោរពប្រតិបត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជាពិសេស គឺដើម្បីឈ្វេងយល់ឱ្យបានកាន់តែស៊ីជម្រៅថែមទៀតលើការពង្រឹងសមត្ថភាពលើការតាក់តែង

និងប្រើប្រាស់លិខិតរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារ។

បន្ថែមពីនេះ ឯកឧត្តមក៏បានគូសបញ្ជាក់ដែរថា កិច្ចការរដ្ឋបាលឬរដ្ឋបាលកិច្ច គឺជាភារកិច្ចដ៏សំខាន់ជាទីបំផុត ដោយហេតុថាមុខងារនេះជាមុខងារប្រតិបត្តិការរួមប្រចាំថ្ងៃរបស់អង្គភាព ឬស្ថាប័ននីមួយៗ ហើយលិខិតរដ្ឋបាល គឺជាផ្នែកមួយនៃពិធីការទំនាក់ទំនងរបស់ផ្នែករដ្ឋបាល។ ដូចនេះ គុណភាពនិងសោភណភាពនៃទិដ្ឋភាពទាំងស្រុងរបស់លិខិតរដ្ឋបាលសម្រាប់ទំនាក់ទំនងផ្ទៃក្នុងនិងជាមួយមជ្ឈដ្ឋានខាងក្រៅ គឺជាមុខមាត់និងជាកិត្តិយសរបស់អង្គភាពឬស្ថាប័ននីមួយៗ។ លើសពីនេះ សំណេរទាំងស្រុងនៃលិខិតរដ្ឋបាលត្រូវមានលក្ខណៈតាមបែបបទ លំដាប់លំដោយដែលមានឃ្លោងឃ្លាសមរម្យនិងអត្ថន័យខ្លឹមសារ ជាក់លាក់ ច្បាស់លាស់ ងាយយល់និងចំគោលដៅនៃប្រធានបទ ដោយមិនចាំបាច់រៀបរាប់វែងអន្លាយ ឬសរសេរសាចុះសាឡើង ដែលបង្កឱ្យមានលក្ខណៈសាំញ៉ាំទៅវិញ។ ក្នុងន័យនេះ អ្នករៀបចំតាក់តែងឬសរសេរលិខិតរដ្ឋបាលគួរព្យាយាមត្រិះរិះ ផ្ចិតផ្ចង់ និងកំណត់យកពាក្យ វាក្យសព្ទឃ្លោងឃ្លា និងប្រយោគដែលមានលក្ខណៈសាមញ្ញ ងាយយល់ និងសមស្របទៅតាមប្រធានបទ។

ឯកឧត្តមបានបញ្ជាក់បន្ថែមថាវគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងចែករំលែកនូវចំណេះដឹង ចំណេះធ្វើ និងបទពិសោធនៃការអនុវត្តការងារពាក់ព័ន្ធនឹងបែបបទនៃការតាក់តែង និងប្រើប្រាស់លិខិតរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ព្រមទាំងប្រមូលជាតុចូលនិងបញ្ហាប្រឈមនានា ដើម្បីពង្រឹងសមត្ថភាពមន្ត្រីស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ថ្នាក់ដឹកនាំដែលបានលើកឡើងកន្លងមក៖ ទី១.ក្នុងឱកាសនៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩នាថ្ងៃទី១៣ខែវិច្ឆិកាឆ្នាំ២០២៣**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានសម្រេចដាក់ចេញនូវវិធានការកែទម្រង់មុតស្រួចជាកញ្ចប់ ដើម្បីដោះស្រាយបញ្ហាប្រឈមនិងកង្វល់ពាក់ព័ន្ធនឹងវិស័យវិនិយោគឯកជន ក៏ដូចជាការគិតគូរសម្រួលបន្ថែមសម្រាប់វិស័យមួយចំនួន ក្នុងការកាត់បន្ថយថ្លៃធ្វើធុរកិច្ច សំដៅលើកកម្ពស់ភាពប្រកួតប្រជែង និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ទី២.ការណែនាំរបស់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** ដែលការរៀបចំនិងដាក់ឱ្យប្រើប្រាស់នូវកម្មវិធី e-Administration ដែលនឹងក្លាយជាឧបករណ៍ទំនើបដើម្បីគាំទ្រវាល់ការផ្តល់សេវានិងផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនក្នុងការដាក់លិខិតរដ្ឋបាលនានាតាមប្រព័ន្ធអេឡិចត្រូនិកមករដ្ឋបាលសារពើពន្ធដើម្បីដំណើរការឯកសារ និងជាកិច្ចការរយៈពេលវែងសម្រាប់គោលដៅឆ្នាំ២០២៨ ជំរុញនិងគាំទ្រអគ្គនាយកដ្ឋានពន្ធដារកែប្រែឱ្យក្លាយទៅជា Tax Administration 2+ ដែលក្នុងបរិការណ៍នេះ ការបង្កើនល្បឿននៃកិច្ចការកែទម្រង់ គឺជាអភិក្រមនៃការដោះស្រាយបញ្ហានានា ទី៣.ក្នុងឱកាសនៃកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រមូលចំណូលប្រចាំខែមករា ឆ្នាំ២០២៤ នាថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានដាក់ចេញនៅទិសដៅសម្រាប់អនុវត្តបន្ត ដោយពង្រឹងការបណ្តុះបណ្តាលជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ និងដាក់ឱ្យប្រើប្រាស់នូវ "កម្មវិធីរដ្ឋបាលអេឡិចត្រូនិក GDT e-Administration" និង "ប្រព័ន្ធគ្រប់គ្រងការតាមដានឯកសារ មុខងារបញ្ជីឯកសារតាមរយៈ GDT e-Administration" ដែលនឹងក្លាយជាឧបករណ៍ទំនើបដើម្បីគាំទ្រវាល់ការផ្តល់សេវាអ្នកជាប់ពន្ធ ដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនក្នុងការដាក់លិខិតរដ្ឋបាលនានា តាមប្រព័ន្ធអេឡិចត្រូនិកមករដ្ឋបាលសារពើពន្ធដើម្បីដំណើរការឯកសារជូន។

**ឯកឧត្តមបណ្ឌិតអគ្គនាយករង បានផ្តល់នូវអនុសាសន៍ណែនាំបន្ថែមដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារ**

**ដើម្បីបង្កើនផលិតភាពការងារ និងប្រសិទ្ធភាពក្នុងការដឹកនាំ ការគ្រប់គ្រង និងការបំពេញការងារប្រចាំថ្ងៃដូចខាងក្រោម៖**

- អនុវត្តការងារដោយគោរពទៅតាមទស្សនវិស័យ បេសកកម្ម និងក្រមតម្លៃរបស់អង្គភាព
- អនុវត្តការងារទៅតាមលំនាំ គំរូរបៀបរបប បញ្ជីការងារ និងដំណើរនីតិវិធីបែបបទការងារជាជំហានៗតាមលំដាប់លំដោយក្នុងកិច្ចការងារដឹកនាំ គ្រប់គ្រង និងការអនុវត្តសកម្មភាពការងារប្រចាំថ្ងៃ ដែលមានចែងនៅក្នុងនិយាមនីតិវិធីប្រតិបត្តិការងារ (SOP) ប្រកបដោយវិជ្ជាជីវៈ ស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន
- ខិតខំពង្រឹងនិងអភិវឌ្ឍសមត្ថភាពជាប្រចាំទាំងច្បាប់ បទប្បញ្ញត្តិ និងសេចក្តីណែនាំថ្មីៗស្តីពីពន្ធដារ បទពិសោធនៃការអនុវត្តភាពជាអ្នកដឹកនាំ ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ការផ្តល់សេវាអ្នកជាប់ពន្ធ ការប្រមូលចំណូលពន្ធប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព
- បង្កើតវប្បធម៌ចែករំលែករួមទាំងចំណេះដឹង បទពិសោធការងារ និងផលប្រយោជន៍ ព្រមទាំងរួមសាមគ្គីគ្នាក្នុងការចូលរួមដោះស្រាយបញ្ហានានា ចៀសវាងការគេចចេញពីបញ្ហាដែលបង្កជាផលវិបាកដល់ខ្លួនឯង និងអង្គភាពទាំងមូល
- យកចិត្តទុកដាក់អនុវត្តការងារប្រមូលចំណូលពន្ធដារ ស្របតាមបទប្បញ្ញត្តិនិងនីតិវិធីជាធរមាន ព្រមទាំងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ជាពិសេសអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់នៅក្នុងឱកាសនៃកិច្ចប្រជុំប្រចាំខែនីមួយៗ។

សិក្ខាសាលានេះ រៀបចំឡើងដោយមានការធ្វើបទបង្ហាញលើប្រធានបទ ស្តីពី **"បែបបទនៃការតាក់តែង និងប្រើប្រាស់លិខិតរដ្ឋបាលរបស់អគ្គនាយកដ្ឋានពន្ធដារ"** ដោយលោក **ង៉ាន់ វុទ្ធី** អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក និងលោក **ថុង យ៉ត** ប្រធានការិយាល័យនៃនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក ជាវាគ្មិនធ្វើបទបង្ហាញ។ នៅវគ្គបណ្តុះបណ្តាលនេះផងដែរក៏មានការចែករំលែកបទពិសោធ និងវេទិកាសំណួរ-ចម្លើយ ដោយឯកឧត្តមបណ្ឌិត **គៀន សម្បត្តិ** អគ្គនាយករង លោក **អ៊ិន សំបុក** ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក **ជា ពិសិដ្ឋ** ទីប្រឹក្សាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម លោក **កែ ឈុំបញ្ញា** អនុប្រធាននាយកដ្ឋានរដ្ឋបាលនិងកិច្ចការទូទៅ លោក **ម៉ា បូរ៉ា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម លោក **ង៉ាន់ វុទ្ធី** អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក និងលោក **ថុង យ៉ត** ប្រធានការិយាល័យនៃនាយកដ្ឋានហិរញ្ញវត្ថុនិងបុគ្គលិក៕



# សិក្ខាសាលាផ្សព្វផ្សាយ "សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធី នៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ" និង "សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ"




នាព្រឹកថ្ងៃចន្ទ ទី១២ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **"សៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ"** និង **"សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ"** ជូនអ្នកជាប់ពន្ធ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ ក្រោមអធិបតីភាពឯកឧត្តម **លឹម ហ៊ុយជីវ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ និងអ្នកជាប់ពន្ធ ប្រមាណ **១៧០ រូប**។

ជាកិច្ចចាប់ផ្តើម លោក **អេង វេតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំបានសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ចំពោះឯកឧត្តមអគ្គនាយករង និងបានថ្លែងអំណរគុណចំពោះសិក្ខាកាមដែលបានចូលរួមសិក្ខាសាលានេះ ដែលបញ្ជាក់ពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការឈ្វេងយល់ការវិវត្តថ្មីៗជុំវិញប្រធានបទនៃសៀវភៅណែនាំទាំងពីរនេះ ដើម្បីជំរុញបង្កើនអនុលោមភាព និងកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។ លោកប្រធាននាយកដ្ឋានក៏បានស្នើដល់សិក្ខាកាមដែលចូលរួមទាំងអស់យកចិត្តទុកដាក់ស្តាប់ និងសួរសំណួរដែលមានដើម្បីទទួលយកចំណេះដឹងបន្ថែមពីសិក្ខាសាលានេះ។

ជាកិច្ចបន្ទាប់ ឯកឧត្តមអគ្គនាយករងបានផ្តល់ចំណាប់អារម្មណ៍អំពីសារៈសំខាន់នៃសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ និងសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីខ្លឹមសារទាំងស្រុងនៃសៀវភៅណែនាំទាំងពីរនេះជូនសិក្ខាកាម ដើម្បីជាចំណេះដឹងក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធរបស់ខ្លួនក្នុងគោលដៅធានាឱ្យបាននូវអនុលោមភាពសារពើពន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

ឯកឧត្តមអគ្គនាយករង បានបញ្ជាក់បន្ថែមជូនសិក្ខាកាមថាការរៀបចំចងក្រងសៀវភៅណែនាំទាំងពីរនេះជាទម្រង់និយាមនីតិវិធីប្រតិបត្តិការងារ (Standard Operating Procedures - SOP) ដែលមានធាតុចូលគ្រប់ជ្រុងជ្រោយពីសំណាក់តំណាងវិស័យឯកជន គឺដើម្បីបង្កើតបាននូវភាពជាក់លាក់ ច្បាស់លាស់ និងត្រឹមត្រូវជាស្តង់ដាររួមសម្រាប់អនុវត្តការងារសវនកម្មពន្ធដារ និងការងារស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដែលមានរំលេចអំពីជំហាន និងដំណើរបែបបទតាមលំដាប់លំដោយប្រកបដោយតម្លាភាពខ្ពស់។ នៅក្នុងសៀវភៅណែនាំទាំងពីរនេះគឺមានចែងច្បាស់អំពីសិទ្ធិ អំណាច កាតព្វកិច្ច ក្រមសីលធម៌របស់សវនករពន្ធដារ និងមន្ត្រីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ក៏ដូចជារបស់អ្នកជាប់ពន្ធផងដែរ ហើយក៏មានចែងច្បាស់អំពីយន្តការតាមដានត្រួតពិនិត្យ វាយតម្លៃ និងដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការងារសវនកម្មពន្ធដារ និងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ។ ជារួម ការដាក់ឱ្យអនុវត្តសៀវភៅណែនាំទាំងពីរនេះគឺដើម្បីចៀសវាងនូវការធ្វើសវនកម្មដែលមានលក្ខណៈសាំញ៉ាំ និងត្រួតគ្នាច្រើនលើកច្រើនសានិងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារឱ្យមានភាពច្បាស់លាស់ក្នុងគោលបំណងបង្កើនសង្គតិភាព ប្រសិទ្ធភាព និងតម្លាភាពក្នុងការអនុវត្តការងារ ដែលទាំងនេះនឹងជួយជាចំណែកលើកស្ទួយបរិយាកាសធុរកិច្ចឱ្យមានលក្ខណៈច្បាស់លាស់ និងអាចព្យាករបាន (more certain and predictable)។

បន្ទាប់ពីបានលើកឡើងត្រួសៗអំពីទិដ្ឋភាពរួមនៃសៀវភៅណែនាំទាំងពីរនេះ ឯកឧត្តមអគ្គនាយករងបានស្នើឱ្យក្រុមការងារបន្តអនុវត្តតាមរបៀបវារៈជាបន្តបន្ទាប់ ដែលមាន៖ ១.ការធ្វើបទបង្ហាញ ស្តីពីសៀវភៅណែនាំស្តីពីបែបបទនិងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារនិងអ្នកជាប់ពន្ធ ដោយលោកស្រី **ព្រំ ទិត្យដារីយ៉ា** អនុប្រធានការិយាល័យនៃនាយកដ្ឋានសវនកម្មសហគ្រាស ២.ការធ្វើបទបង្ហាញស្តីពីសៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ ដោយលោក **អាន សំណាង** អនុប្រធាននាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ។ ជារួម សិក្ខាសាលានេះបានប្រព្រឹត្តទៅដោយរលូន និងជោគជ័យ ដែលមានការធ្វើបទបង្ហាញ ពន្យល់ បកស្រាយលម្អិត និងក្បោះក្បាយអំពីខ្លឹមសារនីមួយៗនៃសៀវភៅណែនាំទាំងពីរនេះដល់អង្គសិក្ខាសាលាទាំងមូល ព្រមទាំងបានឆ្លើយសំណួរជាច្រើនរបស់សិក្ខាកាម ដើម្បីស្រាយបំភ្លឺនូវចម្ងល់នានាដែលមាន៕



# សិក្ខាសាលាផ្សព្វផ្សាយកាតព្វកិច្ចបិទតែមប្រើអាករសម្រាប់បារី អាករសម្រាប់បំភ្លឺសាធារណៈ និងការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (e-Filing) ដល់សហគ្រាសផលិត នាំចូល និងចែកចាយបន្តផលិតផលស្រា ស្រាបៀរ និងបារី




*ឯកឧត្តម **ម៉ិញ បានកុសល** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*

នាព្រឹកថ្ងៃអង្គារ ទី២០ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីកាតព្វកិច្ចបិទតែមប្រើអាករសម្រាប់បារី អាករសម្រាប់បំភ្លឺសាធារណៈ និងការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (e-Filing) នៅសណ្ឋាគារ Fairfield By Marriot ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **ម៉ិញ បានកុសល** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីលោកបណ្ឌិត **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ លោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម តំណាងរបស់អគ្គ-នាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា លោក លោកស្រីប្រធានសាខាពន្ធដារខេត្ត-ខណ្ឌ និងមន្ត្រីពន្ធដារពាក់ព័ន្ធ ព្រមទាំងម្ចាស់ និងតំណាងសហគ្រាសផលិតនាំចូលនិងចែកចាយបន្តផលិតផលស្រា ស្រាបៀរ និងបារី ចូលរួមដោយផ្ទាល់ និងតាមប្រព័ន្ធអនឡាញ (Zoom Meeting) សរុបចំនួន **២២៨ រូប**។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមបណ្ឌិតអគ្គនាយករង បានមានមតិស្វាគមន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានរបស់ឯកឧត្តម លោក លោកស្រី នាងកញ្ញាទាំងអស់ដែលបានចូលរួមក្នុងសិក្ខាសាលានេះ។ នៅក្នុងសុន្ទរកថាបើក ឯកឧត្តមបណ្ឌិតអគ្គនាយករង បានគូសបញ្ជាក់ដល់អង្គសិក្ខាសាលាទាំងមូលថា ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើប្រធានបទនេះមិនមែនធ្វើឡើងជាលើកទីមួយនោះទេ ប៉ុន្តែគឺត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ ដើម្បីបន្តរំលឹកណែនាំ និងជំរុញម្ចាស់សហគ្រាសផលិត នាំចូល និងចែកចាយបន្តបារី ឱ្យអនុវត្តកាតព្វកិច្ចបិទតែមប្រើអាករលើផលិតផលបារីរបស់ខ្លួនឱ្យបានត្រឹមត្រូវមុនដាក់លក់នៅលើទីផ្សារ និងត្រូវបង់ពន្ធអាករឱ្យបានគ្រប់ចំនួន ដើម្បីចៀសវាងការខាតបង់ប្រាក់កាស ឬទទួលរងទណ្ឌកម្មរដ្ឋបាលផ្សេងៗ ព្រោះថាបារីដែលមិនមានបិទតែមប្រើអាករត្រឹមត្រូវ គឺជាបារីខុសច្បាប់ ដែលនឹងត្រូវរឹបអូស ឬបំផ្លាញចោល នៅក្នុងយុទ្ធនាការចុះចាត់វិធានការតឹងរ៉ឹងរបស់ក្រុមការងារចម្រុះដើម្បីត្រួតពិនិត្យកាតព្វកិច្ចបិទតែមប្រើអាករសម្រាប់បារីរបស់អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នាពេលខាងមុខ។ ដោយឡែក ចំពោះអាករសម្រាប់បំភ្លឺសាធារណៈ ឯកឧត្តមបណ្ឌិតអគ្គនាយករង បានបញ្ជាក់ថា ក្រៅពីមាន

កាតព្វកិច្ចបិទតែមប្រើអាករ ផលិតផលបារី ក៏ត្រូវជាប់អាករសម្រាប់បំភ្លឺសាធារណៈ និងពន្ធអាករដទៃទៀត ដូចផលិតផលស្រា និងស្រាបៀរផងដែរ។ មុនខែមេសា ឆ្នាំ២០២៤ អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវកំណត់តាមអត្រា ៣% នៅគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់ផលិតផលបារីស្រានិងស្រាបៀរទាំងនាំចូលនិងផលិតក្នុងស្រុកប៉ុន្តែដោយពិនិត្យឃើញថាការកំណត់វិធាននៃការប្រមូលអាករនៅគ្រប់ដំណាក់កាលនៃការផ្គត់ផ្គង់ ជាបន្ទុករដ្ឋបាលទាំងអ្នកជាប់ពន្ធ និងរដ្ឋបាលសារពើពន្ធ ព្រមទាំងមានសំណូមពរពីវិស័យឯកជន ទើបរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចកែសម្រួលនីតិវិធីនៃការប្រមូលអាករនេះ មកត្រឹមតែម្តងគត់គឺនៅពេលផ្គត់ផ្គង់ក្នុងស្រុកក្រោយពេលនាំចូល ឬផលិត ដោយកំណត់យកអត្រា ៥% ដែលចាប់ផ្តើមអនុវត្តពីខែមេសា ឆ្នាំ២០២៤ តទៅ តាមរយៈអនុក្រឹត្យលេខ២៨៦ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ និងប្រកាសលេខ ១៦៨ សហវ.ប្រក.អពជ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ ស្តីពីអាករសម្រាប់បំភ្លឺសាធារណៈ។ ជាមួយគ្នានេះ ឯកឧត្តមបណ្ឌិត អគ្គនាយករងក៏បានបញ្ជាក់បន្ថែមថា ដើម្បីសម្រួលដល់ការប្រកាសបង់អាករសម្រាប់បំភ្លឺសាធារណៈនេះ ក៏ដូចជាពន្ធអាករដទៃទៀត អគ្គនាយកដ្ឋានពន្ធដារ បានដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងការប្រកាសពន្ធអាជីវកម្មតាមអនឡាញ (e-Filing) ដែលអ្នកជាប់ពន្ធអាចដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ ដោយមិនចាំបាច់មកដាក់លិខិតប្រកាសដោយផ្ទាល់នៅរដ្ឋបាលសារពើពន្ធ។ ការធ្វើទំនើបកម្មប្រព័ន្ធពន្ធដារនេះ បានជួយកាត់បន្ថយពេលវេលា ថវិកា និងចំណាយផ្សេងៗទៀតដែលមិនចាំបាច់របស់អ្នកជាប់ពន្ធ ដែលជាផ្នែកមួយនៃការផ្តល់សេវាល្អសំដៅពង្រឹងអភិបាលកិច្ចល្អរបស់អគ្គនាយកដ្ឋានពន្ធដារ។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមបណ្ឌិត អគ្គនាយករង បានណែនាំនិងជំរុញម្ចាស់ និងតំណាងសហគ្រាសដែលចូលរួមក្នុងសិក្ខាសាលាឱ្យចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន ចៀសវាងទទួលរងនូវទណ្ឌកម្មរដ្ឋបាលនិងទោសទណ្ឌនានាពីការគេចវេះពន្ធ ព្រមទាំងបានលើកឡើងថាវប្បធម៌នៃការបង់ពន្ធត្រឹមត្រូវ និងតម្លាភាពរបស់អ្នកជាប់ពន្ធនឹងបង្កបរិយាកាសធុរកិច្ចល្អ និងស្មើភាពសម្រាប់វិនិយោគិន ជាពិសេសបង្កើនបរិយាកាសការងារល្អរវាងអ្នកជាប់ពន្ធ និងមន្ត្រីពន្ធដារ។

**អង្គសិក្ខាសាលានាថ្ងៃនេះផ្តោតសំខាន់លើប្រធានបទចំនួនបី ដែលមានការចូលរួមធ្វើបទបង្ហាញនិងពន្យល់បកស្រាយយ៉ាងក្បោះក្បាយដោយវាគ្មិនពីនាយកដ្ឋានពាក់ព័ន្ធ ដោយក្នុងនោះមាន៖**

- បទបង្ហាញស្តីពី "**កាតព្វកិច្ចបិទតែមប្រើអាករសម្រាប់បារី**" ដោយលោក **ម៉ឹង សុខឡៅ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
- បទបង្ហាញស្តីពី "**អាករសម្រាប់បំភ្លឺសាធារណៈ**" ដោយលោក **ប៉ុក បូរក្សី** អនុប្រធានការិយាល័យ នៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ និង
- បទបង្ហាញស្តីពី "**ការប្រកាសពន្ធតាមប្រព័ន្ធអនឡាញ (e-Filing)**" ដោយលោក **ស៊ីវ ស៊ុនហួច** អនុប្រធានការិយាល័យនៃនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន។

បន្ទាប់ពីបញ្ចប់ការធ្វើបទបង្ហាញលើប្រធានបទទាំងបីខាងលើ អង្គសិក្ខាសាលា ក៏មានរៀបចំកម្មវិធីសំណួរ-ចម្លើយ ដែលមានការចូលរួមពីលោកបណ្ឌិត **អេង រតនា** និងវាគ្មិនទាំង ៣រូប ដោយបានផ្តល់ឱកាសឱ្យម្ចាស់និងតំណាងសហគ្រាស ក៏ដូចជាសិក្ខាកាមទាំងអស់ដែលបានចូលរួមលើកជាសំណួរនានាពាក់ព័ន្ធនឹងប្រធានបទទាំងបីនេះ ឬក៏ចម្ងល់ផ្សេងៗទៀតទាក់ទងនឹងពន្ធដារ។ ក្រោយមានការលើកជាសំណួរផ្សេងៗពីសិក្ខាកាម ដែលជាអ្នកជាប់ពន្ធ លោកបណ្ឌិត និងវាគ្មិន បានបកស្រាយបំភ្លឺយ៉ាងក្បោះក្បាយដែលធ្វើឱ្យម្ចាស់សំណួរអស់ចម្ងល់ និងទទួលបានការសាទរពីអ្នកចូលរួមទាំងអស់គ្នា។

ក្នុងសុន្ទរកថាបិទអង្គសិក្ខាសាលា លោកបណ្ឌិត **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ បានលើកឡើងថា ក្រោយបញ្ចប់សិក្ខាសាលាផ្សព្វផ្សាយនេះ សិក្ខាកាមទាំងអស់នឹងយល់កាន់តែច្បាស់អំពីកាតព្វកិច្ចបិទតែមប្រើអាករសម្រាប់បារី របៀបគណនាអាករសម្រាប់បំភ្លឺសាធារណៈ និងរបៀបដាក់លិខិតប្រកាសពន្ធតាមអនឡាញ។

ជាមួយគ្នានេះដែរ លោកបណ្ឌិតក៏បានណែនាំដល់តំណាងសហគ្រាសដែលមកចូលរួមសិក្ខាសាលានេះ ត្រូវរាយការណ៍ និងពន្យល់ដល់ម្ចាស់សហគ្រាសអំពីកាតព្វកិច្ចសារពើពន្ធ និងចំណេះដឹងដែលទទួលបានពីសិក្ខាសាលានេះ ដោយធ្វើយ៉ាងណាឱ្យម្ចាស់សហគ្រាសទាំងនោះ ចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារជាធរមាន។ ជាកិច្ចបញ្ចប់ លោកបណ្ឌិតបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោក លោកស្រី នាងកញ្ញា ជាថ្នាក់ដឹកនាំនិងមន្ត្រីពាក់ព័ន្ធ ជាពិសេសលោក លោកស្រី នាងកញ្ញា ជាម្ចាស់និងតំណាងសហគ្រាស ដែលបានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយនេះ ព្រមទាំងប្រសិទ្ធពរឱ្យជួបតែវិបុលសុខ និងសមប្រកបតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕







*លោក **ម៉ឹង សុខឡៅ** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ*


*លោកបណ្ឌិត **អេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ*



# សិក្ខាសាលា ស្តីពី "វិធាននិងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នានិងការផ្លាស់ប្តូរព័ត៌មានសម្រាប់គោលបំណងពន្ធ"



នាព្រឹកថ្ងៃពុធ ទី២១ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារភ្នំពេញ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំសិក្ខាសាលាស្តីពី "វិធាននិងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា (Double Taxation Agreement-DTA) និងការផ្លាស់ប្តូរព័ត៌មានសម្រាប់គោលបំណងពន្ធ (Exchange of Information-EOI)" ក្រោមអធិបតីភាព លោកជំទាវ **ម៉ិន នារី** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អមដោយលោកបណ្ឌិត **សេង ជាសិទ្ធ** ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ (ន.នគសអ) ព្រមទាំងមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងសាខាពន្ធដារខណ្ឌទាំង៩ រួមទាំងតំណាងក្រុមហ៊ុនឯកជន និងភ្នាក់ងារសេវាកម្មពន្ធដារដទៃទៀតប្រមាណ **៣០០ រូប**។

ជាកិច្ចចាប់ផ្តើម ក្នុងនាមអគ្គនាយកដ្ឋានពន្ធដារ លោកជំទាវ **ម៉ិន នារី** បានថ្លែងសុន្ទរកថាបើកអង្គសិក្ខាសាលា និងសម្តែងនូវមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលជាថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារ ព្រមទាំងតំណាងក្រុមហ៊ុនឯកជន និងភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ដែលមានវត្តមានក្នុងសិក្ខាសាលានេះ។ លោកជំទាវអគ្គនាយករង បានលើកឡើងអំពីសារៈតារ និងគោលបំណងដែលកម្ពុជាត្រូវមានកិច្ចព្រមព្រៀង DTA ព្រមទាំងចែករំលែកបទពិសោធ និងចំណេះដឹងនានាដល់សិក្ខាកាមទាំងអស់ ទាក់ទិននឹងវិធាននិងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀង DTA និងការផ្លាស់ប្តូរព័ត៌មានសម្រាប់គោលបំណងពន្ធ ដើម្បីធានាបាននូវការអនុវត្តកាតព្វកិច្ចសារពើពន្ធប្រកប ដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ជាពិសេសពង្រឹងអនុលោមភាពសារពើពន្ធ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

លោកជំទាវអគ្គនាយករង បានគូសបញ្ជាក់ថា ការរៀបចំការចរចាកិច្ចព្រមព្រៀង DTA ជាមួយបណ្តាប្រទេសជាដៃគូវិនិយោគសំខាន់ៗ ធ្វើឡើងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល តាំងពីនីតិកាលទី៦ នៃរដ្ឋសភា និង

បន្តដល់រាជរដ្ឋាភិបាលនៃនីតិកាលទី៧ នៃរដ្ឋសភា ដើម្បីបំពេញកាតព្វកិច្ចក្រោមក្របខ័ណ្ឌអាស៊ាន ទាក់ទាញនិងសម្រួលការវិនិយោគនិងពាណិជ្ជកម្មអន្តរជាតិ ព្រមទាំងទប់ស្កាត់ការគេចវេះពន្ធ ទាំងក្នុងក្របខ័ណ្ឌជាតិនិងអន្តរជាតិ។ ជាក់ស្តែង កម្ពុជា បានចាប់ផ្តើមចរចាកិច្ចព្រមព្រៀង DTA ដំបូង ក្នុងឆ្នាំ២០១៥ និងរហូតមកដល់បច្ចុប្បន្ននេះ កម្ពុជាមានកិច្ចព្រមព្រៀង DTA ចំនួន ១១ បានចូលជាធរមាន និងកំពុងមានប្រសិទ្ធភាពអនុវត្ត រួមមាន សិង្ហបុរី ចិន ថៃ ប្រ៊ុយណេ វៀតណាម ឥណ្ឌូណេស៊ី តំបន់រដ្ឋបាលពិសេសហុងកុង ម៉ាឡេស៊ី កូរ៉េខាងត្បូង តំបន់រដ្ឋបាលពិសេសម៉ាកាវ និងតួកគី។ កម្ពុជា ក៏កំពុងធ្វើការចរចាបន្តជាមួយជប៉ុន អេមីរ៉ាតអារ៉ាប់រួម មីយ៉ាន់ម៉ា ម៉ារ៉ុក និងបារាំងផងដែរ។

ជាកិច្ចបន្តលោកស្រី **ចាន់ លីហួរ** អនុប្រធានការិយាល័យសហប្រតិបត្តិការពន្ធដារអន្តរជាតិ នៃន.នគសអ បានធ្វើបទបង្ហាញលើប្រធានបទទី១ ស្តីពីវិធាននិងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀង DTA ដោយបានផ្តោតលើចំណុចសំខាន់ៗមានដូចជា ទស្សនទាន និងវឌ្ឍនភាពការងារ DTA របស់កម្ពុជា ដែលលោកស្រីក៏បានជម្រាបជូនដែរថា ទន្ទឹមនឹងអ្វីដែលបានលើកឡើងដោយលោកជំទាវអគ្គនាយករងមានកិច្ចព្រមព្រៀង DTA ចំនួន ២ បានបញ្ចប់ការចរចាជាស្ថាពរត្រឹមកម្រិតបច្ចេកទេស និងកំពុងត្រៀមចុះហត្ថលេខានាពេលខាងមុខ រួមមាន DTA រវាងកម្ពុជា-ឡាវ និងកម្ពុជា-ហ្វីលីពីន។ លោកស្រីក៏បានបកស្រាយអំពីខ្លឹមសារសំខាន់ៗ នៃកិច្ចព្រមព្រៀង DTA ព្រមទាំងវិធាននិងនីតិវិធីនៃការអនុវត្តកិច្ចព្រមព្រៀង DTA ផងដែរ ដែលចំណុចនេះ មានសារៈសំខាន់ខ្លាំងសម្រាប់អ្នកជាប់ពន្ធ ដែលមានបំណងចង់ទទួលបានអត្ថប្រយោជន៍នានាពីកិច្ចព្រមព្រៀង DTA។

បន្ទាប់មកលោក **ហុង សេរីវុឌ្ឍ** ប្រធានការិយាល័យផ្លាស់ប្តូរព័ត៌មាន នៃន.នគសអ បានបន្តធ្វើបទបង្ហាញលើប្រធានបទទី២ ស្តីពីការផ្លាស់ប្តូរព័ត៌មានសម្រាប់គោលបំណងពន្ធ (Exchange of Information-EOI) ដោយបានលើកឡើងអំពីបទដ្ឋានគតិយុត្តនៃការផ្លាស់ប្តូរព័ត៌មាន នីតិវិធីនៃការស្នើសុំព័ត៌មាន និងការទទួលបានការស្នើសុំព័ត៌មានព្រមទាំងការប្រមូលព័ត៌មាន។ តាមរយៈការផ្លាស់ប្តូរព័ត៌មាននេះ ភាគីនៃកិច្ចព្រមព្រៀងអាចស្នើសុំព័ត៌មានរបស់អ្នកជាប់ពន្ធពីគ្នាទៅវិញទៅមក។ បន្ថែមលើនេះ ភាគីនៃកិច្ចព្រមព្រៀង DTA មានកាតព្វកិច្ចស្វែងរក និងប្រមូលព័ត៌មានដើម្បីឆ្លើយតបតាមការស្នើសុំព័ត៌មានពីភាគីនៃកិច្ចព្រមព្រៀងម្ខាងទៀត។ គោលបំណងនៃការផ្លាស់ប្តូរព័ត៌មាន គឺដើម្បីពង្រឹងតម្លាភាពព័ត៌មានពន្ធ កាត់បន្ថយការកិបកេងបន្លំពន្ធ ជំរុញអនុលោមភាពសារពើពន្ធ និងបង្កើនចំណូលពន្ធតាមរយៈការផ្តល់ព័ត៌មានដល់សវនករពន្ធដារ។

បន្ទាប់ពីមានការធ្វើបទបង្ហាញពីវាគ្មិនលើប្រធានបទទាំង ២ ខាងលើរួចមក សិក្ខាសាលាក៏មានរៀបចំវេទិកាសំណួរ-ចម្លើយ ដោយមានការចូលរួមពីសិក្ខាកាមក្នុងការសួរសំណួរយ៉ាងសកម្ម ហើយវាគ្មិនក៏បានផ្តល់នូវចម្លើយយ៉ាងក្បោះក្បាយផងដែរ។

ថ្លែងក្នុងមតិបិទបញ្ចប់អង្គសិក្ខាសាលានេះ លោកបណ្ឌិត **សេខ ជាសិទ្ធ** បានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃន.នគសអ ដែលបានសម្របសម្រួលរៀបចំសិក្ខាសាលានេះឡើងដោយជោគជ័យ និងថ្លែងអំណរគុណចំពោះឯកឧត្តម លោកជំទាវ ឧកញ៉ា លោក លោកស្រី នាងកញ្ញា ដែលជាថ្នាក់ដឹកនាំនិងមន្ត្រីពន្ធដារ ព្រមទាំងតំណាងក្រុមហ៊ុនឯកជននិងភ្នាក់ងារសេវាកម្មពន្ធដារទាំងអស់ ដែលបានចូលរួមនិងលើកឡើងជាមតិយោបល់នានាក្នុងអង្គសិក្ខាសាលានេះ ព្រមទាំងសូមជូនពរប្រកបដោយសុភមង្គលក្នុងក្រុមគ្រួសារ និងជោគជ័យគ្រប់ភារកិច្ច ជួបប្រទះតែនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# វគ្គបណ្តុះបណ្តាលស្តីពី "ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម"



នាព្រឹកថ្ងៃទី១៩ និងទី២៩ ខែសីហា ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ និងនិយ័តករគណនេយ្យនិងសវនកម្ម បានសហការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "**ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម**" ក្រោមអធិបតីភាពឯកឧត្តម **ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម និងឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមពីលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម ថ្នាក់ដឹកនាំ មន្ត្រីពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ និងនិយ័តករគណនេយ្យនិងសវនកម្ម ព្រមទាំងមានការចូលរួមរបស់លោក **សាយ សុខខេង** អគ្គនាយកក្រុមហ៊ុន Digital Finance Consultancy Co., Ltd. (DFC) និងក្រុមការងារក្រុមហ៊ុន DFC សរុបប្រមាណ **១៤០ រូប**។

ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** បានបញ្ជាក់ថា វត្តមានរបស់សិក្ខាកាម ដែលបានចូលរួមវគ្គបណ្តុះបណ្តាលដ៏មានសារៈសំខាន់នេះ គឺឆ្លុះបញ្ចាំងឱ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការពង្រឹង និងបង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈរបស់ខ្លួន ជាពិសេសពាក់ព័ន្ធស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យម សំដៅបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងផលិតភាពការងាររបស់អង្គភាព។ ដោយឡែក ចំពោះវគ្គបណ្តុះបណ្តាលនេះ ពិតជាមានសារៈសំខាន់ចំពោះមន្ត្រីពន្ធដារគ្រប់រូប ដើម្បីបំពេញបន្ថែមលើចំណេះដឹងផ្នែកគណនេយ្យ ដោយហេតុថា ចំណេះដឹងទាំងនេះ មានភាពប្រទាក់ក្រឡាគ្នាទៅនឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធ ដើម្បីធ្វើការវិភាគ និងអនុវត្តបានត្រឹមត្រូវ។ ជាការពិត ចំណេះដឹងទាំងនេះ អាចយកទៅធ្វើការផ្សព្វផ្សាយ ឬបណ្តុះបណ្តាលបន្តក្នុងក្របខ័ណ្ឌនៃការផ្តល់សេវាអ្នកជាប់ពន្ធ ដែលជាមុខងារស្នូលដ៏សំខាន់មួយ ក្នុងចំណោមមុខងារស្នូលទាំងប្រាំរបស់អគ្គនាយកដ្ឋានពន្ធដារ រួមមាន ១.ការចុះបញ្ជីពន្ធដារ ២. ការផ្តល់សេវាអ្នកជាប់ពន្ធ ៣.ការចាត់ចែងលិខិតប្រកាស ៤.ការធ្វើសវនកម្ម និង៥.ការប្រមូលបំណុលពន្ធនិងបណ្តឹងតវ៉ា។ ការផ្តល់សេវាល្អជូនអ្នកជាប់ពន្ធពិតជាមានសារៈសំខាន់

ណាស់ដើម្បីឱ្យអ្នកជាប់ពន្ធរីករាយ និងពេញចិត្តក្នុងការបង់ពន្ធ ព្រោះប្រសិនបើអ្នកជាប់ពន្ធពុំមានអនុលោមភាពដោយស្ម័គ្រចិត្តទេ នោះនឹងមានការពង្រឹងការអនុវត្តច្បាប់ តាមរយៈការធ្វើសវនកម្មជាដើម ដែលអាចនាំឱ្យមានការមិនសប្បាយចិត្តទាំងអស់គ្នារវាងអ្នកជាប់ពន្ធនិងមន្ត្រីពន្ធដារ។ កិច្ចការ នេះទាមទារឱ្យមន្ត្រីពន្ធដារ ក៏ដូចជាមន្ត្រីទទួលបន្ទុកផ្តល់សេវាអ្នកជាប់ពន្ធ ត្រូវខិតខំឈ្វេងយល់និងបន្តពង្រឹង និងកសាងសមត្ថភាពរបស់ខ្លួនជាប្រចាំ ទាំងជំនាញវិជ្ជាជីវៈ ច្បាប់និងបទប្បញ្ញត្តិ បទពិសោធនៃការអនុវត្ត ដូចពាក្យស្លោកបានពោលថា "**រៀនច្រើនកើនចំណេះវិជ្ជា**" និង "**កាន់តែរៀនកាន់តែចេះ**"។

បន្ថែមពីនេះ ឯកឧត្តមបណ្ឌិត បានលើកឡើងពីការណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ឱ្យពង្រឹងសមត្ថភាពមន្ត្រីពន្ធដារ ជាពិសេសក្រមសីលធម៌ វិន័យ និងវិជ្ជាជីវៈ ដោយឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី តែងតែយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍមូលធនមនុស្ស ដែលជាគោលបំណងមួយក្នុងចំណោមគោលបំណងទាំង៣ ដែលបានដាក់ចេញនៅក្នុង "**ផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨**" របស់អគ្គនាយកដ្ឋានពន្ធដារ រួមមាន ១.បង្កើនអនុលោមភាពសារពើពន្ធតាមរយៈការធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាកម្ម ភាពច្បាស់លាស់ តម្លាភាព និងគណនេយ្យភាពក្នុងការផ្តល់សេវានិងការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ ២.បន្តធ្វើបរិវត្តកម្មឌីជីថលរដ្ឋបាលសារពើពន្ធ ដើម្បីក្លាយជារដ្ឋបាលសារពើពន្ធ ២.០ បូក និង៣.បន្តអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងប្រសិទ្ធភាពការងារ។

អគ្គនាយកដ្ឋានពន្ធដារសម្រេចបាននូវសមិទ្ធផលដ៏ល្អប្រសើរក្នុងការគ្រប់គ្រងប្រមូលចំណូលពន្ធកន្លងមក ជាពិសេសការពង្រឹងបាននូវអភិបាលកិច្ច រដ្ឋបាលកិច្ច និងការធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ក៏ដោយសារកត្តាធនធានមនុស្ស ដែលរួមមានថ្នាក់ដឹកនាំ អ្នកគ្រប់គ្រង និងមន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលប្រកាន់ខ្ជាប់នូវអភិក្រមការងារ និងអនុវត្តការងារប្រចាំថ្ងៃយ៉ាងទៀងទាត់ ក្រោមការដឹកនាំ និងគ្រប់គ្រងតាមប្រព័ន្ធគ្រប់គ្រងធនធានមនុស្សច្បាស់លាស់ ដែលធានាបាននូវនិរន្តរភាពនៃលទ្ធផលការងាររបស់មន្ត្រីរាជការពន្ធដារគ្រប់រូប ហើយសបញ្ជាក់ពីប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការគ្រប់គ្រងធនធានមនុស្សនៅអគ្គនាយកដ្ឋានពន្ធដារផងដែរ។ សមិទ្ធផលជាក់ស្តែងដ៏ល្អប្រសើរនេះ បានឆ្លុះបញ្ចាំងនូវកិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តកម្មវិធីកែទម្រង់ផ្នែកធនធានមនុស្ស ដែលប្រកបដោយភាពប្រយ័ត្នប្រយែង និងយកចិត្តទុកដាក់ខ្ពស់ស្របតាមឆន្ទៈនយោបាយយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាល ដែលបានកសាងទំនុកចិត្តពីសាធារណជននៅគ្រប់មជ្ឈដ្ឋានទាំងអស់ ហើយជាពិសេស ទទួលបាននូវការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**។ ដូច្នេះមូលធនមនុស្ស ដើរតួនាទីជាកត្តាគន្លឹះ និងជាកម្លាំងចលករដ៏មានសក្តានុពលក្នុងការអភិវឌ្ឍអង្គភាពក្រសួង ស្ថាប័ន និងប្រទេសជាតិឱ្យសម្រេចបានជោគជ័យ ដូចប្រសាសន៍ដ៏ខ្ពង់ខ្ពស់ និងថ្លៃថ្លារបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានថ្លែងថា "**មូលធនមនុស្ស គឺជាគន្លឹះអាទិភាពសម្រាប់ការកសាងប្រទេសរបស់យើង ព្រោះមនុស្សគឺកំណត់ប្រទេស មនុស្សគឺជាដង្ហើម គឺជាអ្នកអនុវត្តប្រតិបត្តិក្នុងការជំរុញសេដ្ឋកិច្ច ថែទាំវប្បធម៌ ថែទាំប្រពៃណី និងអត្តសញ្ញាណជាតិ**"។ ឯកឧត្តមបណ្ឌិត បានបន្ថែមទៀតថា ក្រោយពីបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងយល់កាន់តែច្បាស់ថែមទៀតនូវស្តង់ដាបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីចូលរួមផ្តល់សេវាអ្នកជាប់ពន្ធ និងការងារគ្រប់គ្រងប្រមូលចំណូលពន្ធឱ្យបានត្រឹមត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារជាធរមាន។

ជាកិច្ចបន្ទាប់ ឯកឧត្តម **ម៉ូ ថារិន** អគ្គនាយក នៃនិយ័តករគណនេយ្យនិងសវនកម្ម បានថ្លែងសុន្ទរកថាបើកវគ្គបណ្តុះបណ្តាល និងបានថ្លែងអំណរគុណចំពោះឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងឯកឧត្តមបណ្ឌិត

អគ្គនាយករង ព្រមទាំងថ្នាក់ដឹកនាំអគ្គនាយកដ្ឋានពន្ធដារទាំងអស់ដែលតែងតែផ្តល់កិច្ចសហការដ៏ល្អ និងបានជួយជ្រោមជ្រែងការអនុវត្តតួនាទី ភារកិច្ចរបស់និយ័តករគណនេយ្យនិងសវនកម្មកន្លងមក។ ដោយឡែកសម្រាប់ការបណ្តុះបណ្តាលស្តង់ដាគណនេយ្យ ជូនមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ និយ័តករគណនេយ្យ និងសវនកម្ម បានរៀបចំបណ្តុះបណ្តាលបានជាច្រើនលើក ដែលមានការបណ្តុះបណ្តាលដោយផ្ទាល់និងតាមប្រព័ន្ធអនឡាញ។ សម្រាប់ផែនការសកម្មភាពរបស់និយ័តករគណនេយ្យនិងសវនកម្មក្នុងឆ្នាំ២០២៤នេះ យើងបានរៀបចំបាន **១ លើក** និងរួមទាំងលើកនេះ គឺមានចំនួន **២ លើក**។ ទន្ទឹមនឹងនេះ និយ័តករគណនេយ្យនិងសវនកម្ម នឹងខិតខំបណ្តុះបណ្តាលបន្តទៀត ប្រសិនបើអគ្គនាយកដ្ឋានពន្ធដារមានតម្រូវការ និងប្រសិនបើមានការប្រែប្រួល កែសម្រួលស្តង់ដាគណនេយ្យសម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលមានការប្រជុំគ្នាជាសកលរៀងរាល់៥ឆ្នាំម្តង។ ឯកឧត្តមបានបញ្ជាក់ថាការបណ្តុះបណ្តាលមូលធនមនុស្សគឺជារឿងចាំបាច់ដែលស្របតាមយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេស ធនធានមនុស្សមានសារៈសំខាន់ជាងធនធានរ៉ែ។ ដូច្នេះការបណ្តុះបណ្តាលនេះ និយ័តករគណនេយ្យនិងសវនកម្ម បានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីរាជការពន្ធដារនាពេលនេះមានសារៈសំខាន់ក្នុងការពង្រឹងសមត្ថភាព និងបង្កើនគុណវុឌ្ឍិក្នុងការកៀរគរចំណូលពន្ធដារ និងទទួលបានគោលការណ៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី ដើម្បីការលើកកម្ពស់ក្នុងក្របខ័ណ្ឌគណនេយ្យ និងសវនកម្ម៕



*ឯកឧត្តម **ប៊ូ ថារិន** អគ្គនាយក
នៃនិយ័តករគណនេយ្យនិងសវនកម្ម*



*ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ**
អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ*



# សិក្ខាសាលាផ្សព្វផ្សាយស្តីពី "បច្ចុប្បន្នភាពនៃវិធានរដ្ឋបាលសារពើពន្ធ គណនេយ្យ និងច្បាប់ពាណិជ្ជកម្មសម្រាប់ធុរកិច្ចជន"




នារសៀលថ្ងៃព្រហស្បតិ៍ ទី២៦ ខែកញ្ញា ឆ្នាំ២០២៤ នៅសាលប្រជុំនៃអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ច អគ្គនាយកដ្ឋានពន្ធដារ (អពដ) បានសហការជាមួយសមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា(CTAFA) ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី **"បច្ចុប្បន្នភាពនៃវិធានរដ្ឋបាលសារពើពន្ធ គណនេយ្យ និងច្បាប់ពាណិជ្ជកម្មសម្រាប់ធុរកិច្ចជន"** ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិត **សេង រតនា** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ តំណាងរបស់ឯកឧត្តម **គង់ វិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម **អ៊ុំ សារ៉ាវុធ** ប្រធានសមាគម CTAFA ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអពដ ថ្នាក់ដឹកនាំនិងសមាជិកនៃសមាគមដែលជាតំណាងក្រុមហ៊ុនភ្នាក់ងារសេវាកម្មពន្ធដារ ចូលរួមដោយផ្ទាល់សរុបចំនួនប្រមាណ **១០០ រូប**។

ជាកិច្ចស្វាគមន៍ ឯកឧត្តម **អ៊ុំ សារ៉ាវុធ** ប្រធានសមាគម CTAFA បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ឯកឧត្តមបណ្ឌិត **សេង រតនា** ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអពដ និងក្រុមការងារសមាគម ដែលបានសហការរៀបចំសិក្ខាសាលានេះឡើង ព្រមទាំងអរគុណដល់សមាជិកទាំងអស់ដែលបានចំណាយពេលវេលាដ៏មមាញឹកចូលរួមសិក្ខាសាលាដ៏មានសារៈសំខាន់នាឱកាសនេះ។ ឯកឧត្តមបានលើកឡើងថា គោលបំណងក្នុងការរៀបចំសិក្ខាសាលានេះឡើង គឺដើម្បីចែករំលែកនូវចំណេះដឹង ការអនុវត្តជាក់ស្តែង ព្រមទាំងធ្វើការផ្សព្វផ្សាយនូវបទប្បញ្ញត្តិស្តីពីពន្ធដារ គណនេយ្យ និងច្បាប់ស្តីពីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ជូនដល់ក្រុមហ៊ុនជាភ្នាក់ងារសេវាកម្មពន្ធដារ អ្នកជាប់ពន្ធ និងសាធារណជន។ ឯកឧត្តមបានបញ្ជាក់ជូនផងដែរថា សមាគមសហព័ន្ធភ្នាក់ងារសេវាកម្មពន្ធដារកម្ពុជា គឺជាសមាគមដែលបង្កើតឡើងមិនស្វែងរកប្រាក់ចំណេញ និងដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ជាពិសេសអគ្គនាយកដ្ឋានពន្ធដារ ធ្វើការផ្សព្វផ្សាយ អប់រំ និងបណ្តុះបណ្តាលនូវបទប្បញ្ញត្តិស្តីពីពន្ធដារ គណនេយ្យ និងច្បាប់ស្តីពីពាណិជ្ជកម្ម ព្រមទាំងជួយជំរុញ និងទាក់ទាញអ្នកវិនិយោគថ្មីៗមកបណ្តាក់ទុនរកស៊ីនៅកម្ពុជា ក្នុងគោលដៅជានាឱ្យបាននូវចីរភាព និងវឌ្ឍនភាពនៃសេដ្ឋកិច្ចនៅប្រទេសកម្ពុជាឱ្យកាន់តែប្រសើរឡើង។

ជាកិច្ចបន្ទាប់ ឯកឧត្តមបណ្ឌិត **សេង រតនា** បានថ្លែងសុន្ទរកថាបើកសិក្ខាសាលា និងបានសម្តែងនូវកិច្ចស្វាគមន៍យ៉ាង

កក់ក្តៅចំពោះវត្តមានចូលរួមរបស់ឯកឧត្តម លោកជំទាវ ឧកញ៉ា លោក-លោកស្រីនាងកញ្ញាទាំងអស់ ដែលបានចំណាយពេលវេលាដ៏មមាញឹកអញ្ជើញចូលរួមសិក្ខាសាលាដ៏មានសារៈសំខាន់នាឱកាសពេលនេះ ជាពិសេស ឯកឧត្តម **អ៊ុំ សារ៉ាវុធ** ប្រធានសមាគម CTAFA ថ្នាក់ដឹកនាំ និងក្រុមការងារ ដែលបានសហការរៀបចំសិក្ខាសាលានេះឡើង ដោយផ្តោតសំខាន់លើប្រធានបទពាក់ព័ន្ធនឹងបទប្បញ្ញត្តិស្តីពីពន្ធដារ គណនេយ្យ និងច្បាប់ស្តីពីពាណិជ្ជកម្ម។ ឯកឧត្តមបណ្ឌិតបានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលថ្មី នីតិកាលទី៧ នៃរដ្ឋសភា ដឹកនាំប្រកបដោយគតិបណ្ឌិត និងសក្តានុពលរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ដែលមានបញ្ចកោណសំខាន់ទាំង៥រួមមាន៖ ១.ការអភិវឌ្ឍមូលធនមនុស្ស ២.ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការបង្កើនភាពប្រកួតប្រជែង ៣.ការអភិវឌ្ឍវិស័យឯកជន និងការងារ ៤.ការអភិវឌ្ឍប្រកបដោយភាពធន់ ចីរភាព និងបរិយាបន្ន និង៥.ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ ក្នុងនោះស្នូលនៃយុទ្ធសាស្ត្រគឺ៖ ការកែទម្រង់ និងការពង្រឹងអភិបាលកិច្ច ដែលតាមរយៈនៃយុទ្ធសាស្ត្រនេះ អពដ បានដើរមុនមួយជំហ៊ានដោយបានធ្វើកំណែទម្រង់ និងធ្វើទំនើបកម្មរដ្ឋបាលសារពើពន្ធ ច្បាប់ស្តីពីសារពើពន្ធ និងប្រព័ន្ធពន្ធដារកម្ពុជា ដែលនាំឱ្យលទ្ធផលនៃការប្រមូលចំណូលពន្ធដារ សម្រេចបានលើសផែនការកំណត់ដោយច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជាបន្តបន្ទាប់ចាប់តាំងពីឆ្នាំ២០១២រហូតមកដល់បច្ចុប្បន្ន(ជាង១០ឆ្នាំ)បើទោះបីជាមានវិបត្តិសកលនៃជំងឺកូវីដ-១៩សង្គ្រាមរុស្ស៊ី-អ៊ុយក្រែននិងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចសកលក៏ដោយ។ក្រោមការដឹកនាំប្រកបដោយភាពឈ្លាសវៃ បុរេសកម្ម និងប៉ិនប្រសព្វរបស់ឯកឧត្តម **គន់ និមល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី បានធ្វើឱ្យ អពដ ក្លាយជាស្ថាប័នរដ្ឋមួយដែលឈានមុខគេ ដែលបានដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជាច្រើន ដូចជា ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធអាជីវកម្មតាមអនឡាញ ប្រព័ន្ធគ្រប់គ្រងការបង់ប្រាក់ពន្ធតាមអនឡាញ និងកម្មវិធីអេឡិចត្រូនិកផ្សេងៗទៀត ជាក់ស្តែងថ្មីៗនេះ អពដបានដាក់ឱ្យប្រើប្រាស់កម្មវិធីលិខិតរដ្ឋបាលអេឡិចត្រូនិកពន្ធដារ(GDT e-Administration) ដែលអ្នកជាប់ពន្ធអាចដាក់លិខិតរដ្ឋបាល លិខិតតវ៉ា ឬលិខិតផ្សេងៗតាមប្រព័ន្ធអនឡាញបាន ដែលប្រព័ន្ធទាំងអស់នេះត្រូវបានបង្កើតឡើងដោយធនធានមនុស្សរបស់អពដ ក្រោមការដឹកនាំផ្ទាល់របស់ឯកឧត្តម **គន់ និមល** តែម្តង។ ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមបណ្ឌិតបានផ្តល់នូវបទបង្ហាញពាក់ព័ន្ធនឹងបច្ចុប្បន្នភាពរបស់អពដ ដោយផ្តោតសំខាន់ទៅលើ ចក្ខុវិស័យនិងបេសកកម្ម ការប្រមូលចំណូលពន្ធដារ កំណែទម្រង់ និងផែនការសកម្មភាពរបស់អពដ ជូនដល់សិក្ខាកាមដែលបានចូលរួមផងដែរ។ បន្ថែមពីនេះ ឯកឧត្តមបណ្ឌិតក៏បានគូសបញ្ជាក់ផងដែរថា សិក្ខាសាលានេះជាផ្នែកមួយនៃយុទ្ធសាស្ត្រស្នូលរបស់អពដ ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធឱ្យយល់ច្បាស់ពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ដើម្បីអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ព្រោះរបបពន្ធនៅកម្ពុជាជារបបស្វ័យប្រកាស ដែលមានន័យថាអ្នកជាប់ពន្ធត្រូវគណនា បំពេញលិខិតប្រកាស និងបង់ប្រាក់ពន្ធ ដោយខ្លួនឯង។ ដូច្នេះ អពដ សូមស្វាគមន៍ដល់គ្រប់សមាគមនិងអ្នកជាប់ពន្ធទាំងអស់ ក្នុងការអញ្ជើញមន្ត្រីជំនាញនៃអពដឱ្យធ្វើបទបង្ហាញអំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ដែលអ្នកជាប់ពន្ធនៅមានភាពមិនច្បាស់លាស់ក្នុងការអនុវត្ត។ ជាចុងក្រោយ ឯកឧត្តមបណ្ឌិតបានក្រើនរំលឹកដល់អ្នកជាប់ពន្ធទាំងអស់ត្រូវធ្វើការឈ្វេងយល់អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារដែលពិតជាមានសារៈសំខាន់ណាស់សម្រាប់អ្នកជាប់ពន្ធ ដើម្បីអាចអនុវត្តឱ្យបានត្រឹមត្រូវ និងចៀសវាងបានពីការអនុវត្តខុសច្បាប់ ដែលនាំឱ្យមានការដាក់ទណ្ឌកម្មផ្សេងៗ ដោយរដ្ឋបាលសារពើពន្ធ ហើយរដ្ឋបាលសារពើពន្ធមិនមានបំណងចង់ដាក់ទណ្ឌកម្មដល់អ្នកជាប់ពន្ធនោះទេ ដូច្នេះហើយទើបខិតខំប្រឹងប្រែងក្នុងការផ្តល់សេវាអប់រំ បណ្តុះបណ្តាល ឬការប្រឹក្សាយោបល់អំពីច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារ ជូនដល់អ្នកជាប់ពន្ធជាប្រចាំដោយយកចិត្តទុកដាក់ខ្ពស់និងដោយឥតគិតថ្លៃ។

ជាកិច្ចបញ្ចប់ ឯកឧត្តមបណ្ឌិត **អេង រតនា** បានបញ្ជាក់ជូនថាអពដ នឹងបន្តផ្តល់កិច្ចសហការជាមួយគ្រប់បណ្តាសមាគមទាំងអស់ ហើយសមាគម CTAFA នឹងក្លាយជាដៃគូសហការក្នុងការជំរុញការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារឱ្យបានកាន់តែល្អប្រសើរថែមទៀតនិងសូមជូនពរថ្នាក់ដឹកនាំក្រុមការងារនិងសិក្ខាកាមទាំងអស់សូមជួបប្រទះតែពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ៕

# សិក្ខាសាលាតាមខេត្ត-ខណ្ឌ

នាថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌ៧មករា** នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម សហការជាមួយសាខាពន្ធដារខណ្ឌ៧មករា បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី"បញ្ជីគណនេយ្យសាមញ្ញ កាតព្វកិច្ចសារពើពន្ធប្រចាំខែនិងប្រចាំឆ្នាំ និងកម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)" សម្រាប់អ្នកជាប់ពន្ធ ក្រោមអធិបតីភាពលោក **ម៉េង មិនា** អនុប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម៕



នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពង់ស្ពឺ** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស" សម្រាប់អ្នកជាប់ពន្ធ ក្រោមអធិបតីភាពលោក **គង់ សុគន្ធ** អនុប្រធានសាខាពន្ធដារខេត្តកំពង់ស្ពឺ៕



នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តព្រៃវែង** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) វិធាននៃការប្រើប្រាស់វិក្កយបត្រ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" សម្រាប់អ្នកជាប់ពន្ធ ក្រោមអធិបតីភាព លោក **សេក វណ្ណា** អនុប្រធានសាខាពន្ធដារខេត្តព្រៃវែង៕



នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកណ្តាល** មានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "កាតព្វកិច្ចពន្ធកាត់ទុកទូទៅ និងការដាក់លិខិតរដ្ឋបាលនានាតាមរយៈកម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (GDT e-Administration)" សម្រាប់អ្នកជាប់ពន្ធ ក្រោមអធិបតីភាព លោក **តៅ តៃហុក** អនុប្រធានសាខាពន្ធដារខេត្តកណ្តាល៕



នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តបន្ទាយមានជ័យ** បានរៀបចំសិក្ខាសាលា ស្តីពី "កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) និងវិធាននៃការប្រើប្រាស់វិក្កយបត្រ" សម្រាប់អ្នកជាប់ពន្ធ ក្រោមអធិបតីភាពលោក **ឡាយ ហុង** អនុប្រធានសាខាពន្ធដារខេត្តបន្ទាយមានជ័យ៕



នាថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តពោធិ៍សាត់** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App) និងវិធាននៃការប្រើប្រាស់វិក្កយបត្រ" សម្រាប់អ្នកជាប់ពន្ធក្រោមអធិបតីភាពលោក **ផាន ភក្តី** អនុប្រធានសាខាពន្ធដារខេត្តពោធិ៍សាត់៕



នាថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តស្ទឹងត្រែង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ពន្ធលើមធ្យោបាយដឹកជញ្ជូន និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" ជូនដល់តំណាងមន្ទីរ-អង្គភាពពាក់ព័ន្ធ ក្រោមអធិបតីភាពលោក **ថន ម៊ុនយ៉ន** ប្រធានសាខាពន្ធដារខេត្តស្ទឹងត្រែង៕



នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌ៧មករា** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ពន្ធលើអចលនទ្រព្យនិងពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ" ជូនដល់មេភូមិ និងចៅសង្កាត់ទាំង ៨ ក្នុងមូលដ្ឋានខណ្ឌ៧មករា ក្រោមអធិបតីភាពលោក **សិញ្ញ សេងហោ** ប្រធានសាខាពន្ធដារខណ្ឌ៧មករា៕



នាថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពត** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ការដាក់លិខិតប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ សម្រាប់សហគ្រាសលទ្ធកម្មសាធារណៈ" ជូនតំណាងសហគ្រាសក្រោមអធិបតីភាពលោក **ហៀន សុខលី** ប្រធានសាខាពន្ធដារខេត្តកំពត៕



នាថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តកំពង់ស្ពឺ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ពន្ធលើប្រាក់បៀវត្ស" ជូនតំណាងមន្ទី-អង្គភាពជុំវិញរដ្ឋបាលខេត្តកំពង់ស្ពឺ ក្រោមអធិបតីភាពលោក **ម៉ែត ចក់** ប្រធានសាខាពន្ធដារខេត្តកំពង់ស្ពឺ៕



នាថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពី "ការពង្រឹងក្រមសីលធម៌សវនករពន្ធដារ និងការអនុវត្តកម្មវិធីសវនកម្ម" ជូនថ្នាក់ដឹកនាំនិងសវនករនៃសាខាពន្ធដារខណ្ឌមានជ័យ ក្រោមអធិបតីភាពលោក **ជ័យ រិទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម និងលោកស្រី **គាន រ៉ាមី** ប្រធានសាខាពន្ធដារខណ្ឌមានជ័យ៕



នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តព្រៃវែង** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្តីពី "ទោសប្បញ្ញត្តិស្តីពីពន្ធដារ និងអាករលើតម្លៃបន្ថែម" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធមធ្យមក្រោមអធិបតីភាពលោក **សំ សារ៉ាវុធ** អនុប្រធានសាខាពន្ធដារខេត្តព្រៃវែង៕



នាថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "សិទ្ធិនិងកាតព្វកិច្ចអ្នកជាប់ពន្ធ បញ្ជីគណនេយ្យសាមញ្ញ វិធាននៃការប្រើប្រាស់វិក្កយបត្រ និងកម្មវិធីវិក្កយបត្រនាំសំណាង" ជូនតំណាងសហគ្រាសជាអ្នកជាប់ពន្ធតូច ដែលទើបចុះបញ្ជីពន្ធដារថ្មី ក្រោមអធិបតីភាពលោក **មុត ណុច** ប្រធានសាខាពន្ធដារខណ្ឌពោធិ៍សែនជ័យ៕



នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខេត្តបន្ទាយមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "ពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យ ពន្ធលើអចលនទ្រព្យ ពន្ធលើដីធ្លីមិនបានប្រើប្រាស់និងពន្ធលើចំណេញមូលធន" ជូនអាជ្ញាធរក្នុងមូលដ្ឋានខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពលោក **ព្រឹម សាលី** ប្រធានសាខាពន្ធដារខេត្តបន្ទាយមានជ័យ៕



នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារខណ្ឌមានជ័យ** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "សិទ្ធិនិងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ការអនុវត្តវិធាននៃការប្រើប្រាស់វិក្កយបត្រ និងកម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាពលោកស្រី **គាន រ៉ាមី** ប្រធានសាខាពន្ធដារខណ្ឌមានជ័យ៕



នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២៤ នៅ **សាខាពន្ធដារចំការមន** បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ ស្ដីពី "ប្រព័ន្ធគ្រប់គ្រងការដាក់លិខិតប្រកាសពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំតាមអនឡាញ (ToI e-Filing) លើមុខងារ កែតម្រូវលិខិតប្រកាស" ជូនតំណាងសហគ្រាស ក្រោមអធិបតីភាពលោក **ប៉េង ឆុង** ប្រធានសាខាពន្ធដារខណ្ឌចំការមន៕



## កម្មវិធីទូរស័ព្ទដៃពេញនិយមទាំង ១០ របស់អគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)**
សម្រាប់បង់ពន្ធលើអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើផ្ទាំងផ្សព្វផ្សាយ

**កម្មវិធីប្រកាសពន្ធសម្រាប់អ្នកជាប់ពន្ធតូច (GDT Tax Prefiling App)**
សម្រាប់ប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ របស់សហគ្រាសដែលជាអ្នកជាប់ពន្ធតូច

**កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ (GDT Check & Track App)**
សម្រាប់តាមដានឯកសារដែលបានដាក់ស្នើមករដ្ឋបាលសារពើពន្ធ ពិនិត្យភាពត្រឹមត្រូវនៃឯកសារដែលមាន QR Code ចេញដោយអគ្គនាយកដ្ឋានពន្ធដារ

**កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (GDT Salary Tax Calculation App)**
សម្រាប់គណនាពន្ធលើប្រាក់បៀវត្សប្រចាំខែដែលត្រូវបង់

**កម្មវិធីគណនាពន្ធលើមធ្យោបាយដឹកជញ្ជូន (GDT Means of Transportation Tax Calculation App)**
សម្រាប់គណនាប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូន ដែលត្រូវបង់ប្រាក់ពន្ធប្រចាំឆ្នាំ

**ព័ត៌មានពន្ធដារ (GDT News App)**
សម្រាប់ទទួលបានព័ត៌មាន វគ្គបណ្តុះបណ្តាល សិក្ខាសាលា ច្បាប់និងលិខិតបទដ្ឋានគតិយុត្ត វីដេអូផ្សេងៗទៀតស្តីពីពន្ធដារ...

**កម្មវិធីជជែកផ្ទាល់ជាមួយពន្ធដារ (GDT Live Chat App)**
សម្រាប់សាកសួរព័ត៌មានផ្សេងៗស្តីពីពន្ធដារ (ផ្នែកពន្ធទូទៅ និង e-Tax Service)

**ប្រតិទិនពន្ធដារ (GDT Calendar App)**
អាចពិនិត្យកាលបរិច្ឆេទដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធប្រចាំខែ និងឆ្នាំ

**កម្មវិធីសទ្ទានុក្រមពន្ធដារ (Tax Glossary App)**
សម្រាប់ស្វែងរកពាក្យគន្លឹះផ្សេងៗស្តីពីពន្ធដារ

**កម្មវិធីវិក្កយបត្រនាំសំណាង (GDT Lucky Draw App)**
សម្រាប់បញ្ចូលវិក្កយបត្រ ដើម្បីចូលរួមផ្សងសំណាងឈ្នះរង្វាន់ជាច្រើនពីអគ្គនាយកដ្ឋានពន្ធដារ

## តើលោក-លោកស្រី បានឈ្វេងយល់អំពីព្រឹត្តិបត្រនេះបានកម្រិតណាដែរ? លោក-លោកស្រី អាចសាកល្បងឆ្លើយនូវសំណួរខាងក្រោម៖

១. តើការបើកការដ្ឋានសាងសង់ព្រែកជីកហ្វូណនតេជោ ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ បានប្រារព្ធធ្វើនៅថ្ងៃ ខែ ឆ្នាំណា?

- ក. ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤
- គ. ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤
- ខ. ថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤
- ឃ. ថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤

២. តើទស្សនិកជនអាចលើកជាសំណួរក្នុងកម្មវិធីពន្ធដារកម្ពុជាបានដោយរបៀបណា?

- ក. ១២៧៧
- គ. Comment ក្នុង Facebook page
- ខ. GDT Live Chat
- ឃ. ចម្លើយទាំងអស់ត្រឹមត្រូវ

៣. តើអ្នកជាប់ពន្ធ អាចបង់ពន្ធអចលនទ្រព្យ ពន្ធលើមធ្យោបាយដឹកជញ្ជូន និងពន្ធលើផ្ទាំងផ្សព្វផ្សាយតាមរយៈកម្មវិធីមួយណា?

- ក. GDT Taxpayer App
- គ. GDT Check and Track App
- ខ. GDT News App
- ឃ. GDT Lucky Draw App

៤. តើចំណូលតាមប្រភេទអ្នកជាប់ពន្ធមួយណាដែលដើរតួនាទីស្នូលនៃចំណូលពន្ធដារ?

- ក. អ្នកជាប់ពន្ធតូច
- គ. អ្នកជាប់ពន្ធមធ្យម
- ខ. អ្នកជាប់ពន្ធធំ
- ឃ. អ្នកជាប់ពន្ធផ្សេងៗទៀត

៥. តើអ្នកជាប់ពន្ធតូច អាចបំពេញកាតព្វកិច្ចពន្ធតាមរយៈកម្មវិធីឈ្មោះអ្វី?

- ក. GDT Lucky Draw App
- គ. GDT Tax Prefiling App
- ខ. GDT Live Chat
- ឃ. GDT Taxpayer App

៦. តើកម្មវិធី "ពន្ធដារកម្ពុជា" ធ្វើការផ្សាយផ្ទាល់នៅរៀងរាល់ថ្ងៃណា?

- ក. រៀងរាល់ថ្ងៃព្រហស្បតិ៍
- គ. រៀងរាល់ថ្ងៃពុធ
- ខ. រៀងរាល់ថ្ងៃអង្គារ
- ឃ. រៀងរាល់ថ្ងៃសុក្រ

៧. តើប្រភពព័ត៌មានសំខាន់ៗរបស់អគ្គនាយកដ្ឋានពន្ធដារមានអ្វីខ្លះ?

- ក. គេហទំព័រអគ្គនាយកដ្ឋានពន្ធដារ
- គ. ខិត្តប័ណ្ណផ្សព្វផ្សាយ
- ខ. ទំព័រហ្វេសប៊ុកផ្លូវការ និងតេលេក្រាម
- ឃ. ចម្លើយទាំងអស់ត្រឹមត្រូវ

៨. តើអគ្គនាយកដ្ឋានពន្ធដារមានប្រព័ន្ធឬកម្មវិធីសម្រាប់អ្នកជាប់ពន្ធតាមដានឯកសារដែលស្នើសុំមករដ្ឋបាលសារពើពន្ធដែរឬទេ? បើមានឈ្មោះអ្វី?

- ក. មាន កម្មវិធីត្រួតពិនិត្យនិងតាមដានឯកសារ GDT Check & Track App
- ខ. មិនមាន អ្នកជាប់ពន្ធត្រូវមកជួបមន្ត្រីពន្ធដារដោយផ្ទាល់

៩. តើក្នុងត្រីមាសទី៣ ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារ បានរៀបចំកម្មវិធីពន្ធដារកម្ពុជា បានសរុបប៉ុន្មានលើក?

- ក. ១៥ លើក
- ខ. ២៥ លើក
- គ. ៨ លើក
- ឃ. ១៣ លើក

១០. តើពន្ធលើមធ្យោបាយដឹកជញ្ជូនឆ្នាំ២០២៤ ចាប់ផ្តើមប្រមូលពីពេលណា ដល់ពេលណា?

- ក. ចាប់ប្រមូលពីថ្ងៃទី១ ខែមិថុនា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤
- ខ. ចាប់ប្រមូលពីថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤

១១. តើ Call Center មានលេខប៉ុន្មាន?

- ក. ១២៧៧
- ខ. ១២៧២
- គ. ១២២២
- ឃ. ១២៥២

១២. តើចំណូលតាមប្រភេទពន្ធមួយណាដែលដើរតួនាទីស្នូលនៃចំណូលពន្ធដារ នៅក្នុងរយៈពេល ៩ខែដើមឆ្នាំ២០២៤?

- ក. ពន្ធលើអចលនទ្រព្យ
- ខ. ពន្ធលើផ្ទាំងផ្សព្វផ្សាយ
- គ. អាករលើតម្លៃបន្ថែម
- ឃ. ពន្ធលើប្រាក់ចំណូល

១៣. តើលោកអ្នកអាចបញ្ចូលវិក្កយបត្រដើម្បីចូលរួមផ្សងសំណាងតាមរយៈកម្មវិធីឈ្មោះអ្វី?

- ក. GDT News App
- ខ. GDT Lucky Draw App
- គ. Tax Glossary App
- ឃ. GDT Check and Track App

ចម្លើយ

| សំណួរ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ចម្លើយ | ខ | ឃ | ក | ខ | គ | ក | ឃ | ក | ឃ | ក | ក | ឃ | ខ |




# អគ្គនាយកដ្ឋានពន្ធដារ
# សូមស្វាគមន៍

## សូមទូរស័ព្ទទៅកាន់ **១២៧៧** រួចចុច **លេខតំណភ្ជាប់របស់អង្គភាព**
## (ដោយមិនចាំបាច់ជ្រើសរើសភាសា)
## ដើម្បីទាក់ទងទៅកាន់នាយកដ្ឋាន ឬសាខាពន្ធដារខេត្ត-ខណ្ឌ
## **ដោយឥតគិតថ្លៃ**

អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
សារអេឡិចត្រូនិក: gdt@tax.gov.kh លេខទូរស័ព្ទ: (855) 23 266 668

# អាសយដ្ឋាននាយកដ្ឋាន សាលាជាតិពន្ធដារ ទីចាត់ការពន្ធដាររាជធានីភ្នំពេញ និងសាខាពន្ធដារខេត្ត-ខណ្ឌ

## នាយកដ្ឋានថ្នាក់កណ្តាល សាលាជាតិពន្ធដារ និងទីចាត់ការពន្ធដាររាជធានីភ្នំពេញ

### នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១០៩៩
សារអេឡិចត្រូនិក: admin.info@tax.gov.kh

### នាយកដ្ឋានហិរញ្ញវត្ថុ និងបុគ្គលិក
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ១៨០០
សារអេឡិចត្រូនិក: dfp@tax.gov.kh

### នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២១០០
សារអេឡិចត្រូនិក: dlpic@tax.gov.kh

### នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ២៧០១
សារអេឡិចត្រូនិក: dpt@tax.gov.kh

### នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៨០១៤
សារអេឡិចត្រូនិក: dit@tax.gov.kh

### នាយកដ្ឋានស៊ើបអង្កេតបទល្មើសពន្ធដារ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣២០១
សារអេឡិចត្រូនិក: dtci@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៣៦០១
សារអេឡិចត្រូនិក: dlt@tax.gov.kh

### នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូចនិងមធ្យម
អគារជាន់ទី១៩ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៤៩០០
សារអេឡិចត្រូនិក: dsmt@tax.gov.kh

### នាយកដ្ឋានសវនកម្មសហគ្រាស
អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៥៦០០
សារអេឡិចត្រូនិក: dea@tax.gov.kh

### សាលាជាតិពន្ធដារ
អគារលេខ៤១-៤៣ ផ្លូវ១១២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ (ខាងកើតអគ្គនាយកដ្ឋានពន្ធដារ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៤០១
សារអេឡិចត្រូនិក: nts@tax.gov.kh

### ទីចាត់ការពន្ធដាររាជធានីភ្នំពេញ
អគារជាន់ទី១៨ ផ្លូវ១០២ មជ្ឈមណ្ឌលភ្នំពេញ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៦៨០១
សារអេឡិចត្រូនិក: ppmd@tax.gov.kh

## សាខាពន្ធដារខណ្ឌ

### សាខាពន្ធដារ ខណ្ឌឫស្សីកែវ
អគារ១០២ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០០៧
សារអេឡិចត្រូនិក: russeykeo@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដូនពេញ
ផ្ទះលេខ១៦៦ ផ្លូវលេខ១៣០ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៣២
សារអេឡិចត្រូនិក: daunpenh@tax.gov.kh

### សាខាពន្ធដារ ខណ្ឌ៧មករា
ដីឡូលេខ០៥ ផ្លូវលេខ១៥០ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៥៧
សារអេឡិចត្រូនិក: 7makara@tax.gov.kh

### សាខាពន្ធដារ ខណ្ឌមានជ័យ
អគារលេខ៣៤C ផ្លូវ៣៦១ កែងផ្លូវ៦៤២ សង្កាត់ច្បារអំពៅ១ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩០៨៣
សារអេឡិចត្រូនិក: meanchey@tax.gov.kh

### សាខាពន្ធដារ ខណ្ឌចំការមន
អគារលេខ២៨ ផ្លូវលេខ៤៨៨ សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១០៩
សារអេឡិចត្រូនិក: chamkarmorn@tax.gov.kh

### សាខាពន្ធដារ ខណ្ឌទួលគោក
ផ្ទះលេខ២៤ ផ្លូវ២៨៧ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៣៥
សារអេឡិចត្រូនិក: tuolkork@tax.gov.kh

### សាខាពន្ធដារ ខណ្ឌដង្កោ

ផ្លូវ២១៧ ភូមិរលួស សង្កាត់ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៦១
សារអេឡិចត្រូនិក: dangkor@tax.gov.kh

### សាខាពន្ធដារ ខណ្ឌសែនសុខ

អគារលេខ៩ ផ្លូវលេខ១០១៩(ហាណូយ) សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩១៨៨
សារអេឡិចត្រូនិក: sensok@tax.gov.kh

### សាខាពន្ធដារ ខណ្ឌពោធិ៍សែនជ័យ

ផ្ទះលេខ២៣៤B ផ្លូវលេខ ២០០៧ សង្កាត់កាកាប១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២១៣
សារអេឡិចត្រូនិក: porsenchey@tax.gov.kh

## សាខាពន្ធដារខេត្ត

### សាខាពន្ធដារ ខេត្តបន្ទាយមានជ័យ

ភូមិក្បាលស្ពាន សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ(ខាងត្បូងស្ពានសែសិបចំងាយ ៣០០ម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ៥ ឆ្ពោះទៅកាន់ស្រុកមង្គលបូរី)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧០៨
សារអេឡិចត្រូនិក: banteaymeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តបាត់ដំបង

ផ្ទះលេខ២ ផ្លូវជាតិលេខ៥ សង្កាត់រតនៈ ក្រុងបាត់ដំបង ខេត្តបាត់ដំបង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៩២
សារអេឡិចត្រូនិក: battambang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ចាម

ផ្ទះលេខ៥ ភូមិទី១៥ ផ្លូវខេមរភូមិន្ទ សង្កាត់កំពង់ចាម ក្រុងកំពង់ចាម ខេត្តកំពង់ចាម
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៦៥
សារអេឡិចត្រូនិក: kampongcham@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ឆ្នាំង

ភូមិឃ្លាំងប្រាក់ សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៧៣
សារអេឡិចត្រូនិក: kampongchhnang@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ធំ

ភូមិបល្ល័ង្កលិច សង្កាត់ដំរីជាន់ខ្លា ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៦៩
សារអេឡិចត្រូនិក: kampongthom@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពង់ស្ពឺ

ផ្លូវជាតិលេខ៤ ភូមិត្រពាំងលើក សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៩៩
សារអេឡិចត្រូនិក: kampongspeu@tax.gov.kh

### សាខាពន្ធដារ ខេត្តកំពត

ផ្លូវលេខ៧២៩ ភូមិ១ឧសភា សង្កាត់កំពង់កណ្តាល ក្រុងកំពត ខេត្តកំពត
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥២៦
សារអេឡិចត្រូនិក: kampot@tax.gov.kh

### សាខាពន្ធដារ ខេត្តកណ្តាល

អគារលេខ២២៦ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្តាល
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩២៣៩
សារអេឡិចត្រូនិក: kandal@tax.gov.kh

### សាខាពន្ធដារ ខេត្តកោះកុង

អគារកែងផ្លូវលេខ៩០០ និងផ្លូវលេខ៩៩៥ ភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៧៧
សារអេឡិចត្រូនិក: kohkong@tax.gov.kh

### សាខាពន្ធដារ ខេត្តក្រចេះ

ភូមិក្រចេះ សង្កាត់ក្រចេះ ក្រុងក្រចេះ ខេត្តក្រចេះ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៣០
សារអេឡិចត្រូនិក: kratie@tax.gov.kh

### សាខាពន្ធដារ ខេត្តមណ្ឌលគិរី

ផ្លូវលេខ ៣៧៦៣ ភូមិកណ្តាល សង្កាត់ស្ពានមានជ័យ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៨១
សារអេឡិចត្រូនិក: mondulkiri@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រៃវែង

អាគារកែងផ្លូវលេខ៥ និងផ្លូវលេខ៣ ភូមិ២ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣១៨
សារអេឡិចត្រូនិក: preyveng@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះវិហារ

ភូមិអណ្តូងពោធិ៍ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦០៤
សារអេឡិចត្រូនិក: preahvihear@tax.gov.kh

### សាខាពន្ធដារ ខេត្តពោធិ៍សាត់

ផ្លូវជាតិលេខ៥ ភូមិមាន់ចៃ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤៤៧
សារអេឡិចត្រូនិក: pursat@tax.gov.kh

### សាខាពន្ធដារ ខេត្តរតនគិរី

ផ្លូវលេខ ២០ ភូមិថ្មដា សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៦៥៥
សារអេឡិចត្រូនិក: ratanakiri@tax.gov.kh

### សាខាពន្ធដារ ខេត្តសៀមរាប

ផ្លូវជាតិលេខ 6 ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៤៣
សារអេឡិចត្រូនិក: siamreap@tax.gov.kh

### សាខាពន្ធដារ ខេត្តព្រះសីហនុ

វិថី ២៨មិថុនា ភូមិ០១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៥៥២
សារអេឡិចត្រូនិក: preahsihanouk@tax.gov.kh

### សាខាពន្ធដារ ខេត្តស្ទឹងត្រែង

ផ្លូវភូមិស្ពានថ្ម សង្កាត់ស្ទឹងត្រែង ក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៣៣
សារអេឡិចត្រូនិក: stoengtreng@tax.gov.kh

### សាខាពន្ធដារ ខេត្តស្វាយរៀង

ផ្លូវលេខ១១៤ ភូមិរពងបន្លែ សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៤២១
សារអេឡិចត្រូនិក: svayrieng@tax.gov.kh

### សាខាពន្ធដារ ខេត្តតាកែវ

ភូមិ១ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៣៩៦
សារអេឡិចត្រូនិក: takeo@tax.gov.kh

### សាខាពន្ធដារ ខេត្តឧត្តរមានជ័យ

អគារខាងលិចសាលាខេត្ត ទល់មុខវិមានឯករាជ្យ ភូមិបុរីរដ្ឋបាល សង្កាត់សំរោង ក្រុងសំរោង ខេត្តឧត្តរមានជ័យ
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨១១
សារអេឡិចត្រូនិក: odormeanchey@tax.gov.kh

### សាខាពន្ធដារ ខេត្តកែប

ផ្លូវលេខ២៣៥០ ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៥៩
សារអេឡិចត្រូនិក: kep@tax.gov.kh

### សាខាពន្ធដារ ខេត្តប៉ៃលិន

ភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៧៨៥
សារអេឡិចត្រូនិក: pailin@tax.gov.kh

### សាខាពន្ធដារ ខេត្តត្បូងឃ្មុំ

ភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ (ជាប់ខាងត្បូងសាលាឧទ្ទរណ៍ខេត្តត្បូងឃ្មុំ)
លេខទំនាក់ទំនង: សូមទូរស័ព្ទទៅកាន់ ១២៧៧ រួចចុច ៩៨៣៧
សារអេឡិចត្រូនិក: tboungkhmum@tax.gov.kh

## កម្មវិធីរៀនអំពីពន្ធដារតាមអនឡាញ (GDT E-Learning)

អគ្គនាយកដ្ឋានពន្ធដារ បានបង្កើតឱ្យមានកម្មវិធី "រៀនអំពីពន្ធដារតាមអនឡាញ (GDTE-Learning)" ដែលជាកម្មវិធីសិក្សាពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិកតាមរយៈវីដេអូបង្រៀនអំពីពន្ធអាករគ្រប់ប្រភេទ ដោយមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានពន្ធដារ និងមានការចាក់ផ្សាយជារៀងរាល់សប្តាហ៍នៅថ្ងៃអង្គារ វេលាម៉ោង ១១:៣០នាទីព្រឹក។

សូមស្កែន ដើម្បីចូលទៅកាន់ (Youtube Channel) អគ្គនាយកដ្ឋានពន្ធដារ




## កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App)

សូមស្កែនដើម្បីទស្សនាវីដេអូណែនាំកម្មវិធីទូរស័ព្ទដៃសម្រាប់អ្នកជាប់ពន្ធ GDT Taxpayer App




កម្មវិធីទូរស័ព្ទដៃអ្នកជាប់ពន្ធ (GDT Taxpayer App) គឺជាកម្មវិធីទូរស័ព្ទដៃដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ អាចបង់ពន្ធនៅគ្រប់ទីកន្លែងបានតាមទូរស័ព្ទលើប្រភេទពន្ធមួយចំនួនដូចជា ៖

- ពន្ធលើអចលនទ្រព្យ
- ពន្ធលើមធ្យោបាយដឹកជញ្ជូន និង
- ពន្ធលើផ្ទាំងផ្សព្វផ្សាយ។

សូមធ្វើការទាញយកកម្មវិធី GDT Taxpayer App ដើម្បីងាយស្រួលក្នុងការបង់ពន្ធ៕

# មជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទរបស់អគ្គនាយកដ្ឋានពន្ធដារ (១២៧៧) មានចម្ងល់ពីពន្ធដារ មិនដឹងសួរនៅទីណាមែនទេ?

លោកអ្នកអាចទទួលសេវាពិគ្រោះយោបល់តាមទូរស័ព្ទដោយទាក់ទងមកលេខ ១២៧៧ ដោយឥតគិតថ្លៃ រៀងរាល់ថ្ងៃនិងម៉ោងធ្វើការ ដើម្បីសាកសួររាល់ចម្ងល់ទាំងឡាយស្ដីពីពន្ធដារ ដូចជា៖

- ច្បាប់និងលិខិតបទដ្ឋានគតិយុត្តស្ដីពីពន្ធដារ
- សេវាកម្មអេឡិចត្រូនិក
- ការចុះបញ្ជីនិងការធ្វើបច្ចុប្បន្នភាពព័ត៌មានអ្នកជាប់ពន្ធ
- ពន្ធលើអចលនទ្រព្យ និងពន្ធលើដីធ្លីមិនបានប្រើប្រាស់
- ពន្ធប្រថាប់ត្រា
- ពន្ធលើមធ្យោបាយដឹកជញ្ជូន
- ការប្រកាសបង់ពន្ធទូទៅ និង
- ព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងពន្ធដារ




## ឬលោកអ្នកអាច Chat សួរសំណួរពីពន្ធដារតាម កម្មវិធី GDT Live Chat ដោយគ្រាន់តែស្កេន QR Code ខាងក្រោម



# កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration)

**ដាក់លិខិតរដ្ឋបាលនិងឯកសារនានាមករដ្ឋបាលសារពើពន្ធបានពីគ្រប់ទីកន្លែង ដោយគ្រាន់តែប្រើប្រាស់កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ ( GDT e-Administration ) តាមជំហានងាយៗដូចខាងក្រោម៖**

**ជំហានទី ១**

ចូលទៅកាន់គេហទំព័រផ្លូវការរបស់អគ្គនាយកដ្ឋានពន្ធដារ **https://www.tax.gov.kh** ជ្រើសរើសសេវាកម្មអេឡិចត្រូនិកពន្ធដារ និងទាញយក (**Download**) កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ (**GDT e-Administration**) រួចដំឡើង (**Setup**) កម្មវិធីនេះនៅលើកុំព្យូទ័រជាការស្រេច។

**ជំហានទី ២**

ប្រើប្រាស់គណនីដែលមានស្រាប់ដូចធ្លាប់ចូលប្រើប្រាស់ប្រព័ន្ធ កម្មវិធីផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ ក្នុងករណីមិនទាន់មានគណនី សូមចុះឈ្មោះប្រើប្រាស់ដោយចុច "**បង្កើតគណនីថ្មី**"។

**ជំហានទី ៣**

ជ្រើសរើសប្រភេទអ្នកប្រើប្រាស់ជា អ្នកជាប់ពន្ធ ឬភ្នាក់ងារសេវាកម្មពន្ធដារ ឬអ្នកតំណាងសហគ្រាស រួចបញ្ចូលព័ត៌មាន និងឯកសារដែលកម្មវិធីតម្រូវ។

**ជំហានទី ៤**

ចុចម៉ឺនុយ "**បង្កើតលិខិតរដ្ឋបាលថ្មី**" បន្ទាប់មកបញ្ចូលព័ត៌មានអ្នកស្នើសុំ កម្មវត្ថុនៃលិខិត និងខ្លឹមសារសង្ខេប រួចជ្រើសរើសអង្គភាពដែលត្រូវទទួលលិខិត។

**ជំហានទី ៥**

ភ្ជាប់លិខិតរដ្ឋបាលនិងឯកសារយោងផ្សេងៗ (**Attachment**) ជាទម្រង់ **PDF** បន្ទាប់មកពិនិត្យផ្ទៀងផ្ទាត់ព័ត៌មានដែលបានបញ្ចូលព្រមទាំងឯកសារភ្ជាប់ឡើងវិញ រួចចុចបញ្ជូនជាការស្រេច។



# ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ




ប្រព័ន្ធគ្រប់គ្រងការស្នើសុំវិញ្ញាបនបត្រពន្ធដារ ត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងគោលបំណង ដើម្បីផ្តល់ភាពងាយស្រួល រហ័ស និងចំណេញពេលវេលាជូនអ្នកជាប់ពន្ធក្នុងការបង្កើតការស្នើសុំ និងបោះពុម្ពវិញ្ញាបនបត្រពន្ធដារ ដូចជា៖

- វិញ្ញាបនបត្រអនុលោមភាពសារពើពន្ធ
- វិញ្ញាបនបត្របញ្ជិកាគណនេយ្យត្រឹមត្រូវ
- វិញ្ញាបនបត្រអនុញ្ញាតអត្រាសូន្យនូវអាករលើតម្លៃបន្ថែម
- វិញ្ញាបនបត្រលើកលែងពន្ធលើប្រាក់ចំណូល៕

សូមស្កេន QR Code ដើម្បីទស្សនាវីដេអូណែនាំពីរបៀបប្រើប្រាស់ប្រព័ន្ធ

# ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក (E-Commerce Tax System)




ដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ ស្របតាមយុគសម័យបរិវត្តកម្មឌីជីថល អគ្គនាយកដ្ឋានពន្ធដារ បានអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-Commerce Tax System ) សម្រាប់អ្នកជាប់ពន្ធប្រើប្រាស់លើមុខងារសំខាន់ៗចំនួន ៤ រួមមាន៖

- ស្នើសុំចុះបញ្ជីសហគ្រាស
- ស្នើសុំធ្វើបច្ចុប្បន្នភាពព័ត៌មាន
- ពិនិត្យមើលប្រវត្តិនៃការបង់ពន្ធ និង
- ទាញយកលិខិតជូនដំណឹងស្តីពីការបំពេញកាតព្វកិច្ចសារពើពន្ធផ្សេងៗ។

ដើម្បីឈ្វេងយល់កាន់តែច្បាស់ពីរបៀបប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យអាជីវកម្មតាមប្រព័ន្ធអេឡិចត្រូនិក ( E-Commerce Tax System ) ដែលមានជាអាទិ៍របៀបចូលប្រើប្រាស់ប្រព័ន្ធ និងការពន្យល់ពីរបៀបប្រើប្រាស់មុខងារនីមួយៗ សូមទស្សនាវីដេអូណែនាំ សូមស្កេន QR Code ខាងលើ៕

# កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (Cambodia Salary Tax Calculation)

កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (Cambodia Salary Tax Calculation) ជាកម្មវិធីទូរស័ព្ទដែលអ្នកជាប់ពន្ធ ពិសេសនិយោជិតអាចប្រើប្រាស់សម្រាប់គណនាពន្ធលើប្រាក់បៀវត្សដោយខ្លួនឯងបានយ៉ាងងាយស្រួលនិងឆាប់រហ័ស និងត្រឹមត្រូវដើម្បីធានានូវភាពត្រឹមត្រូវនៃការកាត់ពន្ធពីនិយោជក។

ក្នុងការគណនាពន្ធលើប្រាក់បៀវត្ស លោកអ្នកត្រូវបំពេញនូវព័ត៌មានចាំបាច់មួយចំនួន ដូចជា៖

- ចំនួនប្រាក់បៀវត្ស
- ចំនួនប្រាក់ឧបត្ថម្ភផ្សេងៗដែលជាកម្មវត្ថុនៃពន្ធលើប្រាក់បៀវត្សចំពោះអត្ថប្រយោជន៍បន្ថែម
- ចំនួនសហព័ទ្ធ និងចំនួនកូនក្នុងបន្ទុក។

លោកអ្នកអាចធ្វើការទាញយក (Download) កម្មវិធីគណនាពន្ធលើប្រាក់បៀវត្ស (Cambodia Salary Tax Calculation) ដោយឥតគិតថ្លៃពី App Store សម្រាប់ប្រព័ន្ធ iOS និងទាញយកពី Play Store សម្រាប់ប្រព័ន្ធ Android៕




# សទ្ទានុក្រមពន្ធដារ ជាជំនួយស្មារតី និងជាមូលដ្ឋានគ្រឹះក្នុងការស្វែងយល់ពាក្យបច្ចេកទេស និងវាក្យសព្ទពាក់ព័ន្ធនឹងពន្ធដារ



# ការប្រកាសនិងបង់ប្រាក់ពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤




# អ្នកជាប់ពន្ធតូចកាន់តែងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធ តាមរយៈកម្មវិធី ( GDT Tax Prefiling App)




ដើម្បីជួយសម្រួលដល់ការប្រកាសនិងបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធតូចអគ្គ-នាយកដ្ឋានពន្ធដារបានបង្កើតនិងដាក់ឱ្យប្រើប្រាស់កម្មវិធីទូរស័ព្ទដៃដែលមានឈ្មោះ កម្មវិធីប្រកាសពន្ធអាជីវកម្មសម្រាប់អ្នកជាប់ពន្ធតូច ( GDT Tax Prefiling App ) ដែលមានមុខងារកត់ត្រាទិន្នន័យទិញ-លក់ជួយគណនាប្រាក់ពន្ធដែលត្រូវបង់ក្នុងការប្រកាសពន្ធប្រចាំខែនិងប្រចាំឆ្នាំ ពិនិត្យមើលទិន្នន័យបំណុលពន្ធ និង បង់ប្រាក់ពន្ធ។

សូមស្កេន ដើម្បីទាញយកកម្មវិធី ប្រកាសពន្ធអាជីវកម្មសម្រាប់ អ្នកជាប់ពន្ធតូច

(GDT Tax Prefiling App)

Download on the App Store

GET IT ON Google Play

YouTube

សូមស្កេន ដើម្បីទស្សនាវីដេអូណែនាំអំពីការប្រើប្រាស់

GDT Tax Prefiling App

# ប្រភពព័ត៌មានអំពីពន្ធដារ




## គេហទំព័រហ្វេសប៊ុកផ្លូវការរបស់ អគ្គនាយកដ្ឋានពន្ធដារ

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ

សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

**សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ**




## ឆាណែលតេឡេក្រាម ព័ត៌មានពន្ធដារកម្ពុជា

សូមស្វាគមន៍ការមកកាន់ប្រព័ន្ធផ្សព្វផ្សាយរបស់អគ្គនាយកដ្ឋានពន្ធដារ

សម្រាប់ការផ្សព្វផ្សាយ និងចែកចាយព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ ។

**សូមស្កេនដើម្បីទទួលបានព័ត៌មានថ្មីៗរាល់ថ្ងៃពីពន្ធដារ**




## តើលោកអ្នកនៅតែមានចម្ងល់ អំពី ពន្ធដារ មែនទេ?

ជួយសម្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនដែលមានចម្ងល់ពាក់ព័ន្ធនឹងពន្ធដារ

បានជជែកផ្ទាល់ជាមួយមន្ត្រីជំនាញពន្ធដារតាមអនឡាញពីគ្រប់ទីកន្លែងរៀងរាល់ម៉ោងធ្វើការ

Download on the App Store

GET IT ON Google Play

**សូមស្កេនដើម្បីទាញយកកម្មវិធី GDT LIVE CHAT**




www.tax.gov.kh/km/tax-bulletin

សូមស្កេន QR Code
ដើម្បីទទួលបានព្រឹត្តិបត្រពន្ធដារ
តាមរយៈទូរស័ព្ទដៃ




www.tax.gov.kh/km/tax-news-letter

សូមស្កេន QR Code
ដើម្បីទទួលបាន
ព្រឹត្តិបត្រព័ត៌មានប្រចាំសប្តាហ៍
តាមរយៈទូរស័ព្ទដៃ




## សម្រាប់ព័ត៌មានបន្ថែមលោក-លោកស្រីអាចទំនាក់ទំនងតាមរយៈ:

Website Facebook Instagram Youtube


អាសយដ្ឋាន ៖ អគារកែងមហាវិថីសហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

មជ្ឈមណ្ឌលពិគ្រោះយោបល់ / Call Center ៖ ១២៧៧ (ដោយឥតគិតថ្លៃ) | គេហទំព័រ ៖ www.tax.gov.kh | សារអេឡិចត្រូនិក ៖ gdt@tax.gov.kh